ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១៦)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(16)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2012, 15:48
CMS/CFO: Uch Arun

| | |
|---|---|
| នៅចំពោះមុខ: | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម Agnieszka KLONOWIECKA-MILART** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Florence NDEPEDL MWACHANDE MUMBA** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម យ៉ា ណារិន** |
| កាលបរិច្ឆេទ: | **ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២** |
| ភាសា: | **ខ្មែរ/អង់គ្លេស** |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខឆ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**ជនជាប់ចោទ**

អៀង ធីរិទ្ធ

**អ្នកអាណាព្យាបាលទូទៅ**

អៀង វិជីដា

**មេធាវីជនជាប់ចោទ**

ផាត់ ពៅស៊ាង
Diana ELLIS, QC

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល”) និង(“អ.វ.ត.ក”) បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ដែលបានដាក់នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ប្រឆាំងនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (“បណ្តឹងសាទុក្ខភ្លាមៗ”)[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (“សេចក្តីសម្រេចដែលរងការជំទាស់”)[2] ដែលអង្គជំនុំជម្រះសាលាដំបូងបានតម្កល់សេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួនថា អៀង ធីរិទ្ធ នៅតែពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះបានទេ ដោយសារតែជំងឺវង្វេងស្មារតីដែលចេះតែវិវឌ្ឍន៍ទៅមុខ (ដែលទំនងថា ជាជំងឺ Alzheimer) និងបានរកឃើញថា វាហាក់ដូចជាគ្មានការរំពឹងសមហេតុផលដែលថា ការធ្លាក់ចុះខ្សោយខាងបញ្ញាស្មារតីរបស់គាត់ អាចត្រូវបានធ្វើឲ្យប្រសើរឡើងវិញបានឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបន្តផ្អាកកិច្ចដំណើរការនីតិវិធីដោយមិនកំណត់រយៈពេល និងដោះលែងជនជាប់ចោទជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ។

[1] បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ [ E138/1/10/1/1] (“បណ្តឹងសាទុក្ខភ្លាមៗ”)។

[2] សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E138/1/10 (“សេចក្តីសម្រេចដែលរងការជំទាស់”)។

2. នៅក្នុងរយៈពេល ២៤ ម៉ោង នៃសេចក្ដីសម្រេចដែលរងការជំទាស់ សហព្រះរាជអាជ្ញាបានដាក់សំណើជូនប្រធានអង្គជំនុំជម្រះតុលាការកំពូលសុំផ្អាកដីកាបង្គាប់ឲ្យដោះលែង[3] រួមជាមួយនឹងបណ្ដឹងសាទុក្ខភ្លាមៗមួយច្បាប់របស់សហព្រះរាជអាជ្ញា ដែលនៅក្នុងបណ្ដឹងសាទុក្ខនោះ សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែម[4]។

3. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានផ្អាកដីកាបង្គាប់ឲ្យដោះលែងត្រង់ចំណុចដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ និងបានបង្គាប់ថា ក្នុងពេលរង់ចាំការសម្រេចលើបណ្ដឹងសាទុក្ខនេះ ជនជាប់ចោទត្រូវបានដោះលែង ដោយស្ថិតក្រោមលក្ខខណ្ឌថា ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែនរបស់ខ្លួន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ និងត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ[5]។ ជនជាប់ចោទត្រូវបានដោះលែងពីមន្ទីរឃុំឃាំង អ.វ.ត.ក នៅថ្ងៃនោះ។

4. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់ការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែម[6] ដែលបានដាក់នៅ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១២[7]។

5. សហមេធាវីជន ជាប់ចោទបានដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២[8] ហើយបានស្នើសុំបើកសវនាការផ្ទាល់មាត់លើបណ្ដឹងសាទុក្ខនេះ។

---

[3] សំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E138/1/10/1/2។

[4] បណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣(ខ)។

[5] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្ដីសេចក្ដីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E138/1/10/1/2/1។

[6] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែមលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាបង្គាប់ដោះលែង អៀង ធីរិទ្ធ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E138/1/10/1/3/1។

[7] សារណាបន្ថែមរបស់សហព្រះរាជអាជ្ញា បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្ដីសម្រេច របស់អង្គជំនុំ ជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E138/1/10/1/5។

[8] ចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំ

6. អង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតតាមសំណើសុំរបស់មេធាវីការពារក្តី[9] ហើយបានបើកសវនាការលើបណ្តឹងសាទុក្ខ នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។ បន្ថែមលើការស្តាប់សារណា ផ្ទាល់មាត់របស់អយ្យការ និងមេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលបានសួរសំណួរទៅកាន់ជនជាប់ចោទ និងអ្នកអាណាព្យាបាលទូទៅ គឺលោកស្រី អៀង វិជីដា ដែលមានវត្តមាននៅក្នុងសវនាការ។

## II. ប្រវត្តិនីតិវិធី

7. មុនពេលសង្ខេបសេចក្តីសម្រេចដែលរងការជំទាស់ និងសារណាដែលពាក់ព័ន្ធ ការរំឭកឡើងវិញនូវប្រវត្តិនីតិវិធី និងអង្គហេតុនានាដែលនាំឲ្យមានសេចក្តីសម្រេច និងសារណាទាំងនេះគឺជាការចាំបាច់។

8. បន្ទាប់ពីមានការដាក់សំណើមួយពីមេធាវីការពារក្តី អៀង ធីរិទ្ធ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលលើកឡើងថា "សុខភាពខួរក្បាលរបស់ជនជាប់ចោទកំពុងតែរារាំងសមត្ថភាពរបស់មេធាវីការពារក្តីក្នុងការត្រៀមរៀបចំការជំនុំជម្រះដែលនឹងមកដល់ឆាប់ៗនេះ"[10] អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងក្រុមអ្នកជំនាញពីរក្រុម ដើម្បីធ្វើការវាយតម្លៃសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ៖ ក្រុមទីមួយ មានវេជ្ជបណ្ឌិតជំនាញផ្នែកព្យាបាលមនុស្សចាស់ (សាស្ត្រាចារ្យ A. John Campbell) ដោយមានការគាំទ្រពីវេជ្ជបណ្ឌិតជំនាញផ្នែកវិកលវិទ្យា (វេជ្ជបណ្ឌិត ការ ស៊ុនបូណាត) ហើយក្រុមបន្ទាប់មកទៀត មានវេជ្ជបណ្ឌិតជំនាញផ្នែកវិកលវិទ្យាចំនួនបួនរូប (វេជ្ជបណ្ឌិត ហួត លីនណា វេជ្ជបណ្ឌិត កើត ឈុនលី វេជ្ជបណ្ឌិត Seena Fazel និងវេជ្ជបណ្ឌិត Calvin Fones Soon Leng)[11]។ អ្នកជំនាញដែលត្រូវបានចាត់តាំងទាំងនោះ បានធ្វើតេស្តមួយចំនួននៅចន្លោះខែ មេសា និងខែ តុលា ឆ្នាំ ២០១១។ អ្នកជំនាញទាំងអស់នោះបានសន្និដ្ឋានថា ជនជាប់ចោទមានជំងឺវង្វេងស្មារតីធ្ងន់ធ្ងរកម្រិតមធ្យម អាចថាជាជំងឺវង្វេងវង្វាន់"[12]។ អ្នកជំនាញកត់សម្គាល់ថា ការសាកល្បងប្រើឱសថ Donepezil

---

ជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ និងសារណាបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E138/1/10/1/5/3 ("សារណាតបរបស់មេធាវីការពារក្តី")។

[9] ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E138/1/10/1/5/5។

[10] សំណើរបស់មេធាវីការពារក្តីស្នើសុំចាត់តាំងអ្នកជំនាញផ្នែកវិកលចរិតដើម្បីវាយតម្លៃសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការជម្រះក្តី ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E52 កថាខណ្ឌ ៣៦។

[11] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138 កថាខណ្ឌ ១ ("សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទា")។

[12] របាយការណ៍របស់អ្នកជំនាញផ្នែកមនុស្សចាស់របស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ នៅក្នុងការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E62/3 ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១

ដែលជាប្រភេទឱសថសម្រាប់ព្យាបាលជំងឺវង្វេងវង្វាន់ ដែលមានប្រសិទ្ធិភាពលើអ្នកជំងឺ ប្រហែលមួយភាគបី[13] រួមជាមួយនឹងវិធីព្យាបាលដោយចលនានោះ អាចធ្វើឱ្យមុខងារដំណើរការខួរក្បាលរបស់ជនជាប់ចោទមានលក្ខណៈល្អប្រសើរតិចតួច[14]។

9. នៅក្នុងសេចក្តីសម្រេចមួយដែលបានចេញនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើសម្បទាលើកទីមួយរបស់អង្គជំនុំជម្រះសាលាដំបូង") អង្គជំនុំជម្រះសាលាដំបូងបានប្រកាសជាឯកច្ឆន្ទថា ជនជាប់ចោទពុំមានសម្បទា ដើម្បីចូលរួមក្នុងសវនាការបានឡើយ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យបំបែកបទចោទប្រកាន់ លើជនជាប់ចោទ ប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើជនជាប់ចោទ និងបង្គាប់ឱ្យដោះលែង ជនជាប់ចោទពីមន្ទីរឃុំឃាំង។ អង្គជំនុំជម្រះ សាលាដំបូងមិនបានឈានទៅដល់ការយល់ស្របគ្នាឡើយ ពាក់ព័ន្ធនឹងថាតើ គួរបង្គាប់ឱ្យជនជាប់ចោទ ទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្របន្ថែមទៀត ឬគួរដោះ លែងគាត់ដោយគ្មានលក្ខខណ្ឌ។ ចៅក្រមចំនួនបីរូបយល់ឃើញថា គួរតែដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌមួយចំនួនហើយផ្ទេរជនជាប់ចោទទៅមន្ទីរពេទ្យដើម្បីទទួលបាន នូវការព្យាបាល ដូចដែលអ្នកជំនាញផ្នែកវេជ្ជសាស្ត្របានណែនាំ ដោយផ្អែកទៅលើមាត្រា ២២៣(១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងយុត្តិសាស្ត្រអន្តរជាតិ[15]។ ចៅក្រមពីររូបផ្សេងទៀតយល់ឃើញថា ពុំមានមូលដ្ឋានគតិយុត្តិណាមួយក្នុងការដាក់លក្ខខណ្ឌភ្ជាប់ទៅនឹងការដោះលែងជនជាប់ចោទ ឬបង្គាប់ឱ្យលោកស្រីចូលសម្រាកក្នុងមន្ទីរពេទ្យនោះទេ ពីព្រោះកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ដោយគ្មាន មូលហេតុសមស្របថានឹងមានការជំនុំជម្រះក្តីលើរូបគាត់ឡើងវិញបានឡើយ និងបានសន្និដ្ឋានថា ជម្រើសតែមួយគត់ដែលមានគឺត្រូវដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ[16]។ ដោយអវត្តមាននៃសំឡេងគាំទ្រលើសលុបចំនួនបួនសំឡេង អង្គជំនុំ

---

ឯកសារលេខ E62/3/6 កថាខណ្ឌ ៤០ ("របាយការណ៍អ្នកជំនាញផ្នែកមនុស្សចាស់")។ របាយការណ៍លើ អៀង ធីរិទ្ធ យោងតាមដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E62/3 ចុះថ្ងៃទី 04 ខែ មេសា ឆ្នាំ ២០១១ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E62/3/12 ("របាយការណ៍តាមដានរបស់អ្នកជំនាញផ្នែកមនុស្សចាស់")។ *សូមមើល* របាយការណ៍អ្នកជំនាញដែលរៀបចំជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E111 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ថ្ងៃទី 0៩ ខែ តុលា ឆ្នាំ ២០១១ E111/8 កថាខណ្ឌ ៣៦ ("របាយការណ៍អ្នកជំនាញចិត្តសាស្ត្រ") លើកឡើងថា "ដើម្បីឱ្យមានតុល្យភាព យើងនឹងយល់ស្របជាមួយការវិភាគជំងឺ Alzheimer"។

[13] របាយការណ៍វាយតម្លៃបន្ថែមរបស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ៨។

[14] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ ៣៨។

[15] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទា កថាខណ្ឌ ៦៥-៦៧។

[16] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទា កថាខណ្ឌ ៧៤-៧៦។

ជម្រះសាលាដំបូងបានយល់ស្របជាឯកច្ឆន្ទថា លទ្ធផលនៃការមិនព្រមព្រៀងគ្នានោះ គឺការដោះលែងដោយឥតលក្ខខណ្ឌ។

10. ដោយបានពិចារណាលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធដីកាបង្គាប់ឱ្យដោះលែងរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១[17]។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យមានការព្យាបាលបន្ថែមដល់ជនជាប់ចោទ ដែលការព្យាបាលនេះត្រូវធ្វើឡើងនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀត ដោយត្រូវមានការត្រួតពិនិត្យលើជនជាប់ចោទដើម្បីកំណត់ថាតើ ជនជាប់ចោទមានសម្បទាចូលរួមសវនាការដែរ ឬយ៉ាងណា ហើយការត្រួតពិនិត្យនេះត្រូវធ្វើឡើងក្នុងរយៈពេល ០៦(ប្រាំមួយ)ខែ គិតចាប់ពីពេលចាប់ផ្តើមការព្យាបាល[18]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ផ្អែកទៅលើការយល់ឃើញសំខាន់ៗចំនួនបី។

11. ទីមួយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ការផ្អាកកិច្ចដំណើរការនីតិវិធីដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង មិនមែនជាការសម្រេចសេចក្តីដែលមានលក្ខណៈអចិន្ត្រៃយ៍នោះទេ"[19]។ ជាពិសេស អង្គជំនុំជម្រះយល់ឃើញថា ៖

> "'ការផ្អាក' សំដៅដល់ 'ការពន្យារ ឬការព្យួរកិច្ចដំណើរការនីតិវិធី សាលក្រម ឬដែលមានលក្ខណៈប្រហាក់ប្រហែល' និងសំដៅដល់ 'ការបង្គាប់ឱ្យបង្អស់ទាំងស្រុង ឬផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីតុលាការ ឬសាលក្រមដែលចេញមកពីកិច្ចដំណើរការនីតិវិធីនោះ'។ នៅពេលដែលមានការអនុញ្ញាតឱ្យផ្អាកកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ការផ្អាកនេះមានតួនាទីដោះស្រាយឧបសគ្គដែលកើតមានយូរអង្វែងចំពោះការបន្តកិច្ចដំណើរការនីតិវិធី។ ជាចុងក្រោយ ទោះបីជាឧបសគ្គមិនទាន់បានដោះស្រាយក៏ដោយ ក៏ស្ថានភាពនៃការផ្អាកនេះត្រូវបានផុតរលត់ ដោយសារការបញ្ចប់នៃដំណើរការនីតិវិធី បន្ទាប់ពីមរណភាពរបស់ជនជាប់ចោទ ឬផុតអាជ្ញាយុកាលនៅពេលដែលប្រព័ន្ធច្បាប់អនុញ្ញាតដូច្នេះ។ [...] លក្ខណៈពិសេសមួយដែលជាផលវិបាកបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធីនេះ គឺថា ទោះបីជាកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាកក៏ដោយ ក៏ការផ្អាកនេះមិនបានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ដែលមានគោលបំណងដោះស្រាយ

[17] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/7 ("សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ") ផ្នែកសម្រេចសេចក្តី។

[18] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារ E138/1/7 ផ្នែកសម្រេចសេចក្តី។

[19] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣៨។

បញ្ហាដែលជាឧបសគ្គនោះដែរ។ ការបំពេញកិច្ចដំណើរការនីតិវិធីនេះ គឺជាកាតព្វកិច្ចរបស់អាជ្ញាធរដែលមានយុត្តាធិការលើរឿងក្តីនេះ”[20]។

12. ទីពីរ បន្ទាប់ពីបានពិនិត្យលើយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធ និងពិនិត្យទៅលើយុត្តាធិការជាតិមួយចំនួនរួចមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ៖

> “(...) ការដោះលែងដោយគ្មានលក្ខខណ្ឌ គឺមិនមែនជាជម្រើសតែមួយគត់ដែលមាននៅក្នុងតុលាការព្រហ្មទណ្ឌ ដែលបានផ្អាក ឬពន្យារកិច្ចដំណើរការនីតិវិធី ដោយសារតែឧបសគ្គមួយដែលអាចនឹង ដោះស្រាយនៅពេលខាងមុខប៉ុណ្ណោះទេ។ ការមិនមានសម្បទា ឬឧបសគ្គធ្ងន់ធ្ងរដទៃទៀតដែល រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី មិនមែនធ្វើឲ្យតុលាការមិនអាចយកវិធានការដទៃទៀតមកអនុវត្តបាន ដូចជាការបន្តឃុំខ្លួនដែលធ្វើក្នុងគោលបំណងធានាវត្តមានរបស់ជនជាប់ចោទនៅពេល ជំនុំជម្រះនោះទេ”[21]។

13. ទីបី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា “ដោយពិចារណាលើអត្ថប្រយោជន៍នៃយុត្តិធម៌ក្នុងការជំនុំជម្រះក្តីជនជាប់ចោទ បន្ទាប់ពីរកឃើញថាគ្មានសម្បទានោះ វិធានការដោះស្រាយត្រូវតែធ្វើឡើង ដោយផ្អែកលើលទ្ធភាពដែលអាចមាន ទោះបីជាតិចតួចក៏ដោយ ក្នុងការធ្វើឲ្យមានភាពប្រសើរឡើង ដោយពិតប្រាកដនោះ”[22]។ ទោះបីជាមានការយល់ឃើញថា លទ្ធភាពនៃការធ្វើឲ្យប្រសើរឡើងផ្នែក បញ្ញាស្មារតី មានតិចតួចក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដោយពិចារណាទៅលើ យោបល់របស់អ្នកជំនាញ មតិភាគតិចនៃអង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនបាន ប្រើឲ្យអស់ពីលទ្ធភាពនូវវិធានការដែលអាចធ្វើបាន ក្នុងការធ្វើឲ្យសុខភាពស្មារតីរបស់ជនជាប់ចោទ ប្រសើរឡើង ដែលអាចឲ្យជនជាប់ចោទមានសម្បទាចូលរួមក្នុងការជំនុំជម្រះក្តីនៅពេលខាងមុខឡើយ[23]។ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា “ទោះបីភាពប្រសើរឡើងវិញបានយូរអង្វែងមិនអាចធ្វើទៅបានក៏ដោយ ក៏ដំណើរការនីតិវិធីព្រហ្មទណ្ឌនៅតែមានអានុភាពដដែល ដោយហេតុថា ភាពប្រសើរឡើង អាចកើតមានក្នុងពេលមួយដែលចាំបាច់ ក្នុងការសម្រួលដល់ការជំនុំជម្រះក្តីព្រហ្មទណ្ឌនាពេលបន្ទាប់”[24]។

---

[20] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៨។

[21] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៥។

[22] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៩។

[23] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣៧។

[24] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣៧។

14. នៅក្នុងការសម្រេចថាតើត្រូវចាត់វិធានការបែបណា ទាក់ទិននឹងជនជាប់ចោទដែលពុំមានសម្បទានោះ អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថា មានគោលបំណងពីរដែលត្រូវអនុវត្តក្នុងពេលដំណាលគ្នា[25]។ ទីមួយ គឺដើម្បីធានានូវវត្តមានរបស់ជនជាប់ចោទក្នុងពេលជំនុំជម្រះនៅពេលបន្តការជំនុំជម្រះឡើងវិញ។ ទីពីរ គឺដើម្បីជំរុញឲ្យមានភាពប្រសើរឡើងដល់សុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទ ដោយអនុវត្តនូវការព្យាបាលតាមអ្នកជំនាញបានណែនាំ[26]។ ក្នុងការស្វែងរកជម្រើសនៃការដាក់នូវវិធានការដែលមានលក្ខណៈរិតត្បិតតិចជាងការឃុំខ្លួន ដើម្បីសម្រេចឲ្យបាននូវគោលបំណងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថា ការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺអាចយកមកអនុវត្តបាននៅដំណាក់កាលជំនុំជម្រះ[27]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ៖

> "ទោះបីជាការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាជម្រើសមួយនៅក្នុងរឿងក្ដីនេះក៏ដោយ ក៏ពុំមានការលើកឡើងពី បញ្ហានេះនៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់ ដែលនឹងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការកំណត់ ពីបញ្ហាថាតើ មានមូលដ្ឋានអង្គហេតុក្នុងការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការដែរ ឬយ៉ាងណា។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ពុំមានមធ្យោបាយក្នុងការកំណត់ច្បាស់លាស់ពីបញ្ហាថាតើ ជនជាប់ចោទមានឆន្ទៈ និងលទ្ធភាព (ដោយពិចារណាលើភាពពុំមានសម្បទាក្នុងការយល់ ការចងចាំដែលបានបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង) ក្នុងការទទួលយក 'កាតព្វកិច្ច' មួយក្នុងចំណោមនោះ នៅក្នុងអំឡុងពេលនៃការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ (...) ក្នុងការធានាឲ្យបានថា ជនជាប់ចោទអាចបំពេញកាតព្វកិច្ចរបស់ខ្លួន ទាក់ទិននឹងការត្រួតពិនិត្យតាមផ្លូវតុលាការ ចាំបាច់ត្រូវតែមានការធានាពីបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងជនជាប់ចោទ និងអ្នកដែលមានឆន្ទៈ ជួយដល់ជនជាប់ចោទជំនះនឹងភាពមិនមានសមត្ថភាពស្មារតី ដើម្បីធានាការបំពេញកាតព្វកិច្ចនេះជំនួសជនជាប់ចោទ និងដើរតួនាទីជាអ្នកជំនួស"[28]។

អង្គជំនុំជម្រះបានសន្និដ្ឋានថា "ការបន្តឃុំខ្លួនមានលក្ខណៈចាំបាច់ រហូតដល់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ការព្រួយបារម្ភខាងលើបានចុះថយ"[29]។ អង្គជំនុំជម្រះបានសម្រេចថា ការឃុំខ្លួនគួរតែអនុវត្ត

[25] សេចក្ដីសម្រេចទីមួយលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤១។

[26] សេចក្ដីសម្រេចទីមួយលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤១។

[27] សេចក្ដីសម្រេចទីមួយលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៦។

[28] សេចក្ដីសម្រេចទីមួយលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៧។

[29] សេចក្ដីសម្រេចទីមួយលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៨។

នៅក្នុងមន្ទីរពេទ្យ ឬកន្លែងប្រហាក់ប្រហែល[30] និងបានចង្អុលបង្ហាញថា ការបន្តការឃុំខ្លួននេះ គឺតម្រូវឲ្យមានការពិនិត្យឡើងវិញ អនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង នៅពេលមានការស្នើសុំពី ជនជាប់ចោទ។

15. ក្រោយពីអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេច និងស្ថិតក្រោមការត្រួតពិនិត្យនៃអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវបានព្យាបាលនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដែលនៅទីនោះ លោកស្រីទទួលបានរបបព្យាបាល និងការប្រើប្រាស់ឱសថថ្មីមួយ ទៅតាមអនុសាសន៍របស់អ្នកជំនាញ ដែលត្រូវបានចាត់តាំងដោយតុលាការ។

16. នៅថ្ងៃទី ២៧ និង ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ អ្នកជំនាញដែលមានវត្តមានបានធ្វើការពិនិត្យជនជាប់ចោទ ដើម្បីកំណត់ថាតើវិធីសាស្ត្រព្យាបាល ដែលគ្រូពេទ្យព្យាបាលបានប្រើប្រាស់បាន ឬពុំបាន ធ្វើឲ្យសមត្ថភាពបញ្ញាស្មារតីរបស់លោកស្រី មានភាពប្រសើរឡើងវិញ រហូតអាចផ្ដល់លទ្ធភាពឲ្យលោកស្រីមានសម្បទាចូលរួមការជំនុំជម្រះក្ដីដែរ ឬយ៉ាងណា។ អ្នកជំនាញបានសន្និដ្ឋានថា "ពុំមានភស្តុតាង (...) នៃការបានធូរស្រាលណាមួយឡើយ បន្ទាប់ពីការប្រើប្រាស់ឱសថ Rivastigmine និងកម្មវិធីលើកកម្ពស់បញ្ញាស្មារតី" ទោះបីជាពេលវេលាគ្រប់គ្រាន់ដើម្បីឲ្យការព្យាបាលទាំងនេះទទួលបានប្រសិទ្ធភាពបានកន្លងផុតទៅហើយ ប្រសិនបើការព្យាបាលទាំងនេះនឹងមានប្រសិទ្ធភាព[31]។ អ្នកជំនាញបានផ្ដល់អនុសាសន៍ថា ការព្យាបាលទាំងនេះគួរបញ្ឈប់ ហើយអ្នកជំនាញបានលើកឡើងថា ខ្លួនពុំដឹងថាតើមានការព្យាបាលណាផ្សេងទៀត ដើម្បីធ្វើឲ្យសមត្ថភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ មានភាពល្អប្រសើរឡើងវិញឡើយ[32]។ អ្នកជំនាញបានសន្និដ្ឋានថា ជនជាប់ចោទមានជំងឺ "វង្វេងស្មារតីពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ"[33]។ នៅក្នុងការយល់ឃើញរបស់អ្នកជំនាញ ជំងឺវង្វេងស្មារតីរបស់ជនជាប់ចោទ បានវិវឌ្ឍន៍កាន់តែធ្ងន់ធ្ងរចាប់តាំងពីឆ្នាំ ២០១១ ហើយក៏មានការធ្លាក់ចុះបន្តិចបន្តួចនៃសមត្ថភាពបញ្ញាស្មារតីរបស់គាត់ ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ បើទោះជាមានការព្យាបាលថ្មីៗនេះក៏ដោយ[34]។ អ្នក

[30] សេចក្ដីសម្រេចទីមួយលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤២ និងផ្នែកសម្រេចសេចក្ដី។

[31] របាយការណ៍សង្ខេបរបស់អ្នកជំនាញស្ដីពី អៀង ធីរិទ្ធ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ E138/1/7/13/2 ("របាយការណ៍សង្ខេបរបស់អ្នកជំនាញ ឆ្នាំ ២០១២") កថាខណ្ឌ ៥៨។

[32] របាយការណ៍សង្ខេបរបស់អ្នកជំនាញ កថាខណ្ឌ ៥៨-៥៩។

[33] របាយការណ៍សង្ខេបរបស់អ្នកជំនាញ កថាខណ្ឌ ៦០។

[34] របាយការណ៍សង្ខេបរបស់អ្នកជំនាញ កថាខណ្ឌ ៦០។

ជំនាញនៅតែយល់ឃើញថា ជនជាប់ចោទនឹងមាន "ការលំបាកខ្លាំង" ក្នុងការបំពេញលក្ខណវិនិច្ឆ័យនៃសម្បទាចូលរួមក្នុងការជំនុំជម្រះក្តី[35]។

## III. សេចក្តីសម្រេចដែលរងការជំទាស់

17. ផ្អែកតាមការរកឃើញរបស់អ្នកជំនាញវេជ្ជសាស្ត្រ ដែលបានបង្ហាញឲ្យឃើញថា ជនជាប់ចោទពិតជារងនូវស្ថានភាពវង្វេងស្មារតី ដែលចេះតែវិវឌ្ឍន៍ទៅមុខ (ទំនងយ៉ាងខ្លាំងថាជាជំងឺ Alzheimer) នោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជាថ្មីអំពីសេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួនដែលថា ការបាត់បង់ការចងចាំរយៈពេលខ្លី និងរយៈពេលវែងរបស់ជនជាប់ចោទ ពិតជាធ្វើឲ្យគាត់ពុំមានសមត្ថភាពយល់ដឹងគ្រប់គ្រាន់អំពីការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី និងពុំអាចពិគ្រោះយោបល់ជាមួយនឹងមេធាវីបានគ្រប់ជ្រុងជ្រោយ និងពុំអាចចូលរួមក្នុងការការពារខ្លួនប្រកបដោយប្រសិទ្ធភាពឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញទៀតថា វាហាក់ដូចជាគ្មានរំពឹងសមហេតុផលដែលថា ជនជាប់ចោទអាចប្រែជាមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការនាពេលខាងមុខ ដែលគេអាចប្រមើលដឹង ពីព្រោះថា ការសាកល្បងព្យាបាលតាមគ្រប់វិធីសាស្ត្រ ដែលអាចធ្វើទៅនាពេលបច្ចុប្បន្ន ដើម្បីធ្វើឲ្យស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទមានភាពប្រសើរឡើងវិញនោះ ត្រូវបានយកមកប្រើប្រាស់អស់លទ្ធភាពហើយ ហើយជនជាប់ចោទពុំទំនងជាធូរស្រាលឡើយ[36]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឲ្យផ្អាកកិច្ចដំណើរការនីតិវិធីនាពេលមុនៗ "បន្តទៀតដោយមិនកំណត់រយៈពេល"[37]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ពាក្យ "មិនកំណត់រយៈពេល" មានន័យថា ផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់មានការបង្គាប់របស់អង្គជំនុំជម្រះ ឲ្យបន្តកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ"[38] ហើយ "បទចោទប្រឆាំងនឹងជនជាប់ចោទនៅតែមាន"[39]។

18. អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការបន្តការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ននៅក្នុងស្ថានភាពដែលទំនងជាគ្មានលទ្ធភាពសមហេតុផលណាមួយ ដែលជនជាប់ចោទអាចប្រឈមនឹងការជំនុំជម្រះនៅក្នុងពេលអនាគតខាងមុខ ដែលគេប្រមើលដឹងនេះ នឹងជាការរំលោភលើសិទ្ធិមូលដ្ឋាននានាដូចមានចែងនៅក្នុងក្របខ័ណ្ឌអន្តរជាតិ ហើយបង្គាប់ឲ្យដោះលែងជនជាប់ចោទឲ្យមានសេរីភាពជា

---

[35] របាយការណ៍សង្ខេបរបស់អ្នកជំនាញ កថាខណ្ឌ ៦២។

[36] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៥។

[37] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨។

[38] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨។

[39] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤០។

បន្ទាន់ពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការឃុំខ្លួនជនជាប់ចោទពុំអាចធ្វើយុត្តិកម្មបាន ផ្អែកលើ"ការប៉ាន់ស្មានផ្នែកវេជ្ជសាស្ត្រដែលថាស្ថានភាពជំងឺដែលមិនអាចព្យាបាលបានពេលបច្ចុប្បន្ន ប៉ុន្តែប្រហែលជាអាចព្យាបាលបាននាពេលអនាគត"[40]។ បន្ថែមពីលើនេះ ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនមានចែងអំពីមូលដ្ឋានច្បាប់ដើម្បីធ្វើជាយុត្តិកម្មក្នុងការបន្តការឃុំខ្លួនជនជាប់ចោទក្នុងកាលៈទេសៈបច្ចុប្បន្ននេះទេ[41]។

19. អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យបង្គាប់ការដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ពោលគឺ ការដោះលែងជនជាប់ចោទឱ្យមានសេរីភាព នឹងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដោយបង្ខំ ដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ផ្អែកលើ*សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី I គឺ "សេចក្តីសម្រេចស្តីពីការដោះលែង* Thomas Lubanga Dyilo *ឱ្យមានសេរីភាព"* ("សេចក្តីសម្រេច Lubanga") ដែលបានចេញដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")[42] ការផ្អាកកិច្ចដំណើរការនីតិវិធីមានន័យថា អង្គជំនុំជម្រះសាលាដំបូង "មិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើជនជាប់ចោទបានទេ ក្នុងរយៈពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធីនេះ"[43]។ យោងតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង យុត្តាធិការតុលាការលើជនជាប់ចោទត្រូវបាន "ផ្អាក" ក្នុងពេលផ្អាកកិច្ចដំណើរការនីតិវិធីនេះ[44]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខ្លួន"មិនមាន (...) មូលដ្ឋានគតិយុត្តិច្បាស់លាស់ ដើម្បីកំណត់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការតាមទម្រង់ផ្សេងៗលើជនជាប់ចោទ នៅពេលដោះលែងទេ"[45]។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូង

[40] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៩។

[41] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣០។

[42] រដ្ឋអាជ្ញា ទល់នឹង Lubanga, សំណុំរឿងលេខ ICC-01/04-01/06-1468, សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំង នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ហៅថា " សេចក្តីសម្រេចស្តីពីផលវិបាកនៃភាពសម្ងាត់នៃភស្តុតាងដោះបន្ទុក តាមមាត្រា ៥៤(៣)(ង)នៃកិច្ចព្រមព្រៀង និងសំណើសុំផ្អាកការចោទប្រកាន់លើជនជាប់ចោទ រួមជាមួយនឹងបញ្ហាមួយចំនួន ដែលបានលើកឡើងក្នុងកិច្ចប្រជុំទាក់ទងនឹងឋានៈនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចលើរឿងក្តី Lubanga ")"។

[43] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨។

[44] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៣។

[45] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៣។

00869518



ផ្អែកតាមអង្គហេតុ យល់ឃើញថា រឿងក្ដីបច្ចុប្បន្នខុសពីរឿងក្ដីអន្តរជាតិផ្សេងៗទៀត ដែលសហព្រះរាជអាជ្ញាបានយកមកធ្វើជាមូលដ្ឋានដើម្បីគាំទ្រលើសំណើសុំរបស់ខ្លួន។ ចំណុចចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់បន្ថែមទៀតថា ក្នុងស្ថានភាពវេជ្ជសាស្ត្ររបស់ជនជាប់ចោទ អៀង ធីរិទ្ធ លក្ខខណ្ឌដោយបង្ខំ នៅក្នុងករណីណាក៏ដោយ គឺតាមសភាពជាក់ស្តែង ឬ តាមផ្លូវច្បាប់ ទំនងជាមិនអាចអនុវត្តបានឡើយ[46]។

20. ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ខ្លួនពុំជំទាស់នឹងវិធានការជាច្រើនដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះទេ[47]។ នៅក្នុងផ្នែកសម្រេចសេចក្តី អង្គជំនុំជម្រះសាលាដំបូងបានរំលឹកអំពីកាតព្វកិច្ចនានា ដូចមានចែងនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលជនជាប់ចោទត្រូវគោរពតាម ពោលគឺ មិនត្រូវជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការ។ អង្គជំនុំជម្រះបានស្នើសុំជនជាប់ចោទឲ្យស្ថិតនៅក្នុងរង្វង់ទឹកដីកម្ពុជា ហើយឲ្យជនជាប់ចោទជូនដំណឹងដល់តុលាការ មុនពេលផ្លាស់ប្តូរអាសយដ្ឋាន ព្រមទាំងធ្វើការពិគ្រោះយោបល់ជាមួយអ្នកជំនាញជារៀងរាល់ឆ្នាំ អំពីការវិវឌ្ឍន៍វេជ្ជសាស្ត្រ ដែលទំនងជាអាចធ្វើឲ្យការចុះខ្សោយបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ប្រែក្លាយមកប្រសើរឡើងវិញ ដែលផ្តល់លទ្ធភាពឲ្យជនជាប់ចោទមានសម្បទាចូលរួមក្នុងការជំនុំជម្រះក្តី។

## IV. **សារណា**

21. សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឲ្យមោឃភាពសេចក្តីសម្រេចដែលរងការជំទាស់ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខ្លួនគ្មានយុត្តាធិការក្នុងការបង្គាប់ឲ្យមានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងក្នុង ការកែប្រែសេចក្តីសម្រេចដែលរងការជំទាស់ដែលតម្រូវឲ្យជនជាប់ចោទ តាមរយៈអាណាព្យាបាលរបស់ខ្លួន អនុវត្តតាមលក្ខខណ្ឌដូចតទៅនេះនោះឡើយ៖ (i) ឲ្យស្នាក់នៅផ្ទះដែលមានអាសយដ្ឋានជាក់លាក់ណាមួយ ដែលត្រូវផ្តល់ដោយសហមេធាវីរបស់គាត់ (ii) ឲ្យធ្វើខ្លួនយ៉ាងណាឲ្យអាជ្ញាធរ ឬមន្ត្រីនានាដែលនឹងត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង អាចត្រួតពិនិត្យពីសុវត្ថិភាពចំពោះរូបគាត់ជាប្រចាំសប្តាហ៍ (iii) ឲ្យប្រគល់លិខិតឆ្លងដែននិងអត្តសញ្ញាណប័ណ្ណ (iv) មិនឲ្យធ្វើទំនាក់ទំនងទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយសហជនជាប់ចោទផ្សេងទៀតក្នុងសំណុំរឿង ០០២ (លើកលែងតែប្តីរបស់គាត់ លោកអៀង សារី) (v) មិនឲ្យធ្វើទំនាក់ទំនងទោះដោយផ្ទាល់ ឬ ដោយប្រយោល ជាមួយសាក្សី អ្នកជំនាញ ឬជនរងគ្រោះ

---

[46] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៧។

[47] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៩។

ណាម្នាក់ឡើយ ដែលបានស្នើស្តាប់ចម្លើយដោយអង្គជំនុំជម្រះសាលាដំបូង និងមិនឲ្យជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ និង (vi) ឲ្យមានការត្រួតពិនិត្យខាងវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដែលត្រូវធ្វើឡើងដោយគ្រូពេទ្យដែលត្រូវតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង[48]។

22. យោងតាមទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបានផ្អាកយុត្តិធិការរបស់ខ្លួនលើជនជាប់ចោទ ឬក៏ច្រានចោលយុត្តាធិការនេះ ដោយសារមូលហេតុចំនួនបី៖ ទីមួយ ពុំមានមូលដ្ឋានច្បាប់នៅក្នុងច្បាប់ អ.វ.ត.ក ឬច្បាប់កម្ពុជា សម្រាប់ឲ្យតុលាការជំនុំជម្រះច្រានចោលយុត្តាធិការរបស់ខ្លួន ក្នុងករណីដែលបណ្តឹងអាជ្ញាមិនត្រូវបានបញ្ចប់តាមអនុភាពនៃច្បាប់ នោះ[49]។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC នៅក្នុងសេចក្តីសម្រេច *Lubanga* ឱ្យបានត្រឹមត្រូវ ដោយសារតែការបង្គាប់របស់ខ្លួនលើ“ការផ្អាកដែលអាចកែប្រែបាន និងមិនអចិន្ត្រៃយ៍” តម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូង ត្រូវកំណត់ជាមុនសិន ថាតើលក្ខខណ្ឌឃុំខ្លួនត្រូវបានបំពេញ ដែរ ឬទេ ហើយប្រសិនបើមិនត្រូវបានបំពេញទេនោះ តើការដោះលែងគួរ ឬមិនគួរមានលក្ខខណ្ឌ[50]។ ទីបី សេចក្តីសម្រេចដែលត្រូវបានជំទាស់បានដាក់ឲ្យជនជាប់ចោទក្នុងស្ថានភាពមួយដែលមិនអាចទទួលបានដោយសារតែភាពមិនប្រាកដប្រជាខាងផ្លូវច្បាប់ ហើយមិនទទួលបានការការពាររបស់តុលាការ និងដោយពុំមានការត្រួតពិនិត្យណាមួយ ដែលជាលក្ខខណ្ឌតម្រូវនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ[51]។

23. សហព្រះរាជអាជ្ញាលើកឡើងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយពុំបានអនុវត្តតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៦៥ និងវិធាន ៨២ នៃវិធានផ្ទៃក្នុង ដែលជាមូលដ្ឋានផ្លូវច្បាប់សម្រាប់ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬដាក់លក្ខខណ្ឌដោយបង្ខំ ដូចដែលអង្គជំនុំជម្រះតុលាការកំពូល[52] បានសម្រេចកាលពីពេល មុន ឬ មិនបានប្រើប្រាស់អំណាចរបស់ខ្លួនដែលមានជាប់មកជាមួយ(ទឡ្ហីករណ៍ទីពីរនៃបណ្តឹងសាទុក្ខ)[53]។

---

[48] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១០។ សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧។

[49] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦(ក)។

[50] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦(ខ)។

[51] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦(គ)។

[52] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៧-៩។

[53] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៩។

24. តាមទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយបានបង្គាប់ឱ្យដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ ជំនួសឱ្យលក្ខខណ្ឌសមស្របនៃការត្រួតពិនិត្យរបស់តុលាការ។ សហព្រះរាជអាជ្ញា លើកឡើងថា លក្ខខណ្ឌដែលបានស្នើសុំនោះ បង្កើតឡើងជាចម្បងគេ គឺដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះជាបន្តបន្ទាប់ ប៉ុន្តែក៏ពាក់ព័ន្ធជាមួយនឹងការធានាអំពីសុចរិតភាពនៃដំណើរការនីតិវិធីរបស់តុលាការ ការការពារជនរងគ្រោះ និងសាក្សីសំខាន់ៗ ការការពារជនជាប់ចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ[54] ដែលជាប្រយោជន៍ស្រមតាមវិធាន ៦៥(១) វិធាន ៨២(២) និងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលត្រូវអានផ្គួបផ្គាជាមួយនឹងវិធាន ២១ នៃវិធានផ្ទៃក្នុង[55] និងស្របជាមួយការអនុវត្តនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ[56]។ ជាពិសេសេ សហព្រះរាជអាជ្ញាជំទាស់ថា ការវាយតម្លៃជាប្រចាំលើសមត្ថភាពស្មារតីរបស់ជនជាប់ចោទ គឺជាការពន្យារពេលធម្មតា និងចាំបាច់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីបង្គាប់ឲ្យផ្អាកដំណើរការនីតិវិធីដោយគ្មានរយៈពេលកំណត់ ជាជាងការផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ និងការពិគ្រោះយោបល់ជាមួយអ្នកជំនាញជាទៀងរាល់ឆ្នាំ ទាក់ទងនឹងការរីកចំរើននៃការព្យាបាលជំងឺវង្វេងស្មារតី ដែលចេះតែវិវឌ្ឍន៍ទៅមុខ[57]។ សហព្រះរាជអាជ្ញាអះអាងបន្ថែមថា ដីកាបង្គាប់ឲ្យស្នាក់នៅក្នុងលំនៅដ្ឋានជាក់លាក់មួយ ដែលសហមេធាវីការពារក្តីរបស់គាត់ត្រូវប្រាប់ពីអាសយដ្ឋាន និងការមកត្រួតពិនិត្យមួយសប្តាហ៍ម្តងពីសុវត្ថិភាព ដោយអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីផ្លូវការ ដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង*ក្នុងចំណោមការការពារផ្សេងទៀត* នឹងការពារសុវត្ថិភាពរបស់ជនជាប់ចោទ រក្សាសណ្តាប់ធ្នាប់សាធារណៈ និងរក្សាវត្តមានរបស់ជនជាប់ចោទ ប្រសិនបើដំណើរការនីតិវិធីចាប់ផ្តើមឡើងវិញ[58]។ ការប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ ដែលអង្គជំនុំជម្រះសាលាដំបូងអាចនឹងផ្តល់ឲ្យវិញ ប្រសិនបើចាំបាច់ក្នុងគោលបំណងជាក់លាក់ណាមួយ ក៏អាចនឹងចូលរួមចំណែកដើម្បីធានាថា ជនជាប់ចោទនៅតែនឹងបង្ហាញវត្តមាន ប្រសិនបើ

---

[54] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។ *សូមមើលផងដែរ* កថាខណ្ឌ ២២, ២៤, ២៥, ២៧, ២៩។

[55] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦-៧។

[56] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១១-១៣។

[57] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩។ ដកស្រង់ចេញពីសេចក្តីសម្រេចដែលរងការជំទាស់ផ្នែកសម្រេចសេចក្តី។

[58] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២២-២៤។

ដំណើរការនីតិវិធីចាប់ផ្តើមឡើងវិញ[59]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា ការបង្គាប់កុំឲ្យទាក់ទងនឹងសហជនជាប់ចោទដទៃទៀត សាក្សីសំខាន់ៗ អ្នកជំនាញ ឬជនរងគ្រោះ គឺចាំបាច់ដើម្បីការពារសុចរិតភាព និងភាពយុត្តិធម៌នៃដំណើរការនីតិវិធី ហើយការបង្គាប់បែបនេះ ត្រូវបានទទួលស្គាល់ ផ្អែកតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[60]។ សហព្រះរាជអាជ្ញា ជំទាស់ថា វិធានការទាំងនេះ មានភាពចាំបាច់ និងជាសក្តានុពលនៅក្នុងកាលៈទេសៈនៃរឿងក្តីបច្ចុប្បន្ននេះ។

25. ផ្អែកតាមទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ឬកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិ ដោយយល់ឃើញថា លក្ខខណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នឹងមិនអាចអនុវត្តដោយបង្ខំ ឬពុំមានប្រយោជន៍នោះទេ។ សេចក្តីសន្និដ្ឋានអំពីសំអាងហេតុជាមូលដ្ឋានដែលថា ជនជាប់ចោទមិនអាចនឹងគោរពតាមលក្ខខណ្ឌចាប់បង្ខំ ដោយសារតែការចុះទន់ខ្សោយនៃសមត្ថភាពបញ្ញាស្មារតី មិនអាចសម្រុះសម្រួលត្រឹម "ការរំឭក" និង "ការស្នើ" ចំពោះជនជាប់ចោទនៅក្នុងផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចដែលរងការជំទាស់នោះទេ[61]។ សហព្រះរាជអាជ្ញាគូសបញ្ជាក់អង្គហេតុដែលថា អាណាព្យាបាលមួយរូបត្រូវបានជ្រើសតាំង[62] ដូចនេះសហព្រះរាជអាជ្ញា ស្នើសុំអង្គជំនុំជម្រះតុលាការកំពូលតម្រូវឲ្យជនជាប់ចោទ "តាមរយៈអាណាព្យាបាល" អនុវត្តនូវលក្ខខណ្ឌជាក់លាក់មួយចំនួន ដែលសហព្រះរាជអាជ្ញាបានស្នើសុំឲ្យដាក់នៅពេលដោះលែងជនជាប់ចោទ។

26. ជាការឆ្លើយតប មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលតម្កល់សេចក្តីសម្រេចដែលរងការជំទាស់នេះ និងសុំឱ្យដកលក្ខខណ្ឌដោយបង្ខំបណ្តោះអាសន្នលើការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ។ មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មិនបានដកខ្លួនចេញពីយុត្តាធិការរបស់ខ្លួននោះទេ ប៉ុន្តែអង្គជំនុំជម្រះបានទទួលស្គាល់ពីដែនកំណត់ដែលគួរតែដាក់លើការអនុវត្តយុត្តាធិការផ្នែកព្រហ្មទណ្ឌនោះ ដោយពិចារណាទៅលើកាលៈទេសៈគតិយុត្តិ និងការអនុវត្តជាក់ស្តែងនៃការផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានរយៈពេលកំណត់ ដែលនៅក្នុងករណីនេះ គឺមានលក្ខណៈជាអចិន្ត្រៃយ៍ និងមិនអាចត្រលប់ក្រោយបាន[63]។ ដោយពិចារណាទៅលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង

---

[59] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៥-២៦។

[60] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧។

[61] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១៧។

[62] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២, ៣១។

[63] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ២៩-៣០។

ដែលយល់ឃើញថា ជនជាប់ចោទមិនមានក្តីសង្ឃឹមពិតប្រាកដថាអាចមានភាពធូរស្រាល និងដោយយោងតាមយោបល់របស់អ្នកជំនាញដែលថា លក្ខខណ្ឌរបស់ជនជាប់ចោទ កាន់តែធ្ងន់ធ្ងរទៅៗ[64] ដូចនេះលក្ខខណ្ឌចាប់បង្ខំដែលបានបង្កើតឡើង គឺ ដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ និងភាពមិនជ្រៀតជ្រែកជាមួយនឹងរដ្ឋបាលតុលាការ មិនមែនជាមូលដ្ឋានគតិយុត្តិត្រឹមត្រូវ និងមិនបានបំពេញនូវលក្ខណៈវិនិច្ឆ័យដូចមានកំណត់នៅក្នុងរឿងក្តី *Lubanga*[65]។ ដូចនេះ លក្ខខណ្ឌដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា នឹងបង្កើតបានជាការរំលោភបំពានដោយមិនត្រឹមត្រូវលើសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ[66]។ បន្ថែមពីលើនេះ ជនជាប់ចោទនៅតែស្ថិតក្រោមការការពាររបស់តុលាការ ដោយសារតែសន្តិសុខ និងសុវត្ថិភាពរបស់ជនជាប់ចោទ ស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អនុលោមតាមមាត្រា ២៤ នៃកិច្ចព្រមព្រៀងអ.វ.ត.ក[67]។

27. ទោះក្នុងកាលៈទេសៈណាក៏ដោយ មេធាវីការពារក្តីតវ៉ាបន្ថែមថា ជនជាប់ចោទមិនមានលទ្ធភាពចងចាំយល់ដឹង និងអនុវត្តតាមលក្ខខណ្ឌចាប់បង្ខំណាមួយដែលបានដាក់មកលើរូបគាត់ ដោយសារការអសមត្ថភាពទាំងស្រុងក្នុងការចងចាំព័ត៌មានថ្មី ហើយថា គាត់ស្ថិតក្នុងភាពមិនយល់ដឹងអ្វីៗនៅជុំវិញខ្លួនឡើយ[68]។ បន្ថែមពីលើនេះ មេធាវីការពារក្តីតវ៉ាថា ការតែងតាំងអាណាព្យាបាលទូទៅឲ្យដល់ជនជាប់ចោទ នឹងមិនអាចជួយដល់ការអនុវត្តនូវលក្ខខណ្ឌចាប់បង្ខំនៅពេលដោះលែងជនជាប់ចោទនោះទេ ដោយសារតែច្បាប់ស៊ីវិលកម្ពុជាចែងថា តួនាទីរបស់អាណាព្យាបាល គឺកំណត់ត្រឹមការការពារទ្រព្យសម្បត្តិ និងផ្តល់ការថែទាំវេជ្ជសាស្ត្រ និងផ្តល់នូវការជួយទូទៅដល់បុគ្គលនោះក្នុងឋានៈជាអាណាព្យាបាល[69]។ វាមិនមានមូលដ្ឋានគតិយុត្តិសម្រាប់ដាក់លក្ខខណ្ឌចាប់បង្ខំលើអ្នកអាណាព្យាបាលដែលត្រូវបានតែងតាំងនោះទេ[70]។ មេធាវីការពារក្តីបានលើកឡើងនូវបញ្ហាអំពីដំណើរការដែលនាំឲ្យមានការតែងតាំងអាណាព្យាបាល ដោយសាលាដំបូងរាជធានីភ្នំពេញ ដែលត្រូវបានរាយការណ៍មិនត្រឹមត្រូវដោយសហ

[64] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៥៣។

[65] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៣៣, ៣៥។

[66] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៥១, ៦៥-៦៦។

[67] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៣៧។

[68] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៧១។

[69] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៧៩។

[70] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៧៥។

00869523



ព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានលើកឡើងករណីថា ការប្រើប្រាស់យន្តការនេះ គឺជាការប៉ុនប៉ងដោយសហព្រះរាជអាជ្ញាដើម្បីជៀសចេញពីយុត្តាធិការរបស់ អ.វ.ត.ក[71]។

## V. ការពិភាក្សា

### ក) ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខភ្លាមៗ

28. សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បណ្តឹងសាទុក្ខភ្លាមៗអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ដោយផ្អែកលើមូលដ្ឋានថា ការផ្អាកដោយមិនមានរយៈពេលកំណត់ ដូចបានបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង ក្រោយពីបានពិនិត្យឃើញផលវិបាកនៃការអាក់ខានដែលអាចមានផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធី "មាន*អនុភាព*បញ្ចប់កិច្ចដំណើរការនីតិវិធី"[72]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង ដោយសារវាពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទចេញពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[73]។ ក្រុមមេធាវីការពារក្តីពុំបានដាក់សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១០៤(៤)។

29. បណ្តឹងសាទុក្ខភ្លាមៗនេះ បានប្តឹងតវ៉ាលើសេចក្តីសម្រេចដែលរងការជំទាស់ ដោយហេតុថា សេចក្តីសម្រេចនេះបានច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យដាក់លក្ខខណ្ឌដោយបង្ខំលើការដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក តាមក្របខ័ណ្ឌនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ដោយសារបណ្តឹងសាទុក្ខនេះពាក់ព័ន្ធនឹងលក្ខខណ្ឌដោះលែងជនជាប់ចោទដោយអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខនេះគឺស្ថិតនៅក្នុងវិសាលភាពនៃវិធាន ១០៤(៤)(ខ) នៃវិធានផ្ទៃក្នុង ដែលផ្តល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងការឃុំខ្លួន ឬការដោះលែងឱ្យនៅក្រៅឃុំ អនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ បណ្តឹងសាទុក្ខនេះអាចទទួលយកបាន។

### ខ) អង្គសេចក្តីនៃបណ្តឹងសាទុក្ខភ្លាមៗ

#### ១. បទដ្ឋាននៃការពិនិត្យឡើងវិញ

---

[71] សារណារបស់មេធាវីការពារក្តី កថាខណ្ឌ ៧២-៧៥។

[72] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤(ក)។

[73] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤(ខ)។

30. អនុលោមតាមវិធាន ១០៤(១) និងវិធាន ១០៥(២) នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខនេះអាចធ្វើឡើងដោយផ្អែកលើមូលដ្ឋានចំនួនមួយ ឬលើសពីនេះ ក្នុងចំណោមមូលដ្ឋានទាំងបីដូចខាងក្រោម៖

-កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ។

-កំហុសនៃអង្គហេតុ ដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។

-កំហុសនៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

31. តាមទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូល ជាដំបូងត្រូវពិនិត្យលើបញ្ហាថាតើ អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ដោយយល់ ឃើញថា ខ្លួនមិនមានយុត្តាធិការក្នុងការដាក់ការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ ឬលក្ខខណ្ឌចាប់បង្ខំលើការដោះលែង (ទឡ្ហីករណ៍ទីមួយ និងទីពីរនៃបណ្តឹងសាទុក្ខ)។ ជាការយល់ស្រប អង្គជំនុំជម្រះត្រូវពិនិត្យលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដោយបាន បង្គាប់ឱ្យដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ ជំនួសឱ្យការដាក់លក្ខខណ្ឌនៃការត្រួតពិនិត្យតាម ផ្លូវតុលាការ និងមានកំហុសអង្គហេតុ ឬក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ ក្នុងការយល់ឃើញថា លក្ខខណ្ឌនៃការត្រួពិនិត្យតាមផ្លូវតុលាការ មិនអាចអនុវត្តបាន ឬមិនមានភាពជាក់ស្តែងក្នុងការអនុវត្ត (ទឡ្ហីករណ៍ទីបី និងទីបួននៃបណ្តឹងសាទុក្ខ)។

**២. ទឡ្ហីករណ៍ទីមួយ និងទីពីរ នៃបណ្តឹងសាទុក្ខ៖ ថាតើអង្គជំនុំជម្រះសាលាដំបូងកំហុសអង្គច្បាប់ដោយមិនបានអនុវត្ត បដិសេធចោល និងមិនបានពិចារណាលើមូលដ្ឋានផ្អែកច្បាប់ ក្នុងការបង្គាប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ឬដាក់លក្ខខណ្ឌចាប់បង្ខំលើកការដោះលែងជនជាប់ចោទនោះទេ**

32. អង្គជំនុំជម្រះតុលាការកំពូលសូមរំលឹកថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC ក្នុងរឿងក្តី *Lubanga* ក្នុងការសន្និដ្ឋានថា ការផ្អាកកិច្ចដំណើរការនីតិវិធី"ដោយគ្មានពេលកំណត់" ដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានបង្គាប់ធ្វើឡើងនោះ រួមមាន "ភាពគ្មានលទ្ធភាពអនុវត្ត" ឬ "ការផ្អាកយុត្តាធិការលើជនជាប់ចោទ"[74] ។ នៅក្នុងការឈានទៅធ្វើការសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះសាលាដំបូងទំនងជាបានអនុវត្តតាមភាពខុស

[74] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨, ៣២ ដល់ ៣៣, យោងលើសេចក្តីសម្រេច*លើរឿងក្តី Lubanga* កថាខណ្ឌ ៣៦។

ប្លែកដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេច *Lubanga* រវាងការផ្អាកកិច្ចដំណើរការនីតិវិធីដែលអាចកែប្រែបាន និងដោយមានលក្ខខណ្ឌ និងការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ និងដែលមិនអាចកែប្រែបាន[75]។ អង្គជំនុំជម្រះសាលាដំបូងទំនងជាពិចារណាលើបញ្ហានៅចំពោះមុខខ្លួន ដោយផ្អែកតាមប្រភេទទីពីរ ពោលគឺ ស្ថានភាពនៃការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ និងមិនអាចកែប្រែបាន ដោយបានសម្រេចថា ដោយសារគ្មានការព្យាបាលផ្នែកវេជ្ជសាស្ត្រណាមួយ ដែលអាចមានលទ្ធភាពធ្វើឱ្យស្ថានភាពរបស់ជនជាប់ចោទប្រសើរឡើងវិញបានទេនោះ ឬដោយសារពុំមានលទ្ធភាពណាមួយដែលអាចឱ្យជនជាប់ចោទធូរស្បើយដោយឯកឯងពុំចាំបាច់ព្យាបាល ហេតុដូច្នេះ ការផ្អាកកិច្ចដំណើរការនីតិវិធីត្រូវបន្តដោយគ្មានពេលកំណត់។ ត្រង់ចំណុចនេះហើយដែលអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយថា ខ្លួនគ្មានលទ្ធភាពអនុវត្តយុត្តាធិការលើជនជាប់ចោទបាន ឡើយ ក្នុងអំឡុងពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធីនេះ[76]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលា ដំបូងបានលើកឡើងពីការពុំមាន "មូលដ្ឋានគតិយុត្តិច្បាស់លាស់" ដែលគេយល់ថាជាការអនុញ្ញាតតាមផ្លូវច្បាប់ជាក់លាក់ដែលជាការកំណត់របស់បទដ្ឋានអន្តរជាតិ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងឃុំខ្លួន ឬដាក់វិធានការដោយបង្ខំផ្សេងទៀត នៅពេលដោះលែង[77]។

33. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញការលើកឡើងរួមគ្នានៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្កើតជាបញ្ហាមួយ ដែលការលើកឡើងនោះគឺថា ខ្លួនគ្មានយុត្តាធិការ ដោយផ្អែកតាមការបកស្រាយសេចក្តីសម្រេច *Lubanga* និងទឡ្ហីករណ៍ដែលថា ខ្លួនគ្មាន "មូលដ្ឋានច្បាស់លាស់" (ពោលគឺ ការអនុញ្ញាតតាមផ្លូវច្បាប់ជាក់លាក់) សម្រាប់ការអនុវត្តវិធានការដោយបង្ខំ។ បញ្ហានៅកន្លែងនេះមានពីរ៖ ទីមួយគឺ ភាពមិនប្រាកដប្រជានៃវិធីសាស្ត្រ ចំពោះបញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសយកមកអនុវត្ត ដោយអនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក[78] ដោយយកទស្សនទាននៃការផ្អាកជាអចិន្ត្រៃយ៍ដូចបានលើកឡើងនៅក្នុងសេចក្តីសម្រេច

---

[75] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៨ ដោយបានដកស្រង់*រឿងក្តី* *Lubanga* កថាខណ្ឌ ៣៦។

[76] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨ ន័យជារួម។

[77] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២១-២៣, ៣០, ៣២, ៣៣។

[78] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់ទោសតាមច្បាប់កម្ពុជា នូវ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀងនៃ អ.វ.ត.ក") មាត្រា ១២ ("នីតិវិធីត្រូវតែស្របជាមួយច្បាប់កម្ពុជា។ ក្នុងករណីដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបញ្ហាជាក់លាក់ណាមួយ ឬ ក្នុងករណីដែលមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តវិធានពាក់ព័ន្ធនៃច្បាប់កម្ពុជា ឬ ក្នុងករណីដែលមានបញ្ហាទាក់ទងនឹងភាព

*Lubanga* ឬក៏ ថាតើ អង្គជំនុំជម្រះសាលាដំបូងផ្អែកលើមូលដ្ឋាននៃច្បាប់កម្ពុជា ហើយបកស្រាយបទប្បញ្ញត្តិជាធរមាន ដោយពិចារណាលើបទដ្ឋានអន្តរជាតិ ដែរ ឬយ៉ាងណា។ ទីពីរមានបញ្ហាកើតឡើងទៅលើការទំនាក់ទំនងដែលជាបទដ្ឋាន រវាងការសម្រេចផ្សេងៗរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅពេលជឿដោយខ្លួនឯងថា ខ្លួនគ្មានយុត្តាធិការលើជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ស្វែងរកមូលដ្ឋានណាមួយសម្រាប់យកមកអនុវត្តវិធានការនានាឡើយ មិនថាវិធានការនោះជាវិធានការដោយបង្ខំ ឬក៏មិនមែននោះទេ ដោយហេតុថានៅពេលខ្លួនគ្មានយុត្តាធិការ ធ្វើឱ្យបញ្ហានៃការដាក់វិធានការនេះក្លាយជាអាសាបង់។ ជាការពិត ការដែលមានបទប្បញ្ញត្តិគតិយុត្តិចែងអំពីការអនុវត្តវិធានការនៅក្នុងបរិបទដែលជនជាប់ ចោទគ្មានសម្បទាក្នុងការចូលរួមសវនាការ នឹងបង្ហាញឱ្យឃើញផ្ទុយពីនេះ ពោលគឺ ជាមូលដ្ឋាន តុលាការមានយុត្តាធិការលើជនជាប់ចោទ។ ការដែលគ្មានមូលដ្ឋានផ្លូវច្បាប់សម្រាប់ដាក់វិធានការ អាចត្រូវបានលើកឡើងជា*សញ្ញាបញ្ជាក់ (indicium)* ថាគ្មានយុត្តាធិការ ដែលតុលាការកំពូលនឹងលើកឡើងចំណុចនេះ នៅផ្នែកខាងក្រោមនៃសេចក្តីសម្រេច ប៉ុន្តែចំណុចនេះ មិនត្រូវចាត់ទុកថាជាទឡ្ហីករណ៍តែមួយនោះទេ។

34. ម្យ៉ាងវិញទៀត សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពគ្មានយុត្តាធិការ ដែលជាលទ្ធផលនៃការយល់ឃើញរបស់ខ្លួនដែលថា ជនជាប់ចោទគ្មានសម្បទាជាអចិន្ត្រៃយ៍នោះ មានលក្ខណៈផ្ទុយគ្នាទៅនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួនដទៃទៀត ដែលបង្ហាញតាមការសន្មតថា លទ្ធភាពនៃការបន្តកិច្ចដំណើរការនីតិវិធី ទោះបីជាមានតិចតួចក៏ដោយ ក៏ពុំអាចបាត់ទៅទាំងស្រុងនោះដែរ។ ជាពិសេសការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា *"ការផ្អាកកិច្ចដំណើរការនីតិវិធីត្រូវបន្តរហូតដល់ពេល និងលើកលែងតែអង្គជំនុំជម្រះបង្គាប់ឱ្យចាប់ផ្តើមកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទឡើងវិញ"*[79] មានន័យថា ការផ្អាកនេះធ្វើឡើងដោយមានលក្ខខណ្ឌ និងទំនងជាលុបចោលវិញនៅក្នុងពេលអនាគត។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តវិធានការមួយចំនួន ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យកិច្ចដំណើរការនីតិវិធីនេះអាចដំណើរការឡើងវិញបាន នៅក្នុងពេលណាមួយដែលការជំនុំជម្រះលើជនជាប់ចោទទំនងជាអាចទៅរួច។ នៅក្នុងគោលបំណងនេះ ក្រោយពីបានទទួលស្គាល់ថា ការវិវឌ្ឍផ្នែកវេជ្ជសាស្ត្រនៅតែមាននៅក្នុងវិទ្យាសាស្ត្រវេជ្ជសាស្ត្រ[80] អង្គជំនុំជម្រះ

ស្របគ្នានៃវិធាននេះជាមួយនឹងបទដ្ឋានអន្តរជាតិ ការណែនាំអាចត្រូវបានស្វែងរកនៅក្នុងវិធានស្តីពីនីតិវិធីដែលមាននៅក្នុងកម្រិតអន្តរជាតិ")។

[79] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨ (សេចក្តីបញ្ជាក់បន្ថែម)។

[80] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៩។

សាលាដំបូងបានពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញរៀងរាល់ ១២ ខែ ម្តង ដើម្បីបញ្ជាក់ ថាតើមានជម្រើសព្យាបាលថ្មី ឬការព្យាបាលដោយចលនាណាមួយ ត្រូវបានរកឃើញ ដែរ ឬទេ ដែលទំនងជាអាចធ្វើឲ្យសមត្ថភាពបញ្ញាស្មារតីរបស់ជនជាប់ចោទមានភាពប្រសើរឡើង[81]។ អង្គជំនុំជម្រះសាលាដំបូងក៏បានព្យាយាមធ្វើយ៉ាងណាឲ្យជនជាប់ចោទ អាចបង្ហាញខ្លួននៅចំពោះមុខតុលាការ ដោយបានស្នើសុំឲ្យជនជាប់ចោទស្ថិតនៅក្នុងប្រទេសកម្ពុជា និងប្រាប់ពីអាសយដ្ឋានរបស់ខ្លួនឲ្យទៅតុលាការ[82]។ ចំណុចចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង"បានបញ្ជាក់"ថា បទចោទប្រឆាំងនឹងជនជាប់ចោទ ពុំត្រូវបានលុបចោលនោះទេ[83] ដោយនេះជាការតម្កល់សេចក្តីសម្រេចមុនៗរបស់ខ្លួនដែលបានលើកឡើងថា ទោះបីជាកិច្ចដំណើរការនីតិវិធីបានផ្អាកក៏ដោយក្តី ក៏កិច្ចដំណើរការនីតិវិធីនេះពុំត្រូវបានបញ្ចប់នៅឡើយ[84]។ ការប្រកាសទាំងនេះ មិនអាចមានន័យថា ជាការលុបចោលយុត្តាធិការលើជនជាប់ចោទនោះទេ។

35. ការលើកឡើងផ្ទុយគ្នានៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទំនងជាកើតឡើង ដោយសារតែការអនុវត្តក្នុងពេលដំណាលគ្នានៃសញ្ញាណខុសៗគ្នានៅក្នុងប្រព័ន្ធគតិយុត្តិ ដែលនាំឲ្យ មានការយល់ច្រឡំលើផលវិបាកផ្នែកគតិយុត្តិនៃសេចក្តីសម្រេចរបស់ខ្លួន។ ជាដំបូង អង្គ ជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា សញ្ញាណនៃ"ការផ្អាក"កិច្ចដំណើរការនីតិវិធី ដែលចេញពីប្រព័ន្ធច្បាប់អង់គ្លូសាក់សុង គឺងាយនឹងទទួលយកពីមូលដ្ឋានផ្សេងៗ ដែលអាស្រ័យលើរបបគតិយុត្តិដែលខ្លួនអនុវត្តនោះ។ ដូច្នេះ នៅក្នុងបរិបទនៃការពិភាក្សានេះ ពាក្យនេះមានបង្កប់ន័យពិសេស[85]។ ការកំណត់លើអត្ថន័យពិតប្រាកដ និងផលវិបាកផ្នែកគតិយុត្តិជាក់លាក់ ទាមទារឲ្យមានការពិចារណាជាក់លាក់លើលក្ខណៈនៃប្រព័ន្ធគតិយុត្តិជាធរមាន។ ហេតុដូច្នេះ យុត្តិសាស្ត្រពីយុត្តាធិការផ្សេងៗ ពុំអាចយកមកអនុវត្តដោយស្វ័យប្រវត្តិ ដោយពុំពិនិត្យលើបរិបទនៃប្រព័ន្ធគតិយុត្តិ នោះទេ។

[81] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៩ និងផ្នែកសេចក្តីសម្រេច។

[82] សេចក្តីសម្រេចដែលរងការជំទាស់ ផ្នែកសេចក្តីសម្រេច។

[83] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤០។

[84] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសមត្ថភាព កថាខណ្ឌ ៦៤។

[85] សេចក្តីសម្រេចលើកទីមួយនៃបណ្តឹងឧទ្ធរណ៍ស្តីពីសមត្ថភាព កថាខណ្ឌ ១៨ ដោយយោងលើវចនានុក្រម the Black Law Dictionary បោះពុម្ពលើកទី ៩ ឆ្នាំ២០០៩ ទំព័រ ១៥៤៨ ពាក្យ "ការផ្អាក" (""ការផ្អាក" សំដៅលើ "ការពន្យារ ឬ ការបញ្ឈប់កិច្ចដំណើរការនីតិវិធី សាលក្រម/សាលដីកា ឬ កិច្ចដំណើរការនីតិវិធី ឬអ្វីដូចៗគ្នានេះ" និងសំដៅលើ"ការបង្គាប់ឲ្យបង្អង់កិច្ចដំណើរការនីតិវិធីតុលាការទាំងស្រុង ឬ មួយផ្នែក ឬ សាលក្រម/សាលដីកាដែលជាលទ្ធផលកើតចេញពីកិច្ចដំណើរការនីតិវិធីនោះ"")។

36. បើទោះជាមានភាពខុសគ្នានៅក្នុងចំណោមបទដ្ឋានគតិយុត្តិក្នុងស្រុក គេអាចនិយាយជាទូទៅថា យុត្តាធិការក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ជាធម្មតា បែងចែក"ការផ្អាក" ជាពីរប្រភេទ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានបញ្ជាក់នៅក្នុងសេចក្តីសម្រេច *Lubanga* ទីមួយ វាអាចមានការផ្អាកកិច្ចដំណើរការនីតិវិធីដោយមានលក្ខខណ្ឌ និងអាចកែប្រែបាន ដែលនៅក្នុងករណីនេះ ការផ្អាកនេះដែលជាឧបសគ្គក្នុងការបន្តកិច្ចដំណើរការនីតិវិធី ទីបំផុត អាចនឹងត្រូវបំបាត់ចោល[86]។ ប្រភេទទីពីរ វាអាចមានការផ្អាកជាអចិន្ត្រៃយ៍ ឬមិនអាចកែប្រែបានជាដាច់ខាត ដែលនាំឱ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធី[87]។ ភាពខុសគ្នាសំខាន់បំផុតរវាងប្រភេទនៃការការផ្អាកកិច្ចដំណើរការនីតិវិធីទាំងពីរនេះ គឺសក្តានុពលក្នុងការលុបចោលឧបសគ្គដែលនាំដល់ការផ្អាកនីតិវិធី ហេតុនេះ មានលទ្ធភាព បើទោះជាតិចតួចក៏ដោយ ដែលថា ទីបំផុត ការផ្អាកនេះអាចនឹងលុបចោលបាន ហើយដំណើរការនីតិវិធីចាប់ផ្តើមឡើងវិញ[88]។ ទោះបីជា នៅក្នុងកាលៈទេសៈទីពីរ យុត្តាធិការលើជនជាប់ចោទ លែងមានតទៅទៀត ក៏ដោយ[89] ក៏នៅក្នុងករណីទីមួយតុលាការនៅតែមានយុត្តា ធិការដដែរ[90]។ លទ្ធភាពសម្រាប់ឱ្យតុលាការបង្គាប់ ការផ្អាក ដោយក្នុងនោះរួមទាំង ការបញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ កើតចេញពីគោលការណ៍នៃឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ដែលត្រូវបានអនុវត្តនៅក្នុង

---

[86] សេចក្តីសម្រេច *Lubanga* កថាខណ្ឌ ៣៣ កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* កថាខណ្ឌ ៨០។ ("ប្រសិនបើការជំនុំជម្រះដែលមានភាពយុត្តិធម៌លើគ្រប់ទិដ្ឋភាពទាំងអស់ អាចកើតមានដោយសារលទ្ធផលនៃកាលៈទេសៈផ្លាស់ប្តូរមែននោះ វាគ្មានហេតុផលណាមួយដែលមិនឱ្យបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម មកទទួលការកាត់ទោសបានឡើយ ដែលជាអំពើដែលមិនត្រូវមិនទទួលនូវការដាក់ទណ្ឌកម្ម ហើយអំពើនោះត្រូវតែគ្មាននិទណ្ឌភាព"។

[87] សេចក្តីសម្រេច *Lubanga* កថាខណ្ឌ ៣៣, ៣៦ និង ៣៧។ *សូមមើលផងដែរ* កថាខណ្ឌ ៨១ ("អង្គជំនុំជម្រះដែលបានផ្អាកកិច្ចដំណើរការនីតិវិធីដោយមានលក្ខខណ្ឌ ដោយក្នុងចន្លោះពេលមួយ ត្រូវពិនិត្យសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ និងកំណត់ថាតើការជំនុំជម្រះដោយយុត្តិធម៌អាចធ្វើឡើងទៅបានដែរឬទេ ជាពិសេស ដោយសារពេលវេលាដែលបានកន្លងផុតទៅនោះ ការជំនុំជម្រះដោយយុត្តិធម៌អាចទំនងពុំមានលទ្ធភាពធ្វើទៅបានជាអចិន្ត្រៃយ៍ និងដោយមិនមានអ្វីផ្លាស់ប្តូរ"។ នៅក្នុងករណីក្រោយនេះ អង្គជំនុំជម្រះអាចត្រូវកែប្រែសេចក្តីសម្រេចរបស់ខ្លួន និងផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍)។

[88] សេចក្តីសម្រេច *Lubanga* កថាខណ្ឌ ៣៣, កថាខណ្ឌ ៣៧ ("ការផ្អាកដោយមានលក្ខខណ្ឌ មិនមែនជាការសម្រេចឱ្យរួចផុតពីបទចោទ ឬការបញ្ចប់កិច្ចដំណើរការនីតិវិធីជាស្ថាពរនោះទេ ប៉ុន្តែ ការផ្អាកនេះអាចលុបចោលវិញបាននៅក្នុងកាលៈទេសៈសមស្រប (...)")។ *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥។

[89] សេចក្តីសម្រេចលើរឿងក្តី *Lubanga* កថាខណ្ឌ ៣៦។

[90] សេចក្តីសម្រេច លើរឿងក្តី *Lubanga* កថាខណ្ឌ ៣៧។

ប្រព័ន្ធយុត្តាធិការច្បាប់អង់គ្លូសាក់សុងភាគច្រើន[91]។ អនុលោមតាមគោលការណ៍នេះ រដ្ឋអាជ្ញាមានអំណាចមិនចោទប្រកាន់ ឬលុបចោលបទចោទ[92] ហើយដូចគ្នាដែរ តុលាការក៏មានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការផ្អាក ឬបញ្ចប់កិច្ចដំណើរការនីតិវិធី ដោយពុំចាំបាច់មានហេតុផលចែងជាក់លាក់នៅក្នុងច្បាប់ ប៉ុន្តែការបញ្ចប់កិច្ចដំណើរការនីតិវិធីនេះត្រូវផ្តល់យុត្តិកម្មផ្អែកលើផលប្រយោជន៍ផ្សេងទៀតនៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តី។

37. ជាទម្លាប់ យុត្តាធិការភាគច្រើននៃប្រព័ន្ធច្បាប់ស៊ីវិល បានអនុវត្តតាមគោលការណ៍នៃគតិយុត្តិកម្ម(ឬផ្ទុយពីនេះ គឺ ការចោទប្រកាន់ដែលជាលក្ខខណ្ឌតម្រូវ) ដែលអនុលោមតាមគោលការណ៍នេះ ស្ថាប័នអយ្យការពុំមានឆន្ទានុសិទ្ធិផ្អាក ឬស្នើសុំឱ្យបង្អង់បណ្តឹងអាជ្ញានោះទេ បន្ទាប់ពីខ្លួនបានផ្តួចផ្តើមបណ្តឹងអាជ្ញានេះរួចហើយនោះ[93] ហើយតុលាការដែលមានអំណាចផ្តាច់មុខលើការបញ្ចប់កិច្ចដំណើរការនីតិវិធី

---

[91] MM. Merle និង Vitu, *Traité de droit criminel*, T.II, បោះពុម្ពលើកទីបួន ប៉ារីស ឆ្នាំ ១៩៨៩ ("MM. Merle និង Vitu") កថាខណ្ឌ ២៨០។ *សូមមើលផងដែរ* ការបញ្ជាក់លើគោលការណ៍នេះនៅក្នុងបរិបទនៃប្រទេសអង់គ្លេស និងវែល ដោយអគ្គរដ្ឋអាជ្ញាលោក Hartley Showcross ដែលបានលើកឡើងនៅក្នុងឆ្នាំ ១៩៥១ ថា "[វា] ពុំធ្លាប់ជាវិធាននៅក្នុងប្រទេសនេះឡើយដែលបទល្មើសព្រហ្មទណ្ឌដែលត្រូវបានសង្ស័យ ត្រូវជាកម្មវត្ថុនៃការចោទប្រកាន់ដោយស្វ័យប្រវត្តិ ហើយខ្ញុំសង្ឃឹមថាវាក៏នឹងមិនក្លាយជាវិធានដូច្នេះនាពេលអនាគតផងដែរ"។ House of Commons Debates លេខ ៤៨៣ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៥១ ដកស្រង់ដោយ M. Bohlander, *គោលការណ៍នៃនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ (ការសិក្សានៅក្នុងនីតិប្រៀបធៀប និងនីតិអន្តរជាតិ)* Hart Publishing Oxford និង Portland ឆ្នាំ ២០១២ ("Bohlander") ទំព័រ ២៦។

[92] MM. Merle និង Vitu, កថាខណ្ឌ ២៧៨-២៧៩។

[93] នៅក្នុងប្រទេសបារាំង នៅពេលយកមកអនុវត្ត ត្រូវយោងទៅលើគោលការណ៍ "le principe de légalité dans l'exercice des poursuites" (*សូមមើល* Merle និង Vitu, កថាខណ្ឌ ២៨៣)។ ប្រទេសអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលឡផ្សេងទៀត ដូចជា អាល្លឺម៉ង់ អ៊ីតាលី ក្រិច និងអេស្ប៉ាញ តាមទំនៀមទម្លាប់ គឺអនុវត្តគោលការណ៍គតិយុត្តិនិយមនៅ ដំណាក់កាលដំបូងគេ (ចាប់ពីពេលផ្តួចផ្តើមធ្វើបណ្តឹងអាជ្ញា) ដែលតម្រូវឱ្យមានការចោទប្រកាន់នៅក្នុងហេតុការណ៍នីមួយៗដែលមានការបញ្ជាក់ពីការប្រព្រឹត្តិនៃអំពើល្មើស មានធាតុផ្សំសត្យានុម័ត លើកលែងតែច្បាប់អនុញ្ញាតយ៉ាងជាក់លាក់ឱ្យលុបចោលបទចោទព្រហ្មទណ្ឌបែបនេះ (*សូមមើល* MM. Merle និង Vitu, បោះពុម្ពលើកទីបួន ប៉ារីស ឆ្នាំ១៩៨៩ កថាខណ្ឌ ២៨០)។ *សូមមើល* ឧទាហរណ៍ កថាខណ្ឌ ១៥២(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ ដែលចែងថា "លើកលែងតែច្បាប់បានចែងផ្សេងពីនេះ ស្ថាប័នអយ្យការត្រូវមានកាតព្វកិច្ចធ្វើបណ្តឹងអាជ្ញានៅក្នុងករណីបទល្មើសព្រហ្មទណ្ឌទាំងអស់ដែលអាចចោទប្រកាន់ ដោយសារតែមាន អង្គហេតុគ្រប់គ្រាន់"។ នៅក្នុងប្រទេសអ៊ីតាលី គោល ការណ៍នេះត្រូវបានបង្កើតឡើងនៅក្នុងរដ្ឋធម្មនុញ្ញ។ មាត្រា ១១២ នៃរដ្ឋធម្មនុញ្ញអ៊ីតាលីចែងថា "រដ្ឋអាជ្ញា មាន កាតព្វកិច្ចធ្វើបណ្តឹងអាជ្ញា"។ ករណីនេះក៏ដូចនៅក្នុងប្រទេស ប៉ូឡូញ (មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ក្នុងប្រទេសរុស្ស៊ី (កថាខណ្ឌ ២១(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌ) និងនៅប្រទេស ប្រេស៊ីល (មាត្រា ២៤ និង ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

អាចធ្វើទៅបានផ្អែកតាមហេតុផលដែលមានចែងជាក់លាក់នៅក្នុងច្បាប់[94]។ ការអនុវត្តគោលការណ៍គតិយុត្តិកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ អាចមានភាពចំរូងចំរាស់ជាពិសេសទាក់ទងទៅនឹងសេចក្តីសម្រេច ថាតើ ត្រូវធ្វើការចោទប្រកាន់ ដែរ ឬយ៉ាងណា។ ម្យ៉ាងវិញទៀត សូម្បីនៅក្នុងទ្វីបអឺរ៉ុប គោលការណ៍នេះអាចបាត់បង់ជាបណ្តើរៗ ដោយសារតែការប្រើប្រាស់លិខិតុបករណ៍ដែលមានការទាក់ទាញផ្សេងទៀត[95]។ ក៏ប៉ុន្តែ ប្រភពនៃគោលការណ៍នេះចេញពីវិធីសាស្ត្រនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងដំណាក់កាលជំនុំជម្រះ ក្នុងការដោះស្រាយឧបសគ្គចំពោះការបន្តកិច្ចដំណើរការនីតិវិធី ដូចជា បញ្ហាសម្បទាក្នុងការចូលរួមសវនាការជាដើម។ ជាធម្មតា កិច្ចដំណើរការនីតិវិធីទាំងនេះត្រូវបានព្យួរ ផ្អាក ឬបង្អង់ រហូតទាល់តែមានការលុបឧបសគ្គទាំងនេះឲ្យបានរួចរាល់សិន។ លើកលែងតែមានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ "ការផ្អាក" ពុំបណ្តាលឲ្យបញ្ចប់កិច្ចដំណើរការ នីតិវិធីដោយមានប្រសិទ្ធភាពបាននោះទេ ហើយវាក៏ពុំនាំឲ្យបាត់បង់យុត្តាធិការ លើជនជាប់ចោទនោះដែរ។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា នៅក្នុងបរិបទនៃប្រព័ន្ធច្បាប់ស៊ីវិលឡូ ដោយសារថាអត្ថបទច្បាប់ដើម ជាធម្មតា ពុំមែនសរសេរជាភាសាអង់គ្លេស ពាក្យ "ផ្អាក" ជារឿយៗ ត្រូវប្រើប្រាស់ពាក្យពេចន៍មួយផ្សេងទៀត ដែលត្រូវបានកំណត់នៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ដើម្បីសំដៅលើស្ថានភាពនៃការបង្អង់បែបនេះ។

38. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ពីមុនរួចមកហើយថា ច្បាប់ដែលអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក មិនបានចែងអំពីលទ្ធភាពបញ្ចប់ដំណើរការនីតិវិធីនៅក្នុងករណីដែលរកឃើញថាជនជាប់ចោទមិនមានសម្បទាចូលរួមនៅក្នុងសវនាការនោះទេ[96]។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយត្រូវបានកម្រិតចំពោះមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ព្រហ្ម និងអាជ្ញាអស់ជំនុំ (*res judicata*)[97]។ ដូច្នេះមានន័យថា ដោយអនុត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

---

[94] Merle និង Vitu, កថាខណ្ឌ ២៧៨-២៧៩, ២៨៣។

[95] *សូមមើល*ក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ កថាខណ្ឌ ១៥៣។ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប៉ូឡូញ មាត្រា ៣៨៧ (ការចូលខ្លួនដោយស្ម័គ្រចិត្តឲ្យដាក់ទោស)។ ក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី មាត្រា ៤៤៤ (applicazione della pena su richiesta delle parti, "*pattegiamento*")។

[96] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨។

[97] *សូមមើលផងដែរ* មាត្រា ៨ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលបានផ្តល់មូលហេតុផ្សេងៗទៀតនៃការរលត់បណ្តឹងអាជ្ញា ដោយចែងថា "កាលណាច្បាប់ដោយឡែកមានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ"។

តុលាការ មិនមានអំណាចបង្គាប់ឲ្យមានការរលត់បណ្តឹងអាជ្ញាដោយមូលហេតុផ្សេងពីនេះបានទេ[98]។ ម្យ៉ាងវិញទៀត ក្រមនីតិវិធីព្រហ្មទណ្ឌចែងពីអំណាចក្នុងការ "បង្អង់" ឬ "ផ្អាក" ដំណើរការនីតិវិធីក្នុងកាលៈទេសៈជាក់លាក់មួយចំនួនដោយសារតែជាឧបសគ្គចំពោះដំណើរការនីតិវិធី ដូចជា ភាពចាំបាច់ដើម្បីសម្រេចលើបញ្ហាបន្ទាន់បង្ខំ ដែលជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការមួយផ្សេងទៀត[99] និងនៅពេលជនជាប់ចោទមិនបង្ហាញខ្លួននៅពេលសវនាការ[100]។ ផលវិបាកនៃការផ្អាកដំណើរការនីតិវិធីគឺថា នៅពេលដែលមានការផ្អាកបណ្តឹងអាជ្ញាការផ្អាកបែបនេះ ការផ្អាកនេះមិនបានរារាំងដល់ដំណើរការនីតិវិធី ដែលមានបំណងដោះស្រាយឧបសគ្គនោះទេ[101]។ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងអំពីប្រភេទគតិយុត្តិដាច់ដោយឡែកនៃ"ការផ្អាកជាអចិន្ត្រៃយ៍" ឬស្ថានភាពណាផ្សេងក្រៅពីការបញ្ចប់ដំណើរការនីតិវិធីនោះទេ នៅក្នុងករណីដែលយុត្តាធិការរបស់តុលាការដែលមានសមត្ថកិច្ចទៅលើរឿងក្តីនេះអាចនឹងបញ្ចប់។ ជម្រើសផ្លូវច្បាប់ជាច្រើន ដែលបានពិចារណា ដោយមានលក្ខណៈជាប្រព័ន្ធ និងស៊ីសង្វាក់គ្នានោះថា ភាពខ្វះចន្លោះនៃច្បាប់ចំពោះឧបសគ្គដែលកើតមានលើកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅក្នុងច្បាប់ប្រទេសកម្ពុជា ត្រូវបានដោះស្រាយទៅតាមភាពស្រដៀងគ្នា ដោយបានធ្វើការពង្រីកករណីនៃ"ការផ្អាក" ជាជាងការពង្រីកករណីនៃការបញ្ចប់ដំណើរការនីតិវិធី។ ដូច្នេះ ជាឧទាហរណ៍ ការបែងចែករវាងការផ្អាកដំណើរការនីតិវិធីជាពីរប្រភេទ ដែលអង្គជំនុំជម្រះតុលាការកំពូលនៃ ICC បានយោងទៅនោះ *ដែលមានន័យថា*ការផ្អាកមិនអចិន្ត្រៃយ៍ និងដោយមានលក្ខខណ្ឌ *ទល់នឹង* ការផ្អាកជាអចិន្ត្រៃយ៍ និង

---

[98] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ" (តម្រូវឱ្យមានការបញ្ជាក់បន្ថែម), ដោយធ្វើការបញ្ជាក់ថា បញ្ជីនេះមានលក្ខណៈលម្អិត។ ជាងនេះទៀត ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលមានខ្លឹមសារស្រដៀងគ្នាទៅនឹងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានកំណត់ជាក់លាក់នូវកាលៈទេសៈមួយចំនួនដែលចៅក្រមស៊ើបអង្កេតអាចច្រានចោលសំណុំរឿងមួយតាមរយៈការចេញដីកាលើកលែងការចោទប្រកាន់ ហើយអង្គជំនុំជម្រះសាលាដំបូងអាចចេញសាលក្រមសម្រេចឲ្យរួចខ្លួន (មាត្រា ២៤៧ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា)។

[99] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៤៣ និង ៣៤៥។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សំគាល់នៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ជើងទំព័រ ៥៩, ពាក្យដើមដំបូងជាភាសាខ្មែរត្រូវបានបកប្រែដោយមិនត្រឹមត្រូវទៅជាពាក្យអង់គ្លេសចំនួនពីរ គឺ "ព្យួរ" និង "ផ្អាក" នៅក្នុងបញ្ញត្តិទាំងពីរនេះ។ ពាក្យនេះនៅក្នុងភាសាខ្មែរមានន័យដូចគ្នានៅក្នុងបញ្ញត្តិទាំងពីរ ហើយមានអត្ថន័យស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងពាក្យជាភាសាអង់គ្លេស"suspend" មានន័យថា "ព្យួរ/ពន្យារពេល" ឬ "stay" មានន័យថា "បញ្ឈប់"។ ភាសាដើមរបស់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលជាភាសាខ្មែរបានចែកយ៉ាងច្បាស់ពាក្យ "ព្យួរ' ឬ "បញ្ឈប់' ទៅនឹងពាក្យ "adjournment" មានន័យថា "ពន្យារពេល ឬលើកទៅពេលក្រោយ" ដែលមានន័យថាការផ្អាកសកម្មភាពមួយរយៈពេលខ្លី ក្នុងខណៈពេលមានការបន្តកិច្ចដំណើរការនីតិវិធី។ *សូមមើល* មាត្រា ៣៤០។

[100] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣១០។

[101] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨ ជើងទំព័រ ៦៤។

មិនអាចកែប្រែបាន ហើយផលវិបាករបស់វាដែលបានយកមកពិភាក្សានៅក្នុងសេចក្តីសម្រេចអំពីករណី *Lubanga*ដើម្បីឱ្យមានការជាប់ទាក់ទងដល់ អ.វ.ត.ក ត្រូវភ្ជាប់ទៅនឹងនីតិវិធីព្រហ្មទណ្ឌកម្ពុជា រវាងការផ្អាកដែលត្រូវបានគេយល់ថាជាការព្យួរ នីតិវិធីក្នុងអំឡុងពេលមានឧបសគ្គ *ទល់នឹង* ការបញ្ចប់នីតិវិធីនៅក្នុងកាលៈទេសៈ ដែលកំណត់ដោយច្បាប់។

39. នៅក្នុងបរិបទគតិយុត្តិនេះ "ការផ្អាកនីតិវិធីដោយគ្មានពេលកំណត់" ដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង អាចត្រូវបានគេយល់ថា ដូចដែលបានកំណត់ពីមុនដោយអង្គជំនុំជម្រះតុលាការកំពូលថាមានអនុភាពផ្អាកនីតិវិធីប្រឆាំងនឹងជនជាប់ចោទ រហូតដល់ឧបសគ្គនោះត្រូវបានដោះស្រាយ ដើម្បីឱ្យដំណើរការនីតិវិធីអាចបន្តឡើងវិញបាន ឬដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយសារមូលហេតុដែលបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ (មានន័យថា នៅពេលស្លាប់តែម្តង)[102]។

40. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចកាលពីមុនរួមមកហើយថា តុលាការរក្សាយុត្តាធិការរបស់ខ្លួនដើម្បីគោលបំណងមួយចំនួន រួមទាំងការដាក់ការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្នុងអំឡុងពេលដែលដំណើរការនីតិវិធីកំពុងតែផ្អាក[103] រួមទាំងនៅក្នុងដំណាក់កាលជំនុំជម្រះ[104] ដូចជានៅក្នុងករណីនាពេលបច្ចុប្បន្នស្រាប់។ ក្នុងពេលនេះ សេចក្តីសម្រេចដែលរងការជំទាស់បានចោទ ថាតើសេចក្តីសន្និដ្ឋានទាំងនេះ មានសុពលភាព ដែរ ឬទេ នៅក្នុងករណី ដែល ការផ្អាកដំណើរការនីតិវិធី ទំនងជាបន្តដោយមិនមានពេលច្បាស់លាស់ ដោយសារតែជនជាប់ចោទមិនមានសម្បទាជាអចិន្ត្រៃយ៍។ បញ្ហាថាតើ ត្រូវដោះស្រាយជាមួយជនជាប់ចោទតាមរបៀបណា ដែលខ្លួនមិនទំនងជាប្រសើរឡើងវិញដើម្បីចូលរួមសវនាការ គឺ ពិតណាស់ មានលក្ខណៈស្មុគស្មាញ។ បញ្ហានេះបង្ករឱ្យមានភាពតានតឹងរវាងសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ (ឧទាហរណ៍ ការសន្មតទុកជាមុនថាគ្មាន និងត្រូវជំនុំជម្រះក្នុងពេលពេលសមស្រប ក៏ដូចជា សិទ្ធិទទួលបានសេរីភាព

[102] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨។

[103] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥ ("ការមិនមានសម្បទា ឬឧបសគ្គធ្ងន់ធ្ងរដទៃទៀតដែលរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី មិនធ្វើឱ្យតុលាការមិនអាចយកវិធានការដទៃទៀតមកអនុវត្តបានឡើយ (...) ដែលអនុវត្តឡើងក្នុងគោលបំណងធានាឱ្យជនជាប់ចោទមានវត្តមាននៅពេលជំនុំជម្រះនោះ")។ សូមមើលផងដែរ កថាខណ្ឌ ២៥ (ដែលលើកឡើងថា ៖ "ដូចដែលបានបង្ហាញនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជានៅក្នុងតុលាការមិនអចិន្ត្រៃយ៍នានាដែរ ការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ"មិនមែនជាលក្ខខណ្ឌតម្រូវ" ឡើយក្នុងបរិបទនៃការផ្អាកដំណើរការនីតិវិធីដែលអាចកែប្រែបាន។ តុលាការជាតិជាច្រើនបានអនុវត្តបែបនេះ ហើយកថាខណ្ឌ ៣៨ (លើកឡើងថា "វិធានការរឹតត្បិតនានា (...) នៅមានសុពលភាពនៅក្នុងពេលផ្អាកនេះ")។

[104] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទី១ កថាខណ្ឌ ៤៥ ដល់ ៤៦។

និងសិទ្ធិឯកជនរបស់បុគ្គល) និងដើម្បីជាប្រយោជន៍យុត្តិធម៌ ឯម្យ៉ាងវិញទៀត (ឧទាហរណ៍ ក្នុងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ) រួមទាំង ផលប្រយោជន៍របស់ជនរងគ្រោះក្នុងការទទួលបាននូវការពិត និងក្នុងការទាមទារសំណងរដ្ឋប្បវេណី[105]។ ក្នុងបរិបទនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិនិត្យ ថាតើដំណោះស្រាយ ដែលបានទាញចេញពីច្បាប់កម្ពុជា និងបានសំអាងក្នុងការរក្សាយុត្តាធិការលើជនជាប់ចោទនោះ មានវិសមតិភាពជាមួយនឹងសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ដែរ ឬយ៉ាងណា និង/ឬ ថាតើបទដ្ឋានអន្តរជាតិ ឬគោលការណ៍ទូទៅរបស់ច្បាប់ នឹងតម្រូវឱ្យមានការបញ្ចប់ដំណើរការនីតិវិធី ឬការឆ្លើយតបទៅតាមកាលៈទេសពិសេសមួយផ្សេងទៀត (*sui generis* response) ដែរ ឬយ៉ាងណា ។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូល បានធ្វើការពិនិត្យលើវិធាន និងការអនុវត្តដែលមាននៅក្នុងកម្រិតអន្តរជាតិ ក៏ដូចជា ការអនុវត្តនៅក្នុងស្រុកផងដែរ។ ដូចដែលបានពិភាក្សានៅខាងក្រោម ការពិនិត្យនេះ បង្ហាញថា ក្រុមអ្នកធ្វើច្បាប់ និងតុលាការបានខិតខំស្វែងរកដំណោះស្រាយជាក់ស្តែង ក្នុងការដោះស្រាយជាមួយជនជាប់ចោទដែលពុំមានសម្បទាខាងស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ជាពិសេស នៅពេល ដែលលទ្ធភាពនៃការជំនុំជម្រះមានលក្ខណៈតិចតួចនោះហើយ ថា វិធីសាស្ត្រផ្សេងៗ ត្រូវបានបង្កើត ឡើង ផងដែរ។ ខាងលើនេះអាចត្រូវបានបញ្ចូលជាបីប្រភេទធំៗគឺ ១) ផ្អាកកិច្ចដំណើរការនីតិវិធី តែមិនបញ្ចប់ ដោយមានជម្រើសប្រើប្រាស់វិធានការក្នុងគោលបំណងជួយសម្រួលដល់ការ បន្តកិច្ចដំណើរការនីតិវិធី។ ២)ត្រូវបន្តដល់ចប់កិច្ចដំណើរការនីតិវិធីដោយសម្រេចថាតើ ជនជាប់ចោទ បានប្រព្រឹត្តិអំពើដែលត្រូវចោទប្រកាន់ ដែរ ឬយ៉ាងណា ដោយមានជម្រើសក្នុងការដាក់វិធានការជាច្រើន ក្នុងគោលបំណងការពារជនជាប់ចោទ និងសាធារណជន។ ៣) បញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងដោះស្រាយជាមួយបញ្ហាជាប់ពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិស្តីអំពីបញ្ហាស្មារតី ឬ បញ្ហាប្រហាក់ប្រហែលគ្នានេះ។

***ដំណោះស្រាយទីមួយ: ផ្អាកកិច្ចដំណើរការនីតិវិធី និងបន្តប្រើប្រាស់យុត្តាធិការ***

41. យុត្តាធិការក្នុងស្រុកមួយចំនួន ដូចជា នៅប្រទេសដែលមានប្រព័ន្ធច្បាប់ស៊ីវិល ដូចជា ប្រទេសអាល្លឺម៉ង់[106] អ៊ីតាលី[107] ប្រទេសប៉ូឡូញ[108] រុស្សី[109] ហូឡង់[110] ប្រទេសអាលបានី[111]

---

[105] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខ កថាខណ្ឌ ២៨។

[106] ក្នុងច្បាប់អាល្លឺម៉ង់ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ ចែងច្បាស់ថា កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទដែលគ្មានសម្បទា មិនត្រូវបានបញ្ចប់ឡើយ ប៉ុន្តែត្រូវផ្អាក និងថា តុលាការបន្តអនុវត្តយុត្តាធិការលើជនជាប់ចោទ។ *សូមមើល* ផ្នែក ៧១(១)នៃក្រមព្រហ្មទណ្ឌ (ចែងថា ("ការបកប្រែដោយសាស្ត្រាចារ្យ Michael Bohlander ដែលបានបោះពុម្ពផ្សាយ ដោយក្រសួងយុត្តិធម៌សហព័ន្ធ") តុលាការអាចបង្គាប់ឱ្យបង្កើតមន្ទីរពេទ្យផ្នែកស្មារតីឯកកជាមួយ ឬបង្គាប់នូវការដោយឃុំខ្លួន

មួយកន្លែង ប្រសិនបើកិច្ចដំណើរការនីតិវិធី មិនអាចអនុវត្តបាន ដោយសារ ជនជាប់ចោទក្លាយជាវិកលចរិត ឬគ្មានសម្បទាចូលរួមសវនាការ")។ ផ្នែក៨១ ច កថាខណ្ឌ ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (ដែលអនុញ្ញាតឱ្យតុលាការបង្គាប់ឱ្យប្រមូល និងវិភាគលើ DNA របស់ជនជាប់ចោទ ក្នុងករណីដែលជនជាប់ចោទ ("បកប្រែដោយ Brain Duffett និង Monika Ebinger បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌សហព័ន្ធ មិនត្រូវបានផ្តន្ទាទោសដោយគ្រាន់តែលើមូលដ្ឋានថា (...) ជនជាប់ចោទគ្មានសម្បទាចូលរួមសវនាការដោយសារវិកលចរិត")។ ផ្នែក ៧៨គ)(១១)នៃក្រមនីតិវិធីព្រហ្មទណ្ឌ (ដែលចែងថា អាជ្ញាយុកាលត្រូវបានរំខានដោយ "ការបញ្ឈប់កិច្ចដំណើរការនីតិវិធីបណ្តោះអាសន្ន ដោយសារភាពគ្មានសម្បទាចូលរួមសវនាការរបស់ជនជាប់ចោទ និងដីការបស់ចៅក្រម ឬអយ្យការ ចេញក្រោយពេលបញ្ឈប់កិច្ចដំណើរការនីតិវិធីនេះ ក្នុងគោលបំណងដើម្បីវិនិត្យមើលឡើងវិញ នូវសម្បទារបស់ជនជាប់ចោទដើម្បីចូលរួមសវនាការ")។

[107] ក្នុងប្រទេសអ៊ីតាលី, កិច្ចដំណើរការនីតិវិធីត្រូវបានបង្អង់ បន្ទាប់ពីរកឃើញការពុំមានសម្បទាក្នុងការចូលរួមសវនាការ និងរហូតដល់ជនជាប់ចោទត្រូវបានលើកលែងការចោទប្រកាន់ ឬដោះលែងឱ្យមានសេរីភាព។ ការវាយតម្លៃសុខភាពត្រូវបានធ្វើឡើងនៅរៀងរាល់ ៦ ខែម្តង ហើយលុបចោលការបង្អង់នេះវិញ បន្ទាប់ពីជនជាប់ចោទមានសម្បទាឡើងវិញ។ លក្ខខណ្ឌនានាអាចត្រូវបានដាក់ចេញចំពោះការដោះលែងជនជាប់ចោទ ក្នុងរយៈពេលកំណត់មួយ នៅពេលចាំបាច់ ដើម្បីបញ្ចៀសហានិភ័យនៃការរត់គេចខ្លួន ការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗទៀត ឬការធ្វើឱ្យខូចខាតដល់ភស្តុតាង។ ប្រសិនបើជនជាប់ចោទត្រូវការការព្យាបាលផ្នែកចិត្តសាស្ត្រ គេអាចបង្គាប់ឱ្យមានការព្យាបាល ដោយអនុលោមតាមលក្ខន្តិកៈស្តីពីសុខភាពបញ្ញាស្មារតី (ក្រមនីតិវិធីព្រហ្មទណ្ឌអ៊ីតាលី មាត្រា ៧១ ៧២ ៧៣(១) និង ២៧៤)។

[108] មាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ូឡូញ (ចែងថា, ប្រសិនបើជនជាប់ចោទមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដោយសារបញ្ហាបញ្ញាស្មារតី ឬជំងឺធ្ងន់ធ្ងរផ្សេងៗទៀតនោះ កិច្ចដំណើរការនីតិវិធីត្រូវតែបង្អង់ ក្នុងរយៈពេលដែលមានឧបសគ្គនេះ។ យោងតាម(មាត្រា ២៥៥) ការផ្អាកនៃកិច្ចដំណើរការនីតិវិធី មិនបានលុបចោលនូវការអនុវត្តវិធានការបណ្តោះអាសន្ន ដូចជា ការដាក់ប្រាក់ធានា ដើម្បីធានាថា ជនជាប់ចោទបង្ហាញខ្លួននៅពេលសវនាការ។

[109] ក្នុងប្រទេសរុស្ស៊ី មាត្រា ២៣៨(១)(២) និង មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងច្បាស់ថា នៅដំណាក់កាលជំនុំជម្រះ កិច្ចដំណើរការនីតិ វិធី ត្រូវផ្អាក ដោយសារ ("(បកប្រែដោយ Legislationonline ) ជនជាប់ចោទ មានជំងឺធ្ងន់ធ្ងរ ដែលអាចបញ្ជាក់ដោយសន្និដ្ឋានតាមវិជ្ជសាស្ត្របាន")។ គ្មានសម្បទាចូលរួមសវនាការ មិនមែនជាករណីនៃការបញ្ចប់បណ្តឹងអាជ្ញា ដែលត្រូវបានធ្វើការរៀបរាប់យ៉ាងច្បាស់លាស់ក្នុងក្រម (*សូមមើល* មាត្រា ២៣៩ និង ២៤ ដល់ ២៨ និង ២១២)។ តុលាការបន្តអនុវត្តយុត្តាធិការលើជនជាប់ចោទ (*សូមមើល* មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ដែលចែងពីលទ្ធភាពដាក់វិធានការដោយបង្ខំតាមលក្ខណៈវិជ្ជសាស្ត្រ រួមមានការបញ្ជូនទៅមន្ទីរ ដែលជនជាប់ចោទ "មានបញ្ហាស្មារតី" បន្ទាប់ពីប្រព្រឹត្តបទល្មើសដែល "មិនអាចមានលទ្ធភាពអនុវត្ត ទោសបាន" និងជនជាប់ចោទបង្កគ្រោះថ្នាក់ដល់ខ្លួនឯងផ្ទាល់ ឬអ្នកដទៃ។

[110] មាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេស Dutch ចែងថា ការចោទប្រកាន់នឹងត្រូវផ្អាក់ នៅពេលដែលជននោះ មិនមានលទ្ធភាពយល់ដឹងអំពីវិសាលភាព នៃការចោទប្រកាន់ ដោយសារកង្វះការរីកចំរើន ឬ បញ្ហាស្មារតី។

[111] នៅក្នុងប្រទេសអាល់បានី, កិច្ចដំណើរការនីតិវិធីត្រូវបានបង្អង់, មានការតែងតាំងអាណាព្យាបាល ហើយតុលាការអាចបង្គាប់ឱ្យមានការសម្រាកព្យាបាលបណ្តោះអាសន្ននៅកន្លែងព្យាបាលផ្នែកចិត្តសាស្ត្រ។ សេចក្តីសម្រេចលើការបង្អង់នីតិវិធីនេះ ត្រូវបានទុកជាមោឃៈ នៅពេលដែលលទ្ធផលបង្ហាញថា ស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ អនុញ្ញាតឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយការយល់ដឹង ឬនៅពេលណាជនជាប់ចោទត្រូវបានរកឃើញថាជាជនគ្មានទោស ឬក៏សំណុំរឿងនេះត្រូវបានបញ្ចប់" (ក្រមនីតិវិធីព្រហ្មទណ្ឌអាល់បានី, ផ្នែក ៤៤(២) និង ៤៦(១))។

ប្រទេសបូសនី[112] និងប្រទេសអាហ្ស៊ែងទីណា[113] ប៉ុន្តែ ក៏រួមបញ្ចូលប្រទេសដទៃទៀត ដូចជាប្រទេសសិង្ហាបូរី[114] ប្រទេសឥណ្ឌា[115] ប្រទេសបូសហ្វាន់ណា[116] ប្រទេសអ៊ីស្រាអែល[117] និងប្រទេស

---

[112] នៅក្នុងប្រទេសបូស្នី, កិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ហើយជនជាប់ចោទនឹងត្រូវបានបញ្ជូនទៅ "អង្គភាពទទួលខុសត្រូវលើបញ្ហាថែទាំសង្គម"។ កិច្ចដំណើរការនីតិវិធីត្រូវតែ "បន្ត" ប្រសិនបើជនជាប់ចោទ មានសម្បទាវិញ ហើយបទចោទផ្សេងៗនឹងត្រូវបានបដិសេធចោល ប្រសិនបើឧក្រិដ្ឋកម្មបានផុតអាជ្ញាយុកាល (ក្រមនីតិវិធីព្រហ្មទណ្ឌបូស្នី និងហ្សេហ្គោវីណា, មាត្រា ៣៨៨)។

[113] នៅក្នុងប្រទេសអាហ្សង់ទីន ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី ប្រសិនជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ តុលាការនឹងផ្អាកសំណុំរឿង។ ការផ្អាក់នៃកិច្ចដំណើរការនីតិវិធីនេះ នឹងបញ្ឈប់កិច្ចស៊ើបសួរ/ការចេញសាលក្រមចាប់ពីពេលចេញដីកា។ (ក្រមនីតិវិធីព្រហ្មទណ្ឌរបស់អាហ្សង់ទីន ដែលបានធ្វើវិសោធនកម្ម ឆ្នាំ ២០១១ មាត្រា ៧៧)។

[114] នៅក្នុងប្រទេសសិង្ហបុរី, បន្ទាប់ពីធ្វើការអង្កេត និងធ្វើការព្យាបាលនៅក្នុងវិទ្យាស្ថានផ្នែកចិត្តសាស្ត្រអស់រយៈពេលបីខែរួចមក ប្រសិនបើមានការព្យាបាននោះ កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទដែលពុំមានសម្បទាចូលរួមក្នុងសវនាការ ត្រូវបានផ្អាក ដោយមានលទ្ធភាពក្នុងការបន្តកិច្ចដំណើរការនីតិវិធីក្នុងពេលណាមួយនោះ។ ជនជាប់ចោទអាចត្រូវបានដោះលែង ដោយដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ប្រសិនបើ"បទល្មើសអាចអនុញ្ញាតឱ្យដោះលែងជនជាប់ចោទដោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" និងដោយមានការធានាសន្តិសុខគ្រប់គ្រាន់ថា (ក) ជនជាប់ចោទត្រូវបានមើលថែទាំត្រឹមត្រូវ, (ខ) គាត់ត្រូវបានរារាំងក្នុងការបង្កឱ្យមានរបួសស្នាមដល់ខ្លួនឯង ឬដល់មនុស្សដទៃ, (គ) គាត់ត្រូវមកបង្ហាញខ្លួន នៅក្នុងតុលាការនៅពេលចាំបាច់ ឬនៅចំពោះមុខមន្ត្រីតុលាការដែលតុលាការបានតែងតាំងសម្រាប់គោលបំណងនេះ និង (ឃ) លក្ខខណ្ឌផ្សេងៗទៀតដែលតុលាការបានកំណត់ថាត្រូវបំពេញ។ បើពុំនោះទេ "តុលាការត្រូវរាយការណ៍អំពីសំណុំរឿងនេះទៅរដ្ឋមន្ត្រីដែលអាចបង្គាប់តាមឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យយកជនជាប់ចោទទៅដាក់នៅកន្លែងព្យាបាលផ្នែកចិត្តសាស្ត្រមួយ ឬកន្លែងសមស្របផ្សេងៗទៀតដែលមានសុវត្ថិភាព ហើយតុលាការត្រូវធ្វើការសម្រេចទៅតាមសេចក្តីបង្គាប់នោះ"។ សាច់ញាតិ ឬមិត្តភក្តិ អាចស្នើឱ្យមានការដោះលែងជនជាប់ចោទ ដោយដាក់ឱ្យស្ថិតក្រោមការថែទាំរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា លក្ខខណ្ឌក្នុងការដោះលែងដូចបានរៀបរាប់ខាងលើ អាចនឹងត្រូវ បានបំពេញ។ កិច្ចដំណើរការនីតិវិធីអាចបន្តទៅទៀតនៅគ្រប់ពេលទាំងអស់ ហើយក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យជនជាប់ចោទដែលបានដោះលែងដោយដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឱ្យមកបង្ហាញខ្លួននៅចំពោះមុខតុលាការ (ក្រមនីតិវិធីព្រហ្មទណ្ឌសិង្ហបុរី, ផ្នែក ២៤៦ ដល់ ២៥៦)។

[115] នៅក្នុងប្រទេសឥណ្ឌា ដំណោះស្រាយប្រហាក់ប្រហែលគ្នាត្រូវបានរក្សាទុក ដែលកិច្ចដំណើរការនីតិវិធីត្រូវបានពន្យារពេលបន្ទាប់ពីរកឃើញថា ជនជាប់ចោទពុំមានសម្បទាដើម្បីចូលរួមក្នុងសវនាការ ប៉ុន្តែអាចមានលទ្ធភាពបន្តសវនាការឡើងវិញក្នុងពេលណាមួយដែលជនជាប់ចោទមានសម្បទាវិញ។ ជនជាប់ចោទអាចត្រូវបានដោះលែង ប្រសិនបើ "បទល្មើសអាចអនុញ្ញាតឱ្យដោះលែងជនជាប់ចោទដោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" និងដោយផ្អែកលើការធានាគ្រប់គ្រាន់ថា ជនជាប់ចោទ "ត្រូវបានមើលថែទាំត្រឹមត្រូវ និងត្រូវបានទប់ស្កាត់ពីការបង្កឱ្យមានរបួសស្នាមដល់ខ្លួនឯង ឬដល់មនុស្សដទៃ ហើយគាត់ត្រូវមកបង្ហាញខ្លួន នៅពេលចាំបាច់" ឬត្រូវបានឃុំឃាំង ដោយមាន "ការថែទាំដែលមានសុវត្ថិភាព" នៅតាមទីតាំង និងលក្ខណៈណាមួយ ដែលតុលាការយល់ឃើញថាសមស្រប។ ជនជាប់ចោទអាចត្រូវបានដោះលែងដោយឱ្យស្ថិតនៅក្រោមការថែទាំរបស់មិត្តភក្តិ ឬសាច់ញាតិ ប្រសិនបើរដ្ឋាភិបាលយល់ឃើញថា ជនជាប់ចោទ នឹង "(ក) ត្រូវបានថែទាំយ៉ាងត្រឹមត្រូវ និងត្រូវបានទប់ស្កាត់ពីការបង្ករបួសស្នាមដល់ខ្លួនឯង ឬដល់អ្នកដទៃ; (ខ) ត្រូវចូលមកបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យរបស់មន្ត្រីពាក់ព័ន្ធ

ហុងគ្រី[118] បានអនុវត្តយកនូវដំណោះស្រាយមួយ ដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងដំណោះស្រាយដែលបានស្នើឡើងខាងលើ ដោយបានជ្រើសរើសធ្វើការផ្អាកកិច្ចដំណើរការនីតិវិធី (ភាសាដែលប្រើប្រាស់ខុសៗគ្នានៅក្នុងចំណោមរដ្ឋផ្សេងៗគ្នា ដែលរួមមាន ការផ្អាក ការព្យួរ ការពន្យារ និង ការផ្អាក) នៅពេលដែលជនជាប់ចោទត្រូវបានយល់ថា មិនមានសម្បទាដើម្បីចូលរួមក្នុងសវនាការ ដោយមិនមានការញែកឲ្យដាច់ពីគ្នារវាងជនជាប់ចោទ ដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ និង ជនជាប់ចោទដែលគ្មានក្ដីសង្ឃឹមសមហេតុផលថា អាចនឹងនាំខ្លួនយកមកជំនុំជម្រះបាន។ ក្នុងអំឡុងពេលនៃការផ្អាកដំណើរការនីតិវិធីច្បាប់ជាតិ ឬយុត្តិសាស្ត្រតែងតែផ្ដល់លទ្ធភាព ដើម្បីរដាក់ចេញនូវវិធានការមួយចំនួន ដែលមានគោលបំណងធានាឲ្យមានការបន្តដំណើរការនីតិវិធីឡើងវិញ និងការការពារសុច្ចរិតភាពរបស់ពួកគេ។ ជាធម្មតា វិធានការទាំងអស់នេះរួមមាន ការវាយតម្លៃផ្នែកវេជ្ជសាស្ត្រជាទៀងទាត់ទៅលើស្ថានភាពរបស់ជនជាប់ចោទ ដែលអាចភ្ជាប់ទៅនឹងការឃុំឃាំងនៅក្នុងមន្ទីរពេទ្យព្យាបាលផ្លូវចិត្ត ឬពន្ធនាគារ ការដោះលែងដោយមានលក្ខខណ្ឌ តាមការចាំបាច់។ រដ្ឋមួយចំនួន ក៏បានចែងឲ្យមានការតែងតាំងអាណាព្យាបាលមួយរូបដែរ ឬក៏របបការពារប្រហាក់ប្រហែល។ ជាពិសេស ដំណោះស្រាយនេះ បានយកទៅអនុវត្តដោយតុលាការ បារាំង

---

និងនៅតាមពេល និងទីកន្លែងតាមការបង្គាប់របស់រដ្ឋាភិបាល; (គ) (...) ត្រូវចូលមកបង្ហាញខ្លួន នៅពេលចាំបាច់ នៅចំពោះមុខចៅក្រម ឬតុលាការ, បង្គាប់ឲ្យបញ្ជូនជននោះទៅសាច់ញាតិ ឬមិត្តភក្តិ" (ក្រមនីតិវិធីព្រហ្មទណ្ឌឥណ្ឌា, ផ្នែក ៣២៨-៣៣២)។

[116] នៅក្នុងប្រទេស បូសហ្វាន់ណា ការជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទដែលគ្មានសម្បទាត្រូវបានផ្អាក ប៉ុន្តែមានលទ្ធភាពក្នុងបន្តការជំនុំជម្រះនេះនៅពេលណាមួយ(ភស្តុតាង និងនីតិវិធីព្រហ្មទណ្ឌរបស់បោះស្វាន់ណា (វិសោធនកម្ម) អនុម័ត ឆ្នាំ ១៩៩៧ មាត្រា ១៦១ (១ និង ២))។

[117] នៅក្នុងប្រទេសអ៊ីស្រាអែល កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទដែលពុំមានសម្បទា "ត្រូវបានបង្អង់" ដោយមានលទ្ធភាពចានឹងដំណើរការនីតិវិធីឡើងវិញ។ មានលទ្ធភាពដែលថា តុលាការអាចចេញសេចក្ដីសម្រេចពីពិរុទ្ធភាពរបស់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទទាមទារឲ្យមានការចេញសេចក្ដីសម្រេចដូចនេះ ឬប្រសិនបើតុលាការមានមូលហេតុពិសេសក្នុងការចេញសេចក្ដីសម្រេចដូចនេះ។ (ច្បាប់នីតិវិធីព្រហ្មទណ្ឌអ៊ីស្រាអែល (១៩៨២), ផ្នែក ១៧០)។ ជនជាប់ចោទអាចត្រូវបានបញ្ជូនទៅសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យ ក្រោម "ការឃ្លាំមើលព្រហ្មទណ្ឌ" និងចុងក្រោយ ក្រោមការឃ្លាំមើលស៊ីវិល (ច្បាប់ស្ដីពីការព្យាបាលអ្នកជំងឺផ្នែកស្មារតី, ឆ្នាំ ១៩៥៥, ផ្នែក ៦(ក); ច្បាប់ស្ដីពីការព្យាបាលអ្នកជំងឺផ្នែកស្មារតី, ឆ្នាំ ១៩៩១, ផ្នែក ១៥; *John Doe v. District Psychiatric Board for Adults*, តុលាការកំពូលអ៊ីស្រាអែល, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣, CrimA 3854/02 (ភាពខុសគ្នារវាងការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ក្រោម "ការឃ្លាំមើលព្រហ្មទណ្ឌ" និង "ការឃ្លាំមើលស៊ីវិល")

[118] ការពិតដូចគ្នាកើតមាននៅក្នុងប្រទេសហុងគ្រី តាមមាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ២០០២ ចែងថា ប្រសិនបើជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបាន កិច្ចដំណើរនេះនឹងត្រូវផ្អាក រហូតដល់ជនជាប់ចោទមានលទ្ធភាពអាចចូលរួមបាន។

ក្នុងប្រព័ន្ធដែលមាននីតិវិធីស្រដៀងគ្នានឹងនីតិវិធីកម្ពុជាដែរនោះ ពុំមានបទប្បញ្ញត្តិច្បាប់ដោះស្រាយជាមួយនឹងស្ថានភាពដែលជនជាប់ចោទមិនមានសម្បទាចូលរួមក្នុងសវនាការនោះទេ និងក្នុងករណីដែលដំណើរការនីតិវិធីសវនាការត្រូវបានផ្អាក[119]។ ទោះបីនៅក្នុងករណីថា ដំណើរការនីតិវិធីមិនអាចចាប់ផ្តើមបន្តឡើងវិញបានក៏ដោយ ក៏ដំណើរការនីតិវិធីមិនអាចត្រូវបានបញ្ចប់នោះទេ ហើយតុលាការកំពូលបារាំង បានលើកឡើងនៅក្នុងសាលដីការបស់ខ្លួនថា ទោះបីជាខ្វះបទប្បញ្ញត្តិជាក់លាក់ដើម្បីដោះស្រាយជាមួយស្ថានភាពដែលម្ចាស់បណ្តឹងឧទ្ធរណ៍ មិនមានសម្បទាចូលរួមក្នុងដំណើរការនីតិវិធីបាន តុលាការគួរតែចាត់វិធានការចាំបាច់មួយចំនួន ដើម្បីធានាថា សិទ្ធិរបស់ភាគី និងផលប្រយោជន៍យុត្តិធម៌ត្រូវបានការពារ[120]។

---

[119] B. Bouloc, Droit penal general, Dalloz ថ្ងៃទី ២០ ឆ្នាំ ២០០៧, ទំព័រ ៣៦៣; F. Desportes and F. Le Gunehec, *Droit pénal général*, Economica, បោះពុម្ពលើកទី ៩, ឆ្នាំ ២០០២, ទំព័រ ៥៨៩; Crim. Cass (តុលាការកំពូលព្រហ្មទណ្ឌ) ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៨៥ (តុលាការកំពូលព្រហ្មទណ្ឌ បានសម្រេចថា ដីកាដំណោះស្រាយ និងដីកាកោះជនជាប់ចោទឱ្យចូលរួមក្នុងសវនាការ ត្រូវបានចេញដោយមានសុពលភាព ក្នុងពេលដែលជនជាប់ចោទមាន "ជំងឺឆ្កួត" ប៉ុន្តែកិច្ចដំណើរការនីតិវិធីតុលាការត្រូវតែបង្អង់ រហូតដល់ពេលជនជាប់ចោទជាសះស្បើយពីបញ្ហាបញ្ញាស្មារតីរបស់គាត់ ដែលបានកើតឡើងនៅក្នុងសំណុំរឿងនេះ)។

[120] Crim. Cass (តុលាការកំពូលព្រហ្មទណ្ឌ) ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ១៩៩៧, Bull. Crim. ២២៨, ទំព័រ ៧៦១។ (បន្ទាប់ពីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការផ្តន្ទាទោសឧក្រិដ្ឋកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ម្ចាស់បណ្តឹងឧទ្ធរណ៍មានជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ហើយជាលទ្ធផល សមត្ថភាពសតិបញ្ញារបស់គាត់ត្រូវបានធ្លាក់ចុះជាប្រចាំរហូតដល់កម្រិតមួយដែលគាត់ពុំមានសម្បទាគ្រប់គ្រាន់ដើម្បីពិគ្រោះរឿងក្តីជាមួយនឹងមេធាវីរបស់គាត់ និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសាលាឧទ្ធរណ៍បានឡើយ។ បើទោះបីថា ស្ថានភាពសុខភាពរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានរងការប៉ះពាល់ជាអចិន្ត្រៃយ៍ក៏ដោយ ក៏កិច្ចដំណើរការនីតិវិធីមិនត្រូវបានបញ្ឈប់ឡើយ ប៉ុន្តែកិច្ចដំណើរការនីតិវិធីនោះត្រូវបានបង្អង់)។ អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ពីវិធីសាស្ត្រជាក់ស្តែងដែល Tribunal de Grande Instance de Paris បានអនុវត្តក្នុងសំណុំរឿងរបស់ Jacques Chirac ដែលនៅក្នុងសំណុំរឿងនេះ បន្ទាប់ពីលោក Chirac បានដាក់សំណើរបស់ខ្លួន តុលាការនេះបានបន្តកិច្ចដំណើរការដោយពុំមានវត្តមានរបស់គាត់។ *សូមមើលរឿងក្តី Ministère public ទល់នឹង Roussin et consorts*, សំណុំរឿងលេខ 9834923017, Tribunal de Grande Instance de Paris, "សាលក្រម", ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ (ចំនួនពីរបីថ្ងៃមុនពេលបើកសវនាការ, មេធាវីការពារក្តីឱ្យ Jacques Chirac បានដាក់របាយការណ៍អ្នកជំនាញមួយ ដោយធ្វើការបញ្ជាក់ថា ស្ថានភាពបញ្ញាស្មារតីរបស់លោក Chirac មានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ប្រហែលជាបណ្តាលមកពីជំងឺវង្វេងវង្វាន់ (Alzheimer) ដូច្នេះ គាត់មិនអាចចូលរួមផ្តល់សក្ខីកម្ម ក្នុងអំឡុងពេលសវនាការរបស់គាត់ឡើយ។ ភ្ជាប់មកជាមួយនឹងរបាយការណ៍នេះ មេធាវីការពារក្តីរបស់ Chirac បានដាក់លិខិតមួយពីកូនក្តីរបស់ខ្លួន ដែលបានបង្ហាញពីបំណងប្រាថ្នារបស់ខ្លួនចង់ឱ្យមានការជំនុំជម្រះក្តី និងបានស្នើសុំឱ្យមានការជំនុំជម្រះ ដោយពុំមានរូបគាត់ចូលរួម ក្នុងពេលគាត់ត្រូវបានតំណាងដោយមេធាវីរបស់គាត់។ ចៅក្រមបានទទួលយកសំណើនេះ អនុលោមតាមមាត្រា ៤១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ការជំនុំជម្រះត្រូវបានធ្វើឡើងដោយគ្មានវត្តមានរបស់

42. ការផ្អាកដំណើរការនីតិវិធីទាក់ទងនឹងជនជាប់ចោទ ដែលលក្ខខណ្ឌរបស់ខ្លួន មិនទំនងជាធ្វើឱ្យពួកគាត់នឹងប្រឈមមុខទៅនឹងការជំនុំជម្រះបាន ត្រូវបានយកមកជជែកតវ៉ានៅចំពោះមុខតុលាការជាតិ ក៏ដូចជានៅចំពោះមុខតុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្សដែរ។

43. អ្វីដែលទាក់ទងផ្ទាល់ជាងគេបំផុតនោះគឺ តុលាការធម្មនុញ្ញអ៊ីតាលី បានទទួលនូវការប្ដឹងជំទាស់មួយប្រឆាំងនឹងបញ្ញត្តិដែលតម្រូវឲ្យជនជាប់ចោទដែលគ្មានសម្បទាគ្រាប់គ្រាន់ជាអចិន្ត្រៃយ៍ ត្រូវទទួលការវាយតម្លៃផ្នែកវេជ្ជសាស្ត្រតាមជាប្រចាំ[121]។ ម្ចាស់បណ្ដឹងបានលើកឡើងថា ក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងពីការវាយតម្លៃឡើងវិញជាទៀងទាត់ជារៀងរាល់ប្រាំមួយខែម្ដង ចំពោះសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ ប៉ុន្តែមិនបានចែងនូវបញ្ញត្តិជាក់លាក់ណាមួយដែលចែងពាក់ព័ន្ធករណីសម្បទាមិនអាចស្ដារឡើងវិញបាននោះ បានរំលោភទៅលើសិទ្ធិធានានូវការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ព្រោះការផ្អាកនិងការវាយតម្លៃឡើងវិញជាបន្តបន្ទាប់ តាមបញ្ញត្តិនោះពិតជាធ្វើឲ្យជនជាប់ចោទត្រូវទទួលការជំនុំជម្រះពេញមួយជីវិតរបស់គាត់[122]។ ម្ចាស់បណ្ដឹងបានលើកឡើងថារោគផ្លូវចិត្តដែលមិនអាចព្យាបាលជា គួរតែអាចនាំទៅដល់ការបញ្ចប់បណ្ដឹងអាជ្ញា ដូចគ្នានឹងករណីដែលជនជាប់ចោទទទួលមរណភាពដែរ[123]។ ក្នុងការបដិសេធមិនបើកសវនាការលើបណ្ដឹងនេះ តុលាការធម្មនុញ្ញនៅអ៊ីតាលី បានវែកញែកនូវហេតុផលនៃផលវិបាកផ្លូវច្បាប់នៃជំងឺផ្លូវចិត្តរ៉ាំរ៉ៃ ចេញពីផលវិបាកផ្លូវច្បាប់នៃមរណភាព ដោយតុលាការបានបង្ហាញថា ផលវិបាកផ្លូវច្បាប់នៃមរណភាពអាចបញ្ជាក់បានដោយច្បាស់លាស់ ប៉ុន្តែផលវិបាកផ្លូវច្បាប់នៃជំងឺផ្លូវចិត្តរ៉ាំរ៉ៃពឹងផ្អែកទៅលើការវិនិច្ឆ័យទុកជាមុនរបស់ពេទ្យដែលផ្អែកលើចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ក្នុងពេលបច្ចុប្បន្នហើយងាយនឹងទទួលឥទ្ធិពលពីអាកប្បកិរិយាបោកប្រាស់របស់ជនជាប់ចោទ[124]។ តុលាការបានផ្ដល់សំអាងហេតុបន្ថែមទៀតថា មូលដ្ឋានសម្រាប់ការបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងករណីមរណភាព គឺជាអាជ្ញាបញ្ញាដែលទាញចេញពីសញ្ញាណដែលថាការទទួលខុសត្រូវព្រហ្មទណ្ឌគឺផ្សារភ្ជាប់ទៅនឹងបុគ្គល ប៉ុន្តែមូលដ្ឋានសម្រាប់ការផ្អាកកិច្ចដំណើរការនីតិវិធី ក្នុងករណីដែលជនជាប់ចោទមិនមានសម្បទាផ្នែកសតិបញ្ញានោះគឺទាញចេញពី

---

Chirac។ លោក Chirac ត្រូវបានរកឃើញថាមានពិរុទ្ធភាព ដោយត្រូវដាក់ពន្ធនាគារចំនួនពីរឆ្នាំ ប៉ុន្តែទោសនោះត្រូវព្យួរ។ លោកមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការផ្ដន្ទាទោសនេះឡើយ)។

[121] Ordinanza N. 289/2011, Corte Constituzionale, ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ (Ordinanza N. 289/2011)។

[122] Ordinanza N. 289/2011, ទំព័រ ៣, ៥។

[123] Ordinanza N. 289/2011, ទំព័រ ៣។

[124] Ordinanza N. 289/2011, ទំព័រ ៣។

គោលការណ៍នីតិវិធីដែលការពារសិទ្ធិរបស់ជនជាប់ចោទ ក្នុងការការពារខ្លួន[125]។លើសពីនេះទៅទៀត តុលាការបានសម្រេចថាការវាយតម្លៃឡើងវិញតាមកាលកំណត់គឺជាការចាំបាច់ ដើម្បីផ្តល់នូវលទ្ធភាព ក្នុងការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសំណុំរឿងឡើងវិញ[126]។

44. បញ្ហាដូចគ្នានេះត្រូវបានជំទាស់នៅចំពោះមុខតុលាការកំពូលក្នុងរឿងក្តី *R ទល់នឹង Demers*។ នៅពេលនោះរបបគតិយុត្តិដែលនៅជាធរមានតាមក្រមព្រហ្មទណ្ឌ ចែងអំពីការព្យាបាលជាបន្ត ឬការវាយតម្លៃតាមកាលកំណត់ទៅលើជនជាប់ចោទដែលត្រូវបានរកឃើញថា មិនមានសម្បទាក្នុងការចូលរួមការសវនាការ ដោយផ្តល់នូវជម្រើសមួយដែលអាចជាការឃុំខ្លួនជនជាប់ចោទ (នៅក្នុងពន្ធនាគារឬមន្ទីរពេទ្យព្យាបាលរោគផ្លូវចិត្ត) ឬការដោះលែងដោយមានលក្ខខណ្ឌ។ ការជំទាស់ទៅនឹងធម្មនុញ្ញត្រូវបានធ្វើឡើងនៅចំពោះមុខតុលាការកំពូលរបស់ប្រទេសកាណាដា ដោយផ្អែកទៅលើមូលដ្ឋានដែលថា ការដែលពុំមានលទ្ធភាពក្នុងការដោះលែង (ឬការដោះលែងដោយឥតលក្ខខណ្ឌ) សម្រាប់ជនជាប់ចោទដែលគ្មានសម្បទាជាអចិន្ត្រៃយ៍ បានរំលោភទៅលើសិទ្ធិមួយចំនួន ក្នុងនោះរួមទាំងសិទ្ធក្នុងការទទួលបានសេរីភាពដែលមានចែងក្នុងធម្មនុញ្ញរបស់ប្រទេសកាណាដាស្តីពីសិទ្ធិ និងសេរីភាព។ តុលាការកំពូលប្រទេសកាណាដាបានសម្រេចថា "ជនជាប់ចោទដែលគ្មានសម្បទាជាអចិន្ត្រៃយ៍ មិនអាចនឹងមានសម្បទាឡើងវិញ ហើយក៏មិនអាចនឹងយកមកធ្វើការជំនុំជម្រះផងដែរ។ បុគ្គលបែបនេះនឹងទទួលរងនូវភិតភ័យ ការបារម្ភ និងភាពអាម៉ាស់ក្នុងសង្គម ដោយសារតែកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅតែបន្តតាមពួកគេដោយគ្មានពេលបញ្ចប់"[127]។ តុលាការបានពិចារណាទៅលើបញ្ហាជាក់លាក់ ដែលមិនមានការវាយតម្លៃផ្អែកសតិបញ្ញាតាមកាលកំណត់ដែលនឹងអនុញ្ញាតឲ្យមានការរៀបចំលក្ខខណ្ឌសម្រាប់ការដោះលែងជនជាប់ចោទ។ បន្ទាប់មក តុលាការបានបន្តសម្រេចថា ដោយមិនអនុញ្ញាតឲ្យមានលទ្ធភាពក្នុងការដោះលែងជាដាច់ខាតចំពោះជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍នោះបញ្ញត្តិដែលរងការជំទាស់បានរំលោភទៅលើសិទ្ធិទទួលបានសេរីភាពរបស់ជនជាប់ចោទ៖

> "តាមទស្សនៈរបស់យើង ផ្នែក XX.1 Cr.C មិនបានដោះស្រាយដោយយុត្តិធម៌ចំពោះជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ ហើយដែលមិនមែនជាការគម្រាមកំហែងធ្ងន់ធ្ងរដល់សុវត្ថិភាពសាធារណៈ។ មិនមានការសម្រេចបាននូវផលប្រយោជន៍សង្គមក្នុងការនាំយកជនជាប់ចោទមកធ្វើការជំនុំជម្រះ ហើយក៏មិនមានការសម្រេច

[125] Ordinanza N. 289/2011, ទំព័រ ៣។

[126] Ordinanza N. 289/2011, ទំព័រ ៤។

[127] *រឿងក្តី R. ទល់នឹង Demers*, [ឆ្នាំ ២០០៤] 2 S.C.R. 489, ("*រឿងក្តី R. ទល់នឹង Demers*") កថាខណ្ឌ ៥៣។

បាននូវផលប្រយោជន៍សង្គម ក្នុងការប្រព្រឹត្តិដោយយុត្តិធម៌ចំពោះជនជាប់ចោទផងដែរ។ របបច្បាប់មិនបានចែងពីការបញ្ចប់ការចោទប្រកាន់នោះឡើយ។ ជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដោយគ្មានកំណត់ទៅលើសេរីភាពរបស់ពួកគាត់ ត្រូវទទួលរងការរិតបន្តឹងដែលមានកម្រិតប្រែប្រួលផ្សេងៗគ្នាដែលជាលទ្ធផលនៃការចេញដីកាសម្រេចសេចក្តីពីក្រុមប្រឹក្សាត្រួតពិនិត្យ ឬពីតុលាការដែលមិនមានសូម្បីតែអំណាច ក្នុងការបង្គាប់ឱ្យមានការវាយតម្លៃផ្នែកសតិបញ្ញា ដើម្បីធ្វើឱ្យការសម្រេចសេចក្តីសមស្របទៅតាមកាលៈទេសៈក្នុងពេលបច្ចុប្បន្នរបស់ជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍។ ហេតុដូច្នេះ ការដែលរបបគតិយុត្តិមិនមានបញ្ញត្តិចែងអំពីជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ រួមជាមួយនឹងការបន្តឱ្យជនជាប់ចោទដែលមិនមានសម្បទាទទួលរងនូវដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលមានភស្តុតាងយ៉ាងច្បាស់ប្រាកដថា សម្បទារបស់ជនជាប់ចោទនឹងមិនអាចស្តារឡើងវិញបាននោះ ធ្វើឱ្យក្របខណ្ឌច្បាប់ទាំងមូលដែលស្ថិតក្រោមផ្នែក XX.1 មានភាពទូលំទំលាយជ្រុល ដោយសារតែបញ្ហានេះពាក់ព័ន្ធទៅនឹងជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ ហើយដែលមិនបង្កនូវការគម្រាមកំហែងធ្ងន់ធ្ងរដល់សុវត្ថិភាពសាធារណៈឡើយ”[128]។

ទោះបីជាតុលាការកំពូលប្រទេសកាណាដាគាំទ្រការបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងករណីដែលគ្មានសម្បទាជាអចិន្ត្រៃយ៍ក៏ដោយ ក៏តុលាការនេះបានសង្កត់ធ្ងន់ថា ការផ្អាកកិច្ចដំណើរការនីតិវិធី (ដែលមានន័យដូចគ្នានឹងការបញ្ចប់កិច្ចដំណើរការនីតិវិធីតាមច្បាប់កាណាដា) មិនត្រូវធ្វើឡើងដោយស្វ័យប្រវត្តិនោះឡើយ ទោះបីជាក្នុងករណីជនជាប់ចោទមិនមានសម្បទាជាអចិន្ត្រៃយ៍ក៏ដោយ ហើយត្រូវធ្វើការពិចារណាទៅលើកត្តាផ្សេងៗគ្នាជាច្រើន មុននឹងអនុម័តយកវិធីសាស្ត្រ “ដែលធ្ងន់ធ្ងរ” ហើយកត្តាដែលត្រូវពិចារណានោះរួមបញ្ចូលទាំងស្ថានទម្ងន់នៃបទចោទផងដែរ៖

“ក្នុងការសម្រេចថាតើត្រូវអនុញ្ញាត ឬមិនអនុញ្ញាតការផ្អាកកិច្ចដំណើរការនីតិវិធី តុលាការត្រូវតែពិចារណាទៅលើកត្តានានា ដូចជា លក្ខណៈនៃការចោទប្រកាន់ រយៈពេលចាប់តាំងពីពេលប្រព្រឹត្តិបទល្មើស ការប្រព្រឹត្តិនៅពេលបន្ទាប់ ការវាយតម្លៃផ្នែកវេជ្ជសាស្ត្របឋម និងបច្ចុប្បន្ន ថាតើជនជាប់ចោទបានទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រដែលចាំបាច់ក្នុងការលុបបំបាត់នូវហានិភ័យ ព្រមទាំងព័ត៌មានដែលពាក់ព័ន្ធនឹងកាលៈទេសៈនានារបស់ជនជាប់ចោទ។ ដូចដែលតុលាការមួយនេះបានបញ្ជាក់នៅក្នុងរឿងក្តី *ប្រទេសកាណាដា (រដ្ឋមន្ត្រី*

[128] *រឿងក្តី R. ទល់នឹង Demers*, កថាខណ្ឌ ៥៥។

*(ក្រសួងសញ្ជាតិ និងអន្តោប្រវេសន៍) តទល់នឹង* Tobiass [1997] S.C.R 391 ត្រង់កថាខណ្ឌ ៩២ ថា ជាការត្រឹមត្រូវផងដែរនៅដំណាក់កាលនេះ "ក្នុងការថ្លឹងថ្លែងរវាងផលប្រយោជន៍ដែលទទួលបានដោយការសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី ធៀបទៅនឹងផលប្រយោជន៍ដែលសង្គមទទួលបាន ក្នុងការចេញសេចក្តីសម្រេចស្ថាពរលើអង្គសេចក្តី"។ ការថ្លឹងថ្លែងនេះបានទទួលស្គាល់ថា រដ្ឋបាលតុលាការត្រូវបានអនុវត្តយ៉ាងល្អបំផុត ដោយការផ្អាកកិច្ចដំណើរការនីតិវិធី ក្នុងករណីដែលប្រមាថទៅនឹងភាពយុត្តិធម៌ និងភាពត្រឹមត្រូវ មិនសមមាត្រជាមួយផលប្រយោជន៍សង្គមក្នុងការដាក់ឱ្យជនជាប់ចោទទទួលរងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ៖*R. v.Conway*, [1989] 1 S.C.R. 1659ត្រង់ទំព័រ១៦៦៧"[129]។

45. ដីកាផ្អាកកិច្ចដំណើរការនីតិវិធីក្នុងករណីដែលជនជាប់ចោទប្រហែលជាមិនអាចមានសម្បទាចូលរួមក្នុងសវនាការ ក៏ត្រូវបានជំទាស់ផងដែរនៅចំពោះមុខតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("ECt HR") ថាជាការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាដ៏សមស្រប ដូចមានចែងក្នុងមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស("ECHR")។ ក្នុងរឿងក្តី *Krakolining តទល់ នឹងប្រទេសអូទ្រីស* ម្ចាស់បណ្តឹងត្រូវបានរកឃើញថាមិនមានសម្បទាក្នុងការចូលរួមសវនាការ បន្ទាប់ពីគាត់បានទទួលរងជំងឺគាំងបេះដូងដែលធ្វើឱ្យគាត់មាន "សុខភាពខ្សោយ" ដោយមានសង្ឃឹមតិចតួចថាមានការប្រសើរឡើងវិញក្នុងពេលអនាគតឆាប់ៗខាងមុខ[130]។ តុលាការប្រទេសអូទ្រីសបានសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងម្ចាស់បណ្តឹង ប៉ុន្តែតុលាការបានច្រានចោលសំណើរសុំបញ្ចប់កិច្ចដំណើរការនីតិវិធីដោយសារតែ"ស្ថានភាពសុខភាពរបស់ម្ចាស់បណ្តឹងតែមួយមុខមិនអាចធ្វើជាសំអាងហេតុសម្រាប់ការបញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងរូបគាត់បានឡើយ"[131]។ ក្នុងការសម្រេចថាពាក្យបណ្តឹងមិនអាចទទួលយកបាននោះ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានសម្រេចថា បើទោះបីជាមិនស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ក៏ដោយ ក៏ស្ថានភាពសុខភាពរបស់ជនជាប់ចោទ "ដោយគ្មានមន្ទិលសង្ស័យ គឺ

---

[129] *រឿងក្តី R. ទល់នឹង* Demers, កថាខណ្ឌ ៦៤។

[130] *រឿងក្តី* Krakolinig *ទល់នឹង* Austria, តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, "សេចក្តីសម្រេចស្តីអំពីភាពអាចទទួលយកបានតាមទម្រង់", សំណើសុំលេខ 33992/07, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២, "សេចក្តីសម្រេចលើរឿងក្តី *Krakolinig*" កថាខណ្ឌ ៧ និង១០។

[131] សេចក្តីសម្រេចលើ *រឿងក្តី Krakolinig* កថាខណ្ឌ ១៣។

ជាមូលហេតុជាសត្យានុម័តសម្រាប់រយៈពេលនៃកិច្ចដំណើរការនីតិវិធី"[132]។ តុលាការបានបញ្ជាក់យ៉ាងច្បាស់ថា "ការរំលោភទៅលើលក្ខខណ្ឌតម្រូវនៃពេលវេលាសមស្របដូចមានចែងក្នុងមាត្រា ៦ អាចកើតឡើងទៅបាន តែក្នុងករណីដែលថា ការផ្អាកពេលនោះបង្កឡើងដោយតុលាការជាតិ"[133]។ ជាពិសេស សម្រាប់ការពិចារណាក្នុងពេលបច្ចុប្បន្ននេះ តុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានកត់សម្គាល់បន្ថែមទៀតថា "មាត្រា ៦ មិនបានផ្តល់សិទ្ធិទទួលបានការបញ្ចប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយផ្អែកលើស្ថានភាពសុខភាពរបស់ជនជាប់ចោទនោះឡើយ"[134]។ ក្នុងរឿងក្តី *Nichitaylov តទល់នឹងប្រទេសអ៊ុយក្រែន* កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងម្ចាស់បណ្តឹង ត្រូវបានផ្អាក "ដោយគ្មានពេលកំណត់" ដោយតុលាការថ្នាក់តំបន់ ដោយហេតុថាម្ចាស់បណ្តឹងមិនមានសម្បទាចូលរួមក្នុងសវនាការដែលបណ្តាលមកពីភាពពិការភ្នែក និងថ្លង់ទាំងស្រុង និងជាអចិន្ត្រៃយ៍។ តុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្សបានកត់សម្គាល់ថា "បើទោះបីជាលទ្ធភាពបែបសម្មតិកម្មនៃការបន្តកិច្ចដំណើរការនីតិវិធីនៅអាចមានក៏ដោយ ក៏ក្នុងពេលបច្ចុប្បន្ននេះហាក់ដូចជាមិនមានចេតនាណាមួយក្នុងការបន្តកិច្ចដំណើរការនីតិវិធីនេះឡើយ"[135]។ នៅទីបំផុត បើទោះបីជាតុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្សបានសម្រេចជាស្ថាពរថា សិទ្ធិរបស់ម្ចាស់បណ្តឹងក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប ត្រូវបានរំលោភបំពានក្នុងរឿងក្តីនេះ ដោយសារតែកិច្ចដំណើរការនីតិវិធីដែលនាំទៅដល់ការផ្អាកនោះ ត្រូវបានរកឃើញថាមានរយៈពេលវែងដោយមិនសមហេតុផលនោះក៏ដោយ ក៏តុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្សបានពិចារណាថា រយៈពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាកនោះ មិនអាចចាត់ទុកថាជាការរំលោភសិទ្ធិនោះឡើយ[136]។ យុត្តិសាស្ត្រនេះបានបង្ហាញថា តុលាការអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្សមិនបានពិចារណាដល់

---

[132] សេចក្តីសម្រេចលើ *រឿងក្តី Krakolinig* កថាខណ្ឌ ២៧។

[133] សេចក្តីសម្រេចលើ *រឿងក្តី Krakolinig* កថាខណ្ឌ ២៧។

[134] សេចក្តីសម្រេចលើ *រឿងក្តី Krakolinig* កថាខណ្ឌ ២៧។

[135] *រឿងក្តី Nichitaylov តទល់នឹង Ukraine,* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, សំណើសុំលេខ 36024/03, សាលក្រមអង្គជំនុំជម្រះ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០, (សេចក្តីសម្រេចលើ *រឿងក្តី Nichitaylov*) កថាខណ្ឌ ៣៦។

[136] សេចក្តីសម្រេចលើ *រឿងក្តី Nichitaylov* កថាខណ្ឌ ៣៦។ *សូមមើលផងដែរ៖ រឿងក្តី Antoine ទល់នឹង United Kingdom,* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, សំណើសុំលេខ 62960/00, "សេចក្តីសម្រេចស្តីអំពីភាពអាចទទួលយកបានតាមទម្រង់", ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣, ("សេចក្តីសម្រេចលើ *រឿងក្តី Antoine*") ទំព័រ ១១ ("បញ្ហាដែលថាតើអ្នកដាក់ពាក្យសុំត្រូវធ្វើការជំនុំជម្រះក្នុងអំឡុងពេលមួយសមរម្យ ឬយ៉ាងណានោះ នឹងអាស្រ័យលើការត្រួតពិនិត្យរយៈពេលរវាងវិធានដាក់ស្តែងដំបូងក្នុង

មាត្រា ៦(១) ជាមួយករណីយុត្តាធិការថ្នាក់ជាតិ ដែលអនុញ្ញាតឲ្យមានការផ្អាកដោយគ្មានពេលកំណត់ចំពោះកិច្ចដំណើរការនីតិវិធីប្រឆាំងជនជាប់ចោទដែលពុំមានសម្បទាជាអចិន្ត្រៃយ៍នោះទេ។

46. ដំណោះស្រាយដោយការបង្អង់ ឬផ្អាកជាបណ្តោះអាសន្ននូវកិច្ចដំណើរការនីតិវិធីដោយមិនបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទដោយសារពុំមាននីតិសម្បទា គ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយនិងដោយការបន្តអនុវត្តនូវយុត្តាធិការ កន្លងមកត្រូវបានគាំទ្រដោយតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍នានា ដែលមិនមានបញ្ញត្តិចែងពាក់ព័ន្ធទៅនឹងជនជាប់ចោទដែលមិនមានសម្បទាក្នុងការចូលរួមក្នុងសវនាការនៅក្នុងឯកសារច្បាប់គោល ឬវិធាននីតិវិធីរបស់ខ្លួននោះ។ តុលាការយោធាអន្តរជាតិ Nuremberg ព្រមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត បានបន្តរក្សាយុត្តាធិការរបស់ខ្លួនទៅលើជនជាប់ចោទទាំងអស់ ដែលត្រូវបានរកឃើញថាមិនមានសម្បទាក្នុងការចូលរួមសវនាការក្នុងពេលកន្លងមក ដោយរួមបញ្ចូលទាំងការដាក់លក្ខខណ្ឌទៅលើការដោះលែង ដែលមានគោលដៅធានានូវវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ ការការពារបុគ្គលដទៃ និងរារាំងការជ្រៀតជ្រែកទៅក្នុងរដ្ឋបាលតុលាការ ទោះបីជានៅក្នុងកាលៈទេសៈដែលកិច្ចដំណើរការនីតិវិធីប្រហែលជាមិនអាចបន្តឡើងវិញបានក៏ដោយ។ ជាពិសេសតុលាការយោធាអន្តរជាតិបានបំបែក និងផ្អាកការជំនុំជម្រះប្រឆាំងជនជាប់ចោទ Gustav Krupp von Bohlen ជាជនជាប់ចោទម្នាក់ដែលទទួលរងការអន់ថយផ្នែកសតិបញ្ញា និងរូបរាងកាយយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែតុលាការបានបង្គាប់ឲ្យរក្សានូវបទចោទនៅក្នុងសំណុំរឿង ក្នុងករណីដែលជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ តុលាការនឹងធ្វើការជំនុំជម្រះឡើងវិញដែលពុំដែលកើតមាន[137]។ នៅ

---

ការរៀបចំឲ្យមានសវនាការមួយទៀតដែលអាចចាត់ទុកថាជាការប៉ះពាល់យ៉ាងខ្លាំងលើជំហររបស់អ្នកដាក់ពាក្យសុំ និងការបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងនោះ")។

[137] "ដីការបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលអនុញ្ញាតឲ្យមានការពន្យារពេលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង Gustav Krupp von Bohlen", ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ត្រូវបានអនុវត្តឡើងវិញនៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខតុលាការព្រហ្មទណ្ឌយោធា, តុលាការ Nuremberg ឆ្នាំ ១៩៤៧ ("ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗ") ទំព័រ ២០ ដល់ ២១។ នៅពេលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានធ្វើឡើងទៅលើ Krupp, ជនជាប់ចោទដេកនៅនឹងមួយ កន្លែង នៅក្នុងផ្ទះរបស់ខ្លួននៅក្នុង Bluhbach, Austria។ វេជ្ជបណ្ឌិត បានហៅគាត់មកធ្វើការពិនិត្យ រកឃើញថា ជនជាប់ ចោទមិនអាចធ្វើដំណើរបាន ដោយប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពរបស់ខ្លួន។ (លិខិតស្តីពីសេវាកម្មលើជនជាប់ចោទ *Gustav Krupp von Bohlen*, ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៤៥, ត្រូវបានអនុវត្តឡើងវិញ នៅក្នុង ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Djukic* បានបដិសេធមិនដកចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមសំណើរបស់មេធាវីការពារក្តី និងរដ្ឋអាជ្ញាឡើយ បើទោះបីជាមាន "ការធ្លាក់ចុះផ្នែកសតិបញ្ញាដែលមិនអាចជៀសបាន" ដែលបណ្តាលមកពីជំងឺដែលមិនអាចព្យាបាលបានក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ទាំងនៅក្នុងលក្ខន្តិកៈ ក៏ដូចជានៅក្នុងវិធានរបស់តុលាការ ICTY មិនមានចែងពីការផ្តល់សិទ្ធិដល់ការដកចេញនោះឡើយ ហើយអង្គជំនុំជម្រះបានដកស្រង់ករណីប្រហាក់ប្រហែលគ្នានេះនៅតុលាការ Nuremberg និងតុលាការទីក្រុងតូក្យូ ដែលមិនបានដកចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងជនត្រូវចោទដែលមានជំងឺស្ថិតក្នុងដំណាក់កាលចុងក្រោយនោះឡើយ[138]។ អង្គជំនុំជម្រះបានយល់ឃើញថា ភាពធ្ងន់ធ្ងរខ្លាំងនៃស្ថានភាព(ជំងឺ) ជនជាប់ចោទ តម្រូវឱ្យមានការដោះលែងដោយផ្អែកលើមូលដ្ឋានមនុស្សធម៌ ប៉ុន្តែបើពិចារណា "ទៅលើអង្គហេតុដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងជនជាប់ចោទត្រូវតែបន្ត វិធានការលើកលែងបែបនេះត្រូវតែធ្វើឡើងជាមួយលក្ខខណ្ឌដ៏តឹងតែងដើម្បីធានានូវវត្តមានរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងករណីចាំបាច់"[139] ។ បើទោះបីជាអាចមានការជំទាស់ ថាតើ លក្ខខណ្ឌដែលត្រូវបានដាក់ចំពោះការដោះលែង *Djukic* ពិតជា "តឹងតែង" ឬយ៉ាងណានោះក៏ដោយ ឬក៏ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានដកស្រង់ ថាការដោះលែងនេះ

---

សំខាន់ៗ ឆ្នាំ ១៩៤៧ វ៉ុល I, ទំព័រ ១១៨)។ កិច្ចដំណើរការនីតិវិធី ត្រូវបានផ្អាកបន្ទាប់ ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយជនជាប់ចោទលែងបាននាំយកមកជំនុំជម្រះនៅក្នុងចំពោះមុខតុលាការព្រហ្មទណ្ឌយោធាអន្តរជាតិ ឬត្រូវបានឃុំខ្លួនឡើយ (*សូមមើល*: ចម្លើយរបស់សហរដ្ឋអាមេរិក ទៅនឹងសំណើសុំដែលបានដាក់ជំនួស *Gustav Krupp von Bohlen*, ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ត្រូវបានអនុវត្តឡើងវិញនៅក្នុងការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ វ៉ុល I ទំព័រ ១៣៤ ដល់ ១៣៨), នៅពេលដែលតំណាងសហរដ្ឋអាមេរិកលើកឡើងថា "[i]t ទំនងជាថា Krupp គប្បីមិនត្រូវបានចាប់ខ្លួន និងនាំយកទៅតុលាការដើម្បីជំនុំជម្រះនោះទេ")។ ជនជាប់ចោទ ទទួលបានសេរីភាព ហើយស្លាប់ក្នុងឆ្នាំ ១៩៥០(សូមមើលគេហទំព័រ US Holocaust Museum website at http://www.ushmm.org/wlc/en/article.php?ModuleId=10007117)។

[138] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Djukic*, សំណុំរឿងលេខ IT -96-20-T, សេចក្តីសម្រេចបដិសេធក្នុងការដកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការបង្គាប់ឱ្យដោះលែងបណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ "សេចក្តីសម្រេចលើ *រឿងក្តី Djukic*"។ កិច្ចដំណើរការនីតិវិធីនានាត្រូវបានបញ្ចប់ ចំនួនពីរបីខែក្រោយមក បន្ទាប់ពីជនជាប់ចោទបានស្លាប់ (*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Djordje Djukic*, សំណុំរឿងលេខ IT-96-20-T, ដីកាបញ្ចប់កិច្ចដំណើការនីតិវិធីលើបណ្តឹងសាទុក្ខ, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៦)។

[139] សេចក្តីសម្រេចលើ *រឿងក្តី Djukic*, ទំព័រ ៤។

ក្រោយមក គឺជា"តាមការជាក់ស្តែងគឺគ្មានលក្ខខណ្ឌ"[140]ក៏ដោយ ក៏ភាពខុសគ្នានៃទស្សនៈបែបនេះមិនបានបន្ថយនូវភាពប្រហាក់ប្រហែលគ្នានៃសេចក្តីសម្រេចក្នុងរឿងក្តី *Djukic* ដែល *Djukic* ត្រូវបានតម្រូវឲ្យផ្តល់ព័ត៌មានពីអាសយដ្ឋានរបស់គាត់ ព្រមទាំងប្រគល់របាយការណ៍វេជ្ជសាស្ត្រស្តីពីស្ថានភាពជំងឺរបស់គាត់តាមកាលកំណត់ទៀតទាត់ ព្រមទាំងត្រូវគោរពទៅតាមដីកាកោះរបស់តុលាការ ប្រសិនបើស្ថានភាពសុខភាពរបស់គាត់អនុញ្ញាតដើម្បីប្រឈមមុខទៅនឹងរឿងក្តីក្នុងពេលបច្ចុប្បន្ន។ នៅក្នុងបរិបទមួយទៀតដែលខុសប្លែកបន្តិច[141] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបង្គាប់ឲ្យដោះលែង *Talic* ជាបណ្តោះអាសន្ន ដោយផ្អែកលើមូលដ្ឋានដែលថា ជំងឺរបស់គាត់ស្ថិតក្នុងដំណាក់កាលចុងក្រោយ ហើយសុខភាពរបស់គាត់បានធ្លាក់ចុះយ៉ាងខ្លាំង ដែលដោយសារកត្តាទាំងអស់នេះហើយ ទើបធ្វើឲ្យគាត់មិនអាចត្រូវឃុំឃាំងបន្តនៅក្នុងមន្ទីរឃុំឃាំងនៃតុលាការ ICTY បានឡើយ។ ទោះបីជា"ការពិតជាក់ស្តែងមិនអាចប្រកែកបាន" ថាស្ថានភាពរបស់ជនជាប់ចោទ នឹងកាន់តែទ្រុឌទ្រោមឡើងៗ ហើយនឹងឈានដល់មរណភាពក៏ដោយ[142] លក្ខខណ្ឌដ៏តឹងរឹងសម្រាប់ការដោះលែងត្រូវបានធ្វើឡើងដើម្បីធានាមួយផ្អែកថា គាត់នឹងមានវត្តមាននៅពេលអនាគតនៅក្នុងការជំនុំជម្រះ ក្នុងករណីដែលសឹងតែមិនអាចកើតឡើង ដែលថាគាត់បានជាសះស្បើយឡើងវិញ ហើយលក្ខខណ្ឌទាំងនោះរួមមាន "ត្រូវស្នាក់នៅ និងបន្តស្នាក់នៅគ្រប់ពេលនៅអាសយដ្ឋានមួយដែលស្ថិតក្នុងទីក្រុង Belgrade"

---

[140] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៦ យោងទៅលើ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Talic*, សំណុំរឿងលេខ IT-99-36-T, សេចក្តីសម្រេចលើសំណើសុំដោះលែងជាបណ្តោះអាសន្នរបស់ជនជាប់ចោទ Momir Talić, អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២("សេចក្តីសម្រេចលើរឿងក្តី*Talic*") កថាខណ្ឌ ៣២។

[141] នៅក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីជនជាប់ចោទ សុំការដោះលែង ដោយផ្អែកលើមូលដ្ឋានថាសុខភាពពុំមានលក្ខណៈសមស្របទៅនឹងការឃុំខ្លួន។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូង ICTY មិនបានធ្វើការសម្រេចអ្វីឡើយ លើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទពីកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងសហជនជាប់ចោទផ្សេងទៀត នៅថ្ងៃដោះលែងជនជាប់ចោទនោះ ហើយអង្គជំនុំជម្រះនេះមិនបានចាត់ការអ្វីឡើយនៅក្នុងសំណុំរឿងនេះ រហូតដល់ជនជាប់ចោទរូបនោះបានស្លាប់ ទើបសម្រេចបញ្ឈប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ។

[142] សេចក្តីសម្រេចលើ *រឿងក្តី Talic*, ទំព័រ ៦ ("ការពិតជាក់ស្តែងនៃស្ថានភាពសុខភាពរបស់ *Talic* គឺថាគាត់មិនអាចគេចផុតពីផលវិបាកជាទូទៅដែលជំងឺរបស់គាត់នឹងនាំមកឲ្យគាត់នោះទេ ពីព្រោះស្ថានភាពជំងឺ របស់គាត់មិនអាចព្យាបាលបាន និងមិនអាចវះកាត់បាន ហើយស្ថានភាពនេះចេះតែយ៉ាប់ទៅ ទោះជាមាន ឬគ្មានការព្យាបាលក៏ដោយ។ តាមការពិតជាក់ស្តែង អ្វីដែលសង្ឃឹមថាគាត់អាចរស់បានមួយឆ្នាំចាប់ពីពេលនេះទៅនោះគឺជាការសង្ឃឹមដ៏ស្តួចស្តើងបំផុត")។

"ត្រូវស្ថិតនៅក្នុងវិសាលភាពនៃរដ្ឋធានី Belgrade" និងត្រូវ "ទំនាក់ទំនងជាមួយមន្ត្រីនគបាលមូលដ្ឋានក្នុងរដ្ឋធានី Belgrade ម្តងក្នុងមួយថ្ងៃ ដែលការទំនាក់ទំនងនេះនឹងត្រូវបានចុះក្នុងបញ្ជី និងត្រូវធ្វើរបាយការណ៍នៅចុងខែនីមួយៗ"[143] ។ រឿងក្តីទាំងអស់នេះបង្ហាញថា ទោះបីជាក្នុងស្ថានភាពជនជាប់ចោទមានជំងឺក្នុងដំណាក់កាលចុងក្រោយក៏ដោយ ក៏មិនអាចធ្វើឱ្យជនជាប់ចោទរួចផុតពីយុត្តាធិការរបស់តុលាការបានដែរ។ រឿងក្តីទាំងអស់នេះក៏បញ្ជាក់ផងដែរពីការអនុវត្តការដាក់វិធានការដែលមានលក្ខណៈប្រហាក់ប្រហែល និងបណ្តាលវិធានការដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា។

47. ក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៃតុលាការតំបន់ Dili នៅប្រទេសទីម័រខាងកើត ក៏បានសម្រេចជ្រើសរើសយកការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងជនជាប់ចោទ Joseph Nahak[144] ដែលត្រូវបានរកឃើញថាមិនមានសម្បទាចូលរួមក្នុងសវនាការ ដោយសារតែបញ្ហារំខានខាងសតិ បញ្ញារបស់គាត់ ធ្វើឱ្យគាត់ក្លាយជា "មនុស្សដែលមានសមត្ថភាពតិចតួចបំផុត"[145] ។ ទោះបីជាមិនមានការបង្ហាញណាមួយដែលថា ជនជាប់ចោទអាចជាសះស្បើយ ហើយមានសម្បទាចូលរួមក្នុងសវនាការវិញក្នុងពេលអនាគតដែលអាចប្រមើលមើលឃើញក៏ដោយ ក៏ក្រុមប្រឹក្សាបានសង្កត់ធ្ងន់ថា ការសម្រេចត្រូវបានធ្វើឡើងក្នុងពេលវេលាជាក់លាក់មួយ ហើយការសម្រេចនេះអាចត្រូវធ្វើការកែប្រែដើម្បីឱ្យសវនាការអាចបន្តទៅមុខបាន ប្រសិនបើជនជាប់ចោទហាក់មានសម្បទាមិនគ្រប់ គ្រាន់តែក្នុងពេលបណ្តោះអាសន្នប៉ុណ្ណោះនោះ[146]។ ដោយផ្អែកលើមាត្រា ១៣៥(៤) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្រុមប្រឹក្សាបានសម្រេចថា "ភាពមិនមានសម្បទាក្នុងការចូលរួមសវនាការ មិនមែនជាការការពារខ្លួនដាច់ខាត់នោះឡើយ វាគ្រាន់តែជាការរារាំងតូចតាចមិនឱ្យមានការជំនុំជម្រះតែប៉ុណ្ណោះ។ វិធានបានចែងយ៉ាងច្បាស់ថា ជនជាប់ចោទដែលមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ត្រូវទទួលការត្រួតពិនិត្យឡើងវិញតាមកាលកំណត់ ហើយនឹងអាចត្រូវទទួលការ

---

143 សេចក្តីសម្រេចលើ *រឿងក្តី Talic,* ផ្នែកសម្រេចសេចក្តី។

144 *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង JosepNahak,* សំណុំរឿងលេខ 1A/2004 ក្រុមប្រឹក្សាពិសេសផ្នែកបទល្មើសកម្រិតធ្ងន់របស់តុលាការ Dili, សំអាងហេតុ និងដីកាសម្រេចលើសមត្ថភាពរបស់ចុងចោទ Nahak ដើម្បីចូលរួមក្នុងសវនាការ, ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០០៥, ("សេចក្តីសម្រេចលើ *រឿងក្តី Nahak"),* ទំព័រ ៥៤ និងកថាខណ្ឌ ១៥៥-១៥៨។

145 សេចក្តីសម្រេចលើ *រឿងក្តី Nahak* , កថាខណ្ឌ ១៥០-១៥១។

146 សេចក្តីសម្រេចលើ *រឿងក្តីត Nahak* , កថាខណ្ឌ ១៥៤, ១៥៧ និង "ដីកា"។

វិនិច្ឆ័យឡើងវិញផងដែរ។ ប្រសិនបើនៅពេលក្រោយ ក្រុមប្រឹក្សា "ជឿជាក់ថា ជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការឡើងវិញ" នៅពេលនោះ កិច្ចដំណើរការនីតិវិធីនឹងត្រូវបន្តធ្វើឡើងវិញ។ ក្រុមប្រឹក្សាបង្គាប់ឲ្យជនជាប់ចោទស្ថិតនៅក្រោមលក្ខខណ្ឌនៃការដោះលែងដោយស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលបានដាក់រួចហើយទៅលើជនជាប់ចោទ មុនពេលធ្វើការវាយតម្លៃលើសម្បទារបស់គាត់ ដែលលក្ខខណ្ឌទាំងនោះរួមមាន៖ (១) រាយការណ៍ទៅការិយាល័យនគរបាលដែលនៅជិតទីកន្លែងស្នាក់នៅរបស់ជនជាប់ចោទ (២) ជៀសវាងមិនធ្វើការទាក់ទង ឬគម្រាមកំហែងដល់ជនរងគ្រោះ ឬក្រុមគ្រួសារជនរងគ្រោះ (៣) ត្រូវស្នាក់នៅក្នុងប្រទេសទីម័រខាងកើត និង (៤) ត្រូវបង្ហាញខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាំងអស់[147]។

48. តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាតុលាការអន្តរជាតិដំបូងបង្អស់ដែលបានអនុម័តវិធានជាក់លាក់មួយចំនួនស្តីពីបញ្ហាសម្បទាដើម្បីចូលរួមសវនាការ។ តុលាការនេះហាក់ដូចជាបានប្រកាន់យក គោលជំហរមួយស្រដៀងទៅនឹងតុលាការ *មិនអចិន្ត្រៃយ៍* តាមរយៈការសម្រេច "ផ្អាក" កិច្ចដំណើរ ការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដែលពុំមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ "រហូតដល់ឧបសគ្គលែងមានអត្ថិភាព" និងពិនិត្យមើលសំណុំរឿងនេះឡើងវិញរៀងរាល់ ១២០ ថ្ងៃម្តង លើកលែងតែមានហេតុផលដើម្បីអនុវត្តផ្សេងពីនេះ[148]។ វិធាននានានៃតុលាការព្រហ្មទណ្ឌអន្តរជាតិពុំចែងអំពីដំណោះស្រាយពិសេសណាមួយ ចំពោះលទ្ធភាពនៃការពុំមានសម្បទាគ្រប់គ្រាន់ជា អចិន្ត្រៃយ៍ឡើយ។

---

[147] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Barros, Mendonca *និង* Nahak សំណុំរឿងលេខ 01/2004 ក្រុមប្រឹក្សាពិសេសផ្នែកបទល្មើសកម្រិតធ្ងន់របស់តុលាការ Dili, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យឃុំខ្លួនមុនជំណាក់ជំនុំជម្រះ, ថ្ងៃទី ១៧ ខែមីនាឆ្នាំ ២០០៤ កថាខណ្ឌ ៥។

[148] វិធាន ១៣៥(៤) នៃវិធានផ្ទៃក្នុងស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ចែងថា "នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ អង្គជំនុំជម្រះនឹងសម្រេចឲ្យផ្អាកសវនាការសិន។ ផ្អែកតាមការផ្តួចផ្តើមរបស់ខ្លួន ឬតាមសំណើរបស់រដ្ឋអាជ្ញា ឬមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យឡើងវិញលើរឿងក្តីរបស់ជនជាប់ចោទ។ នៅក្នុងគ្រប់ករណីទាំងអស់ រឿងក្តីនេះនឹងត្រូវពិនិត្យឡើងវិញរៀងរាល់ ១២០ ថ្ងៃ លើកលែងតែមានសំអាងហេតុដែល តម្រូវឲ្យអនុវត្តផ្សេងពីនេះ។ ប្រសិនបើក្នុងករណីចាំបាច់ អង្គជំនុំជម្រះអាចបង្គាប់ឲ្យត្រួតពិនិត្យបន្ថែមលើជនជាប់ចោទ។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការវិញនោះ អង្គជំនុំជម្រះនឹងអនុវត្តនីតិវិធីអនុលោមតាមវិធាន ១៣២"។ អង្គបុរេជំនុំជម្រះ I បានលើកឡើងថ្មីៗនេះ ថា នៅពេលដែលជនជាប់ចោទពុំមានសម្បទាក្នុងការចូលរួមសវនាការ៖ "ដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវតែផ្អាក

*ដំណោះស្រាយទីពីរ: "សាលក្រមពិសេស"*

49. ចក្រភពអង់គ្លេសបានបង្កើតនូវវិធីសាស្ត្រផ្សេងមួយ[149] ហើយត្រូវបានយកទៅអនុវត្តដោយ ប្រទេសជាច្រើនដែលប្រើអង់គ្លូសាក់សុង ដូចជានៅ ហុង កុង[150] ហ្សេមប៊ៀរ[151] និង ដោយមានការខុសប្លែកគ្នាខ្លះៗ នៅប្រទេសអូស្ត្រាលី[152] ដែលនៅទីនោះ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌលើជនជាប់ចោទ

---

រហូតដល់ពេលដែលមានឧបសគ្គអ្វីកើតមានឡើងទៀត" (*ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Laurent Gbagbo, សំណុំរឿង ICC-02/11-01/11, សេចក្តីសម្រេចលើសម្បទារបស់ Laurent Gbagbo ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការនេះ, អង្គបុរេជំនុំជម្រះ I, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៤៣)។

[149] នៅក្នុងចក្រភពអង់គ្លេស ដែលវិធីនេះត្រូវបានអនុម័តជាដំបូង បន្ទាប់មកពីមានការរកឃើញថាគ្មានសម្បទាគ្រប់គ្រាន់ចូលរួមសវនាការ (ជាអចិន្ត្រៃយ៍ ឬយ៉ាងណានោះ ពុំមានភាពខុសប្លែកគ្នាទេ) អង្គជំនុំជម្រះមិនត្រូវបន្តកិច្ចដំណើរការ និង គណៈវិនិច្ឆ័យត្រូវបានជ្រើសរើសដើម្បីសម្រេច ដែលហៅថា "សាលក្រមពិសេស" ប្រសិនបើជនជាប់ចោទ "បានប្រព្រឹត្ត អំពើសកម្ម ឬ អកម្មចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់"។ (ផ្នែក ៤ ក នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ជំងឺឆ្កួត) ឆ្នាំ ១៩៦៤)។ បន្ទាប់ពីបានរកឃើញថា ជនជាប់ចោទបានប្រព្រឹត្តនូវធាតុផ្សំជាសត្យានុម័តនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ មានដីកាសម្រេចផ្សេងៗត្រូវបានធ្វើឡើង រួមមានការបញ្ជូនទៅកាន់មន្ទីរពេទ្យ ដីកាចាត់តាំងអ្នកអាណាព្យាបាល ដីកាស្តីពីការត្រួតពិនិត្យ និងការព្យាបាល ឬការដោះលែងដោយឥតលក្ខខណ្ឌ (ផ្នែក ៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ជំងឺឆ្កួត) ឆ្នាំ ១៩៦៤)។

[150] ទីក្រុងហុងកុង ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ជំពូក ២២១ ផ្នែក ៧៥, ៧៦ និង ជំពូក ៤(៣) និង (៤) (ឆ្នាំ ២០០)។

[151] ក្រមនីតិវិធីព្រហ្មទណ្ឌ Zambia ជំពូក ៨៨ មាត្រា ១៦១ ដល់ ១៦៦។

[152] នៅក្នុងប្រទេសអូស្ត្រាលី ផ្អែកតាមផ្នែកទី ៦ នៃ*ក្រមព្រហ្មទណ្ឌ* (ប្រជាជនប្រទេសកូមិនវែល (Commonwealth)) ដែលអនុវត្តចំពោះបទល្មើសប្រឆាំងនឹងប្រជាជនប្រទេសទាំងនេះ ចែងថា ប្រសិនបើតុលាការយល់ឃើញថាជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ តុលាការត្រូវតែកំណត់ជាមុនថាតើ មាន ឬមិនមានភស្តុតាងបឋមដែលថា ជនជាប់ចោទបានប្រព្រឹត្តបទល្មើស។ ប្រសិនបើមានភស្តុតាងបឋម ហើយជនជាប់ចោទមិនទំនងជា អាច មានសម្បទាគ្រប់គ្រាន់ក្នុងរយៈពេលដប់ពីរខែនោះទេ តុលាការត្រូវតែ៖ (១) ឃុំចុងចោទនៅក្នុងមន្ទីរពេទ្យដើម្បីព្យាបាលជំងឺ; (២) ឃុំចុងចោទនៅក្នុងកន្លែងមួយដោយឫក្សរួមទាំងពន្ធនាគារ ប៉ុន្តែមិនមែននៅក្នុងមន្ទីរពេទ្យទេ; (៣) ដោះលែងចុងចោទដោយមានលក្ខខណ្ឌ ឬ (៤) ដោះលែងចុងចោទដោយគ្មានលក្ខខណ្ឌ។ ការដោះ លែងដោយមានលក្ខខណ្ឌ អាចសម្រេចដាក់ចុងចោទជាអតិបរមារយៈពេលបីឆ្នាំ និងការឃុំខ្លួន មិនអាចលើសពីថិរវេលានៃទោសអតិបរមាដែលត្រូវដាក់ក្នុងមន្ទីរឃុំឃាំង ក្នុងករណីដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសចំពោះបទល្មើសដែលចោទប្រកាន់។ (ក្រមព្រហ្មទណ្ឌកូមិនវែល ឆ្នាំ១៩១៤ ផ្នែក BA, BC, B6)។ របបគតិយុត្តិស្រដៀងគ្នានេះដែរ ត្រូវបានអនុវត្តនៅក្នុងរដ្ឋ Victoria ។ នៅក្នុងរដ្ឋ Victoria ប្រសិនបើចុងចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការនោះទេ ក្រោយពីសវនាការពិសេស (ដែលស្រដៀងគ្នានឹងការជំនុំជម្រះ) ក្រុមប្រឹក្សាវិនិច្ឆ័យអាចចេញសេចក្តីសម្រេចមួយក្នុង ចំណោមសេចក្តីសម្រេចទាំងបី៖ (១)មិនមានពិរុទ្ធភាពនៃបទល្មើសដែលត្រូវបាន ចោទប្រកាន់; (២) មិនមានពិរុទ្ធភាពនៃបទល្មើស ដោយសារតែការចុះខ្សោយខាងបញ្ញាស្មារតី; (៣) ជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ ឬបទល្មើសដែលអាចមានផ្សេងទៀត។ ប្រសិនបើក្រុមប្រឹក្សាវិនិច្ឆ័យសម្រេចចេញសេចក្តីសម្រេច(២) ឬ(៣) តុលាការត្រូវតែប្រកាសថា ជននោះត្រូវស្ថិតក្រោមការត្រួតពិនិត្យ(ក្រោមការបង្គាប់ឱ្យត្រួតពិនិត្យ

ដែលពុំមានសម្បទា (ទោះបី ជាអចិន្ត្រៃយ៍ ឬយ៉ាងណានោះ ក៏ ជាទូទៅ ពុំមានភាពខុសប្លែកគ្នានោះទេ) ត្រូវបានបន្តដំណើរការដល់ទីបញ្ចប់ ដោយបានការអនុញ្ញាតឱ្យតុលាការ ឬគណៈវិនិច្ឆ័យ សម្រេចថា តើជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែរ ឬយ៉ាងណា (ឬយ៉ាងហោចណាស់ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋនោះ (*actus reus*)។ ជាវិជ្ជមាន តុលាការព្រហ្មទណ្ឌមានសមត្ថកិច្ចដើម្បីបង្គាប់ឱ្យមានវិធានការមួយចំនួន ដែលជាទូទៅរួមមាន ការបញ្ជូនជនជាប់ចោទទៅស្ថាប័នសុខភាពផ្លូវចិត្ត ឬពន្ធនាគារមួយ (ដើម្បីទទួលការព្យាបាល ឬពុំដើម្បីទទួលការព្យាបាល) ការចាត់តាំងអាណាព្យាបាលមួយរូប ឬរបបការពារប្រហាក់ប្រហែល ការដោះលែងដោយមានលក្ខខណ្ឌ ឬដោយឥតលក្ខខណ្ឌ។ ជម្រើសចុងក្រោយនៃការដោះលែងដោយឥតលក្ខខណ្ឌ ត្រូវបានបដិសេធចោលយ៉ាងជាក់ច្បាស់សម្រាប់បទល្មើសធ្ងន់ធ្ងរ ដូចជាមនុស្សឃាតនៅក្នុងចក្រភពអង់គ្លេស[153]។ ដរាបណាធ្វើការពិចារណាទៅលើច្បាប់របស់ចក្រភពអង់គ្លេស វិធានការទាំងនេះ ត្រូវបានចាត់ទុកថា ជាមធ្យោបាយមួយក្នុងការធានានូវការការពារដល់សាធារណជនប្រឆាំងនឹងបុគ្គល ដែលត្រូវបានចាត់ទុកថាជាបុគ្គលមានគ្រោះថ្នាក់ដោយសារអំពើរបស់ខ្លួន ជាជាងការដាក់ទោស[154]។ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវបានផ្អាកដោយពុំមានពេលវេលាកំណត់ ប៉ុន្តែមានលទ្ធភាពមួយសម្រាប់ភាគីអយ្យការដើម្បីធ្វើឱ្យកិច្ច

---

ដោយមិនឃុំខ្លួន ឬការឃុំខ្លួនក្នុងកន្លែងមួយ) ឬដោះលែងជននោះដោយគ្មានលក្ខខណ្ឌ។ ដីកាបង្គាប់ឱ្យត្រួតពិនិត្យ គឺមិនមានរយៈពេលកំណត់នោះទេ ប៉ុន្តែ អាស្រ័យលើការពិនិត្យមើលជាប្រចាំឆ្នាំ និងការពិនិត្យមើលឡើងវិញទៅលើចំណុចសំខាន់នៅចុងបញ្ចប់នៃ "ការផ្តន្ទាទោសជានិមិត្តរូប" (ថិរវេលាកំណត់ដោយតុលាការ ផ្អែកលើការផ្តន្ទាទោសដែលចុងចោទត្រូវទទួល ប្រសិនបើចុងចោទត្រូវរកឃើញថាមានពិរុទ្ធ)។ សូមមើលផ្នែក ១៧-១៨ និង ២៦-២៨ នៃក្រមព្រហ្មទណ្ឌ (ភាពចុះខ្សោយខាងសតិស្មារតី និងភាពមិនមានសម្បទាគ្រប់គ្រាន់ដើម្បីទទួលបានការជំនុំជម្រះ)។

[153] ចក្រភពអង់គ្លេស ផ្នែកទី ៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ជំងឺឆ្កួត) ឆ្នាំ ១៩៦៤។

[154] សភាជាន់ខ្ពស់បានបញ្ជាក់ថា "សេចក្តីសម្រេចពិសេស" មិនមានពាក់ព័ន្ធនឹងការកំណត់អំពីការចោទប្រកាន់អំពីបទព្រហ្មទណ្ឌនោះទេ ដោយសារតែក្រុមប្រឹក្សាវិនិច្ឆ័យ មានអំណាចសម្រេចឱ្យរួចខ្លួន ប៉ុន្តែក្រុមប្រឹក្សាវិនិច្ឆ័យមិនមានអំណាចផ្តន្ទាទោសនោះទេ។ នីតិវិធីមិនអាចនាំឱ្យមានការដាក់ទណ្ឌកម្មនោះទេ។ (*រឿងក្តី R. v. H* និងរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការក្នុងប្រទេស, សេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៣ ត្រង់កថាខណ្ឌ ១៦ និង ១៨, តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្សបានយោងទៅលើសេចក្តីសម្រេចលើ*រឿងក្តី Antoine* ទំព័រ ៥-៦)។ តុលាការអឺរ៉ុបលើកឡើងបន្ថែមថា គោលបំណងសំខាន់នៃកិច្ចដំណើរការនីតិវិធីទាំងនេះ "គឺដើម្បីពិចារណាថាតើអ្នកដាក់ពាក្យសុំ បានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តនូវអំពើណាមួយ ដែលភាពគ្រោះថ្នាក់នៃអំពើនោះ តម្រូវឱ្យមានដីកាបង្គាប់ឱ្យចូលសម្រាកនៅមន្ទីរពេទ្យ ដើម្បីជាប្រយោជន៍ក្នុងការការពារសាធារណជន"។

ដំណើរ ការនីតិវិធីទាំងនេះមានដំណើរការឡើងវិញ[155]។ តាមទស្សនៈរបស់តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប កិច្ចដំណើរការនីតិវិធី "ត្រូវបានបញ្ចប់ដោយមើលទៅលើគោលបំណងជាក់ស្តែង" ហើយពុំអាចចាត់ទុកថាការចោទប្រកាន់ទាំងប៉ុន្មាន នៅត្រូវរង់ចាំការសម្រេចពីតុលាការឡើយ បើទោះបីជាតាមទ្រឹស្តី ភាគីអយ្យការមានលទ្ធភាពធ្វើឱ្យសំណុំរឿងនេះមានដំណើរការឡើងវិញក៏ដោយ[156]។ ក៏ប៉ុន្តែ ស្ថានភាពមានលក្ខខណៈខុសប្លែកបន្តិចនៅក្នុងប្រទេស អូស្ត្រាលី ដែលជនជាប់ចោទ នៅពេលដែលត្រូវបានផ្ទេរទៅមន្ទីរសុខភាពផ្លូវចិត្ត ឬទីកន្លែងសមស្របមួយទៀត ដូចជាពន្ធនាគារ ត្រូវបានចាត់ទុកថា បានអនុវត្តទោសអប្បបរមា ដូច្នេះតុលាការបង្គាប់ឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍[157]។

***ដំណោះស្រាយទីបី៖ ការអនុញ្ញាតឲ្យមានលទ្ធភាពនៃការបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ដោយសារ ជនជាប់ចោទពុំមានសម្បទាគ្រប់គ្រាន់ជាអចិន្ត្រៃយ៍***

50. រដ្ឋមួយចំនួនតូច បានអនុម័តបញ្ញត្តិជាក់លាក់នៅក្នុងច្បាប់របស់ពួកគេ ដើម្បីដោះស្រាយចំពោះស្ថានភាពជាក់លាក់ ដែលជនជាប់ចោទត្រូវបានសម្រេចថា ពុំមានសម្បទាគ្រប់ គ្រាន់ជាអចិន្ត្រៃយ៍ ដើម្បីចូលរួមសវនាការ និងអនុញ្ញាតឲ្យមានលទ្ធភាពបញ្ចប់កិច្ចដំណើរការ នីតិវិធីព្រហ្មទណ្ឌ។ ការបញ្ចប់កិច្ចដំណើរការនីតិវិធីដោយមានការបញ្ចប់នូវយុត្តាធិការលើជនជាប់ចោទផងនោះ មានចែងនៅក្នុង

---

[155] ចក្រភពអង់គ្លេស ជំពូក ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ(វិកលចរិក និងភាពមិនមានសម្បទាដើម្បីចូលរួមសវនាការ) ឆ្នាំ ១៩៩១ កថាខណ្ឌ ៤(១) ។

[156]សេចក្តីសម្រេចលើ *រឿងក្តី Antoine* (នៅក្នុងសំណុំរឿងនេះ "សេចក្តីសម្រេចពិសេស" បានសម្រេចថាអ្នកដាក់ពាក្យសុំ ដែលមានជំងឺសសៃប្រសាទឆ្កួត (paranoid schizophrenia) បានប្រព្រឹត្តនូវអំពើមនុស្សឃាតដែលត្រូវបានគេចោទប្រកាន់ ដូចនេះ កិច្ចដំណើរការនីតិវិធីត្រូវតែ "ផ្អាកមិនមានពេលកំណត់" ហើយជនជាប់ចោទត្រូវតែបញ្ជូនទៅកាន់មន្ទីរពេទ្យព្យាបាល។ អ្នកដាក់ពាក្យសុំ ត្រូវបានចោទប្រកាន់ចំពោះការរំលោភបំពាន *ក្នុងចំណោមមាត្រាផ្សេងៗទៀត* មាត្រា ៦(១) នៃអនុសញ្ញាអ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស (សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប) ដោយផ្អែកលើមូលដ្ឋានថា បទចោទប្រកាន់លើរូបគាត់ មិនទាន់ត្រូវបានសម្រេចនៅឡើយ។ តុលាការយល់ឃើញថា ពាក្យបណ្តឹង មិនអាចទទួលយកបាន ដោយផ្អែកលើសំអាងហេតុថា តាមទ្រឹស្តី ទោះបីជារដ្ឋមន្ត្រីការបរទេស អាចយល់ឃើញថា អ្នកដាក់ពាក្យសុំមានសម្បទា គ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ និងចាប់ផ្តើមឡើងវិញនូវកិច្ចដំណើរការនីតិវិធី ករណីបែបនេះនឹងមិនអាចកើតមាននោះទេ។

[157] ក្រមព្រហ្មទណ្ឌអូស្ត្រាលី (Commonwealth) ផ្នែក ២០(BC)(8)។

ច្បាប់នៃប្រទេស កាណាដា និង ស៊ែបៀរ[158]។ ប៉ុន្តែ នៅប្រទេសកាណាដា មិនអាចប្រព្រឹត្តទៅដោយស្វ័យប្រវត្តិនោះទេ ហើយតម្រូវឱ្យមានការសម្រេចពីតុលាការថា ជនជាប់ចោទ ពិតជាមិនបង្កគ្រោះថ្នាក់ដល់សាធារណជន ហើយថា ការសម្រេចនេះ គឺដើម្បីប្រយោជន៍នៃយុត្តិធម៌ ដោយធ្វើការពិចារណាទៅលើផលប្រយោជន៍ក្នុងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់[159]។ នៅក្នុងប្រទេសដទៃទៀត ដូចជានៅ ប្រទេសស៊ីលី[160] កូសូវ៉ូ[161] លីបេរីយ៉ា[162] សៀរ៉ា

[158] នៅប្រទេស Serbia សវនាការអាចត្រូវបានលើកពេលទៅថ្ងៃជាក់លាក់ណាមួយនៅពេលដែលជនជាប់ចោទមិនមានសម្បទាគ្រប់គ្រាន់ជាបណ្ដោះអាសន្នក្នុងការចូលរួមសវនាការ។ ប្រសិនបើភាពមិនប្រក្រតី និងពិការភាពផ្នែកផ្លូវចិត្ត មានភាពអចិន្ត្រៃយ៍ នោះត្រូវលើកលែងការចោទប្រកាន់ (ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេស Serbia (២០១១) មាត្រា ៣៨៧ និង ៤១៦)។

[159] នៅប្រទេសកាណាដា ពេលថ្មីៗ បានបន្ថែមទៅលើនីតិបញ្ញត្តិរបស់ខ្លួននូវលទ្ធភាពនៃការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ចំពោះជនជាប់ចោទ ដែលទំនងជាមិនមានសម្បទាគ្រប់គ្រាន់ចូលរួមសវនាការ ប្រសិនបើ នេះគឺជាប្រយោជន៍យុត្តិធម៌ជាការឆ្លើយតបទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្ដី R. v. Demers*។ អនុលោមតាមវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌសាលក្រមស្ដីពីការគ្មានសម្បទាគ្រប់គ្រាន់ ក្នុងការចូលរួមសវនាការអាចធ្វើឱ្យផ្អាកដំណើរការនីតិវិធី (ដែលស្មើនឹងការបញ្ឈប់បណ្ដឹងអាជ្ញា និងតម្រូវឱ្យដោះលែងដោយគ្មានលក្ខខណ្ឌ) ប្រសិនបើតុលាការជឿថា ក. ជនជាប់ចោទទំនងជានឹងមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ខ. ជនជាប់ចោទមិនបង្កជាការគំរាមកំហែង ខ្លាំងចំពោះសុវត្ថិភាពសាធារណៈ និង គ. ការផ្អាកដំណើរការនីតិវិធីផ្ដល់ជាប្រយោជន៍ចំពោះរដ្ឋបាលតុលាការដ៏ត្រឹមត្រូវ។ ដើម្បី កំណត់ថាតើការផ្អាកដំណើរការនីតិវិធីផ្ដល់ជាប្រយោជន៍ចំពោះរដ្ឋបាលតុលាការដ៏ត្រឹមត្រូវ តុលាការត្រូវពិចារណាទៅលើ ចំណុចមួយចំនួនក្នុងនោះរួមទាំង លក្ខណៈ និងភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានចោទ និងឥទ្ធិពលជាអវិជ្ជមាននៃការផ្អាក ដំណើរការនីតិវិធី។ (ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសកាណាដាផ្នែក ៦៧២.៨៥១ (៧) ដល់ (៨) នៃ)។

[160] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសស៊ីលីបានបែងចែងជំងឺដែលអាចព្យាបាលបាន និងមិនអាចព្យាបាលបានដែលបណ្ដាលឱ្យមានការគ្មានសម្បទាន។ ក្នុងករណីជំងឺអាចព្យាបាលបានត្រូវមានការផ្អាកដំណើរការនីតិវិធីប៉ុន្តែចំពោះករណីមានជំងឺដែលមិនអាចព្យាបាលបានត្រូវមានការលើកលែងការចោទប្រកាន់។ ជនជាប់ចោទត្រូវទទួលការដោះលែងដោយឥតលក្ខខណ្ឌ ប្រសិនបើការផ្ដល់សេរីភាពឱ្យគាត់មិនបង្កជាការគំរាមដល់ខ្លួនគាត់ និងអ្នកដទៃទេនោះ បើមិនដូច្នេះទេ តុលាការនឹងបញ្ជូនរឿងក្ដីនេះទៅអាជ្ញាធរផ្នែកសុខាភិបាលដែលពាក់ព័ន្ធដើម្បីចាត់វិធានការបន្ត (ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសស៊ីលីមាត្រា ៦៨៦)។

[161] នៅកូសូវ៉ូ ប្រសិនបើការគ្មានសម្បទាកើតឡើងដោយសារតែបញ្ហាសុខភាពបណ្ដោះអាសន្ន "ត្រូវផ្អាកការស៊ើបអង្កេត ឬថាសវនាការសំខាន់នឹងត្រូវផ្អាក"។ ប្រសិនបើជនជាប់ចោទគ្មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដោយសារតែបញ្ហាសុខភាពផ្លូវចិត្តជាអចិន្ត្រៃយ៍ តុលាការត្រូវចេញសេចក្ដីសម្រេចមួយបញ្ឈប់ដំណើរការនីតិវិធី ប៉ុន្តែដំណើរការនីតិវិធីអាចបន្តឡើងវិញនៅពេលរដ្ឋអាជ្ញាស្នើឡើងប្រសិនបើមានសំអាងហេតុក្នុងការលែងត្រូវបញ្ឈប់ដំណើរការនីវិតិធីទៀតហើយ"។ ក្នុងករណីទាំងពីរនេះតុលាការអាចស្នើឱ្យមានការផ្ដួចផ្ដើមដំណើរការនីតិវិធីនាពេលក្រោយទៀត ដោយផ្អែកទៅលើស្ថាប័នសុខាភិបាលនៅក្រោមច្បាប់ស្ដីពីការមិនបន្តនីតិវិធី ប្រសិនបើមានមូលដ្ឋានឱ្យជឿថាជនជាប់ចោទនឹងបង្កជាគ្រោះថ្នាក់ដល់ជីវិត ឬសុខភាពអ្នកណាមួយ។ (បទបញ្ជាលេខ ២០០៤/៣៤ ស្ដីពីដំណើរការនីតិវិធីព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងចារីដែលមានបញ្ហាខាងផ្លូវចិត្ត ដែលត្រូវ

ឡេអូន[163] និង តង់ហ្សានៀ[164] ការបញ្ចប់កិច្ចដំណើរការនីតិវិធី ជាទូទៅ ជាប់ពាក់ព័ន្ធទៅនឹងលទ្ធភាពនៃសកម្មភាពកើតមានពេលអនាគត តាមលក្ខន្តិកៈនៃសុខភាពផ្លូវចិត្ត ដូចជា សកម្មភាពកើតមាននៅក្នុងមន្ទីរសុខភាពផ្លូវចិត្ត។

51. ការបញ្ចប់កិច្ចដំណើរការនីតិវិធី ទោះបីជាមិនមានលក្ខណៈប្រព្រឹត្តទៅដោយស្វ័យប្រវត្តិក៏ដោយ ក៏ដំនងជាអាចកើតមាននៅក្នុង សហរដ្ឋអាមេរិក ប្រសិនបើកាលៈទេសៈនៃរឿងក្តីនេះសមស្រប។ នៅក្នុងកម្រិតរដ្ឋសហព័ន្ធ ការបញ្ចប់កិច្ចដំណើរការនីតិវិធី ពុំមានចែងច្បាស់លាស់នៅក្នុងច្បាប់ ដែលអនុញ្ញាតការបញ្ជូនជនជាប់ចោទដែលមិនមានសម្បទាចូលរួមសវនាការទាំងអស់ ទៅស្ថាប័នឡើយ "រហូតដល់ពេលជនជាប់ចោទមានសមត្ថភាពខាងបញ្ញាស្មារតីដើម្បីចូលរួមក្នុងសវនាការ ឬរហូតដល់ ពេលបទចោទប្រឆាំងនឹងជនជាប់ចោទដែលរង់ចាំការកាត់សេចក្តី ត្រូវបានដោះស្រាយរួចរាល់ដោយ អនុលោម

---

បានអនុវត្តដោយបេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់ អង្គការសហប្រជាជាតិនៅកូសូវ៉ូ។ មាត្រា ៩.១ ដល់ ៩.៤ ក្រមនីតិវិធីព្រហ្មទណ្ឌបណ្តោះអាសន្ននៅកូសូវ៉ូមាត្រា ១០៣ (៣)។

[162] នៅប្រទេសលីបេរីយ៉ា ប្រសិនបើតុលាការយល់ថា ពេលវេលាបានកន្លងផុតច្រើនណាស់ទៅហើយចាប់តាំងពីការ បញ្ជូនជនជាប់ចោទដែលអសមត្ថភាព ហើយការបន្តនីតិវិធីព្រហ្មទណ្ឌនឹងមិនមានភាពយុត្តិធម៌ នោះត្រូវលើកលែងការចោទប្រកាន់។ បន្ទាប់មក ជនជាប់ចោទត្រូវបានដោះលែង ឬប្រសិនបើស្ថានភាពផ្លូវចិត្តរបស់គាត់តម្រូវ ត្រូវបញ្ជូនគាត់ទៅកាន់ស្ថាប័នសមស្រប (ច្បាប់នីតិវិធីព្រហ្មទណ្ឌប្រទេសលីបេរីយ៉ា ឆ្នាំ ១៩៦៩ មាត្រា ៦.៣)។

[163] នៅក្នុងប្រទេសសៀរ៉ាឡេអូន បន្ទាប់ពីមានចេញលិខិតបញ្ជាក់ដោយអាជ្ញាធរ ឬអ្នកអនុវត្តវិជ្ជាជីវៈដែលបានកំណត់ ដែលថា "ស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទនឹងត្រូវរងគ្រោះថ្នាក់ដោយសារតែសវនាការ នោះដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទនឹងមិនត្រូវបន្តឡើយ បើសិនជារដ្ឋអាជ្ញាមិនជូនដំណឹងទៅតុលាការថា គាត់យល់ថាជាប្រយោជន៍សាធារណៈក្នុងការបន្តនីតិវិធី" (ច្បាប់នីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៨ (១))។ បន្ទាប់ពីការផ្អាកនីតិវិធី ជនជាប់ចោទត្រូវរួចពីការចោទប្រកាន់ ហើយដូច្នេះ ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិច្បាប់ផ្នែកសុខភាពផ្លូវចិត្ត "ក្នុងកម្រិតមួយដែលថា អ្នកជំងឺផ្លូវចិត្តមិនត្រូវស្ថិតនៅក្រោមដំណើរការ នីតិវិធីផ្លូវច្បាប់ឡើយ" (ច្បាប់នីតិវិធីព្រហ្មទណ្ឌប្រទេសសៀរ៉ាឡេអូន មាត្រា ៧៨(២))។

[164] នៅ Tanzania ពុំមានបទប្បញ្ញត្តិជាក់លាក់សម្រាប់ជនជាប់ចោទដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ចូលរួមសវនាការ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីលទ្ធភាពក្នុងការចោទប្រកាន់ ដើម្បី"បញ្ចប់"បទចោទប្រកាន់ដែលជាលទ្ធផលមួយថា ជនជាប់ចោទ មានសិទ្ធិទទួលបានការដោះលែងដោយឥតលក្ខខណ្ឌ ឬ "លើកលែងបទចោទប្រកាន់"បទល្មើសព្រហ្មទណ្ឌ និងដោះស្រាយតាមច្បាប់ស្តីពីជំងឺបញ្ញាស្មារតី។ មានលទ្ធភាពក្នុងការធ្វើបណ្តឹងអាជ្ញាឡើងវិញ។ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០២ មាត្រា ២១)។

តាមច្បាប់"[165]។ ដើម្បីឲ្យស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់នេះត្រូវបានបកស្រាយថា ក្នុងករណីដែលជនជាប់ចោទដែលមិនមានសម្បទាខាងបញ្ហាស្មារតីក្នុងការចូលរួមសវនាការ និងត្រូវបានរកឃើញថា ពុំមានលទ្ធភាពក្នុងការទទួលបានសម្បទាគ្រប់គ្រាន់នាពេលអនាគត និង ត្រូវបានរកឃើញថា ពុំមានបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាធារណៈ រដ្ឋត្រូវផ្តួចផ្តើមដំណើរការនីតិវិធីបញ្ជូនផ្នែករដ្ឋប្បវេណី តាមច្បាប់ដែលអាចអនុវត្តចំពោះពលរដ្ឋទាំងអស់ ឬត្រូវដោះលែងជនជាប់ចោទ[166]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី Jackson v. Indiana លើកឡើងថា ការបញ្ចប់កិច្ចដំណើរការនីតិវិធី អាចជាជម្រើសអាស្រ័យលើកាលៈទេសៈនៃរឿងក្តី[167]។ ជម្រើសនេះ មានចែងយ៉ាងច្បាស់លាស់នៅក្នុងនីតិបញ្ញត្តិនៃរដ្ឋមួយចំនួន ដែលតុលាការ ត្រូវបានផ្តល់ឱ្យនូវអំណាចឆន្ទានុសិទ្ធិក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដែលប្រឈមនឹងលទ្ធភាពតិចតួចក្នុងទទួលនូវការជំនុំជម្រះ[168]។ ប៉ុន្តែ ការ

---

[165] 18 U.S.C. ss 4244 to 4246. រដ្ឋជាច្រើននៅសហរដ្ឋអាមេរិក បានអនុវត្តបញ្ញត្តិស្រដៀងគ្នានេះ (*សូមមើលរឿងក្តី Jackson តទល់នឹង Indiana*, 406 U.S. 715, 738 (1972), ("សាលដីកាលើ *រឿងក្តី Jackson* ") ទំព័រ ១២)។

[166] សាលក្រមលើ*រឿងក្តី Jackson* នៅត្រង់ទំព័រ ៧៣៨: "ជាលទ្ធផល យើងបានសម្រេចថា ជនម្នាក់ដែលរដ្ឋបានចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋ ហើយត្រូវបានសម្រេចបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដោយផ្អែកលើមូលដ្ឋានតែមួយគត់គឺការគ្មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី នឹងមិនត្រូវបានឃុំខ្លួនឲ្យលើសពីរយៈពេលដែលសមស្របសម្រាប់ការសម្រេចថាតើនឹងមានលទ្ធភាពច្បាស់លាស់ដែរ ឬទេថា ជននោះនឹងទទួលបានសម្បទាគ្រប់គ្រាន់ឡើងវិញក្នុងពេលជាក់លាក់នាថ្ងៃខាងមុខ។ ក្នុងករណីដែលមានការសម្រេចថា ជននេះនឹងពុំមានលទ្ធភាពបែបនេះទេ រដ្ឋចាំបាច់ត្រូវតែអនុវត្តដំណើរការនីតិវិធីជាទំនៀមទម្លាប់ក្នុងការបញ្ជូនជននោះទៅព្យាបាលនៅមន្ទីរពេទ្យដែលតម្រូវឲ្យធ្វើការព្យាបាលដោយគ្មានពេលវេលាកំណត់ចំពោះជនគ្រប់រូប ឬក៏រដ្ឋចាំបាច់ត្រូវតែធ្វើការដោះលែងជនជាប់ចោទ"។

[167] សាលក្រមលើ*រឿងក្តី Jackson នៅទំព័រ* ៧៤០ (ផ្តល់ជាយោបល់ថា ការលើកលែងបទចោទប្រឆាំងនឹងជនជាប់ចោទគ្មានសម្បទា អាចត្រូវតម្រូវទៅតាមវិសោធនកម្មលើកទី ៦ និង ១៤ ស្តីអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស ឬការបដិសេធនៃកិច្ចដំណើរការទាន់ពេល)។

[168] ឧទាហរណ៍ នៅក្នុងរឿងក្តីសហព័ន្ធក្រុងញូវយ៉កដែលបានពិចារណាទៅលើជនជាប់ចោទស្ថិតនៅក្នុងមន្ទីរឃុំឃាំង ដែលបានបាត់បង់សមត្ថភាពខាងស្មារតី និងមិនមានសម្បទាជាអចិន្ត្រៃយ៍ដើម្បីចូលរួមក្នុងសវនាការនោះ តុលាការបានតម្រូវឲ្យដោះលែង ប៉ុន្តែបានលើកឡើងថា៖ "តុលាការនេះមិនបានអះអាងនៅក្នុងលក្ខខណ្ឌទូទៅ ដើម្បី "ច្រានចោល" ឬលើសពីនេះទៀតលុបចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ប្រសិនបើរដ្ឋអាចធានានាំម្ចាស់ប្តឹងមកធ្វើការជំនុំជម្រះ សេចក្តីសម្រេចថ្ងៃនេះមិនមានបំណងលុបបំបាត់ការអះអាងរបស់រដ្ឋអាជ្ញាដែលថា ដំណើរការនីតិវិធីបែបនេះស្របទៅនឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដែលឆាប់រហ័សនោះទេ (ទោះបីជាអាចមើល ឃើញថាវាមិនឈ្នះការអះអាងនេះយ៉ាងណាក៏ដោយ)។ *U.S. ex rel. von Wolfersdorf តទល់នឹង Johnston*, 317 F.Supp. 66, S.D.N.Y(១៩៧០)។ *សូមមើល រឿងក្តី Greenwood ទល់នឹង U.S.*, 350 U.S. 366, 375, (1956) (ទទួលស្គាល់ថា ស្ថានភាពបច្ចុប្បន្ននៃចំណេះដឹង វិធីព្យាបាលជំងឺទាក់ទងទៅនឹងបញ្ហាបញ្ញាស្មារតី

បញ្ចប់នេះ មិនអាចប្រព្រឹត្តិទៅដោយស្វ័យប្រវត្តិនោះបានទេ[169] ហើយនៅតែអាចកើតមានដដែល យ៉ាងហោចណាស់នៅក្នុងរដ្ឋមួយចំនួន ដើម្បីដាក់វិធានការមួយចំនួនលើការដោះលែង ក្នុងករណីដែលមានលក្ខណៈសមស្របទៅតាមរឿងក្តី[170]។ ភាពបទប៉ៃនៃរដ្ឋសហព័ន្ធរបស់អាមេរិក និងតុលាការក្នុងការ

---

គឺថា វិទ្យាសាស្ត្រមិនអាចឈានដល់ការបញ្ចប់នៃសាលក្រម ដោយសារជាប់ពាក់ព័ន្ធទៅនឹងការជាសះស្បើយ និងភាពអចិន្ត្រៃយ៍នៃអសមត្ថភាព និងសម្រេចថា លទ្ធភាពតិចតួចក្នុងការធូរស្បើយឡើងវិញរបស់ជនជាប់ចោទដែលគ្មានសម្បទានោះ មិនបានរារាំងដល់អំណាចរបស់រដ្ឋសហព័ន្ធក្នុងការចោទប្រកាន់ឡើយ)។

[169] សូមមើល ឧទាហរណ៍ លក្ខន្តិកៈ Alaska § 12.47.100 (ឆ្នាំ 2012) (ចែងពីការលើកលែងបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទដែលគ្មានសម្បទាជាអចិន្ត្រៃយ៍ ហើយបង្គាប់ដល់ស្ថាប័ននៃនីតិវិធីស្តីពីការអនុវត្តរដ្ឋប្បវេណី ដោយអនុលោមតាម AS §§ 47.30.700 – 47.30.915); លក្ខន្តិកៈ Idaho § 18-212 (ឆ្នាំ 2000) (អនុញ្ញាតឱ្យតុលាការលើកលែងបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទគ្មានសម្បទា ប្រសិនបើតុលាការសម្រេចថា "ពេលវេលាបានកន្លងទៅយ៉ាងយូរ (...) ចាប់តាំងពីការបញ្ជូនជនជាប់ចោទ ដែលមានភាពមិនយុត្តិធម៌ក្នុងការបន្តកិច្ចដំណើរការនីតិវិធី")។ លក្ខន្តិកៈ Hawaii ដែលបានធ្វើវិសោធនកម្ម § 705-406 (ឆ្នាំ 2001) (ផ្តល់អំណាចដល់តុលាការក្នុងការលើកលែងបទចោទប្រឆាំងនឹង ជនជាប់ចោទ ដែលខ្វះសមត្ថភាព ដើម្បីប្រយោជន៍យុត្តិធម៌) ។ លក្ខន្តិកៈ New Jersey ដែលបានធ្វើវិសោធនកម្ម § 2C: 4-6 (ឆ្នាំ 2012) (តម្រូវឱ្យតុលាការបើកសវនាការសម្រេចថា តើ ត្រូវលើកលែងបទចោទ ឬ ផ្អាក ដោយហេតុថា ជនជាប់ចោទដែលគ្មានសម្បទា មិនអាចទទួលបានសមត្ថភាពឡើងវិញទេនៅក្នុងរយៈពេលបីខែនៃការបញ្ជូនដែលបង្គាប់ដោយតុលាការ)។

[170] នេះជាសំណុំរឿងក្តីនៅទីក្រុង Illinois។ *រឿងក្តី People ទល់នឹង Ealy*, 365 NE 2d 149, តុលាការឧទ្ធរណ៍នៅទីក្រុង Illinois, 1st Dist. ( ឆ្នាំ ១៩៧៧), ទំព័រ ១២ (ការពិភាក្សាពីការជំនុំជម្រះ *រឿងក្តី Jackson*: "តើ *រឿងក្តី Jackson តទល់នឹង Indiana* ត្រូវការលក្ខខណ្ឌ អ្វីខ្លះ? តើរឿងក្តីនេះតម្រូវឱ្យមានការដោះលែងជនជាប់ចោទឬ - ដោះលែងភ្លាមៗ ឬដោយឥតលក្ខខណ្ឌ ឬក៏ដោះលែងដោយអនុលោមតាមបញ្ញត្តិច្បាប់ក្នុងផ្នែក ៥-២-២ និងលក្ខខណ្ឌនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ? ផ្នែក ៥-២-២ ធ្វើការបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទដែលពុំមានសម្បទា ហើយមិនទាន់បានបញ្ជូនទៅកាន់កន្លែងព្យាបាល អាចត្រូវបានដោះលែង ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬត្រូវគោរព' លក្ខខណ្ឌដែលតុលាការយល់ឃើញថាសមស្រប ដែលអាចរួមបញ្ចូល តែមិនកំណត់ត្រឹមតែតម្រូវឱ្យជនជាប់ចោទត្រូវបញ្ជូនទៅ ឬធានាឱ្យមានការព្យាបាលជំងឺផ្លូវចិត្ត (...)។ តាមការយល់ឃើញរបស់យើង *រឿងក្តី Jackson តទល់នឹង Indiana* មិនបានហាមឃាត់អង្គជំនុំជម្រះសាលាដំបូងមិនឱ្យពិចារណាលើផ្នែក ១១០-៥(ក) និង ១១០-១០(ក) ក្នុងការសម្រេចពីលក្ខខណ្ឌដែលត្រូវយកមកប្រើប្រាស់ដើម្បីដោះលែងជនជាប់ចោទ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ")ឡើយ។ សូមមើល លក្ខន្តិកៈ Hawaii ដែលបានធ្វើវិសោធនកម្ម § 705-406 (ឆ្នាំ 2001) (អនុញ្ញាតការដោះលែងជនជាប់ចោទដែលគ្មានសម្បទា "សំអាងលើលក្ខខណ្ឌដែលតុលាការសម្រេចថាចាំបាច់"); ក្រម Iowa § 812.6 (ឆ្នាំ 2001) (អនុញ្ញាតឱ្យតុលាការតម្រូវឱ្យជនជាប់ចោទដែលគ្មានសម្បទាទទួលការព្យាបាលសុខភាពផ្លូវចិត្តដែលអាចត្រឡប់ទៅផ្ទះវិញបាន ថាជាលក្ខខណ្ឌនៃការដោះលែង) ។ ក្រម Virginia § 19.2-169.3 (ឆ្នាំ 2009) (ផ្តល់អំណាចដល់តុលាការ ក្នុងការជ្រើសតាំងអ្នកអាណាព្យាបាលតាមច្បាប់សម្រាប់ជនជាប់ចោទដែលគ្មានសម្បទា ថាជាលក្ខខណ្ឌនៃការដោះលែង), *សូមមើលផងដែររឿងក្តី People ទល់នឹង Lang*, 391 N.E.2d 350, 352, តុលាការឧទ្ធរណ៍នៅទីក្រុង Illinois (ឆ្នាំ 1979): ("ប្រសិនបើ មិនត្រូវបង្គាប់ឱ្យចូលសម្រាកព្យាបាលក្នុងពេលបើកការជំនុំជម្រះទេនោះ ក្រសួងសុខភាពផ្លូវចិត្ត និងពិការរូបរាងកាយ ត្រូវដាក់ញត្តិទៅតុលាការដើម្បីសុំដោះលែងជន

សម្រេច ថាតើត្រូវលើកលែងបទចោទ ឬត្រូវដាក់វិធានការចំពោះការដោះលែង ដែលក្នុងករណី បានឆ្លុះបញ្ចាំងនូវឆន្ទានុសិទ្ធិដទូលាយរបស់រដ្ឋអាជ្ញា និងមន្ត្រីតុលាការ ដូចដែលមានចែងក្នុង ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។

52. យោងតាមចំណុចខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្នុងចំណោមសារណាតបផ្សេងៗទៅនឹងភាពគ្មានសម្បទាចូលរួមសវនាការ ភាពស្របគ្នានៃការអនុវត្តតាមកម្រិតមួយក្នុងការបង្កើតនូវគោលការណ៍ទូទៅនៃច្បាប់ គឺថា ជនជាប់ចោទដែលគ្មានសម្បទាគ្រប់គ្រាន់ចូលរួមសវនាការ មិនអាចទទួលរងនូវកិច្ចនីតិវិធីជាធម្មតាដែលនាំទៅរកការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌឡើយ។ ទោះបីជាយ៉ាងណា កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដែលពុំមានសម្បទាគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ត្រូវបានបញ្ចប់ ហើយតុលាការបានបោះបង់ចោលនូវយុត្តាធិការលើជនជាប់ចោទ គឺនៅតែជាករណីពិសេស ពាក់ព័ន្ធនឹងសំណុំរឿងនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ ការពិតដែលថា កិច្ចដំណើរការនីតិវិធីនៅតែពុំទាន់ចប់ជាស្ថាពរ ប្រឆាំងនឹងជនជាប់ចោទដែលពុំមានសម្បទាគ្រប់គ្រាន់ ដែលត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ បើទោះ បីជាពុំមានសម្បទាគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ក៏ដោយ ក៏ជាទូទៅពុំត្រូវបានចាត់ទុកថាជាការរំលោភដែលគ្មានសមាមាត្រលើសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទឡើយ ពិសេសសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលសមស្រប។ ដូចការបញ្ជាក់របស់តុលាការកំពូលនៃប្រទេសកាណាដា នៅពេលដែលកិច្ចដំណើរការនីតិវិធីពុំត្រូវបានបញ្ចប់ ហើយល្ខឹកណាដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅមានសុពលភាពគតិយុត្តិ "ប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្ម នៅតែរក្សាអំណាចយុត្តាធិការលើជនជាប់ចោទដែលត្រូវបានរកឃើញថាពុំមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ដោយហេតុថាជននោះស្ថិតក្រោមការចោទប្រកាន់អំពីឧក្រិដ្ឋកម្ម និងកិច្ចដំណើរការនីតិវិធីដែលពុំទាន់ចប់ជាស្ថាពរ"[171]។ យុត្តា

---

ជាប់ចោទដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬការសន្យាគោរពតាមលក្ខខណ្ឌ ដែលតុលាការយល់ឃើញថាសមស្រប ដែលលក្ខខណ្ឌដូចនេះអាចរួមបញ្ចូល តែមិនចាំបាច់កំហិតត្រឹមតែលក្ខខណ្ឌតម្រូវឲ្យជនជាប់ចោទត្រូវធ្វើការព្យាបាល ឬធានាថាមានការព្យាបាលបញ្ហាស្មារតីរបស់ខ្លួនឡើយ")។

[171] *រឿងក្តី R ទល់នឹង Demers* កថាខណ្ឌ ២២។ *សូមមើលផងដែរចំពោះ* កថាខណ្ឌ ២៣ ("ដំណើរការនីតិវិធីព្រហ្មទណ្ឌមានសុពលភាព ហើយត្រូវផ្អាកក្នុងករណីដែលជនជាប់ចោទត្រូវបានកំណត់ថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ") និងកថាខណ្ឌ ២១ (ដែលដកស្រង់ R.D.Schneider នៅក្នុង "បញ្ហាផ្លូវចិត្តនៅក្នុងតុលាការៈការមិនចោទប្រកាន់ទាំងស្រុង ចំពោះការមិនមានសម្បទា?" (២០០០) ២១ សម្រាប់មេធាវីការពារក្តី ៣៦ នៅកថាខណ្ឌ ៣៨ "វិធានស្តីពីសម្បទាត្រូវបានបង្កើតឡើងដើម្បីធានាថា មិនត្រូវបន្តការចោទប្រកាន់ទេ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពក្នុងឆ្លើយតបគ្រប់គ្រាន់ទៅរដ្ឋទេនោះ។ វិធានទាំងនេះបង្កើតឡើងដើម្បីការពារជនជាប់ចោទ។ បើទោះជាវាជាការពិតថា ជនជាប់ចោទអាចថា តាមរយៈ"ការគ្មានសម្បទាជាអចិន្ត្រៃយ៍" ច្បាស់ណាស់ថា ស្ថានភាពរបស់ជនជាប់ចោទដែលបានភ្ជាប់ជាមួយនឹង គោលការណ៍នៃការសន្មតថាគ្មានទោស

ធិការ មានភាពសមហេតុផលដោយសារផលប្រយោជន៍នៃយុត្តិធម៌ ដើម្បីចោទប្រកាន់ជនជាប់ចោទ ដែលត្រូវបានកំណត់ថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តួចផ្តើមការចោទប្រកាន់ ឬការជំនុំជម្រះ ដូចក្នុងសំណុំរឿងនាពេលបច្ចុប្បន្នប្រឆាំងនឹងជនជាប់ចោទ។ ជាក់ស្តែង យុត្តាធិការអនុញ្ញាតឱ្យតុលាការចាត់វិធានការនានាដែលត្រូវបានចាត់ទុកថាជាវិធានការចាំបាច់ និងសមស្របក្នុងកាលៈទេសៈទាំងនេះ ដើម្បីអាចបន្តកិច្ចដំណើរការនីតិវិធី ប្រសិនបើមានឱកាស។ ត្រង់ចំណុចនេះ កត់សម្គាល់ឃើញថា ភាពគ្មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ត្រូវបានវាយតម្លៃដោយផ្អែកតាមលក្ខខណ្ឌរបស់ជនជាប់ចោទ និងវិទ្យាសាស្ត្រផ្នែកវេជ្ជសាស្ត្រ ក្នុងពេលជាក់លាក់ណាមួយ។ មិនត្រឹមតែមានភាពខុសប្លែកគ្នាទាំងពេលវេលា និងការវាយតម្លៃនោះទេ ជាពិសេសនៅពេលជាប់ពាក់ព័ន្ធនឹងស្ថានភាពស្មារតី ទាំងនេះគឺអាស្រ័យលើកំហុសរបស់មនុស្ស និងអាកប្បកិរិយាពុំស្មោះត្រង់របស់ជនជាប់ចោទ[172]។ យោងតាមហេតុផលទាំងនេះ ប្រព័ន្ធគតិយុត្ត និងការអនុវត្តជាក់ស្តែងស្របតាមកម្រិតអន្តរជាតិ បាន

---

(...) មានលក្ខណៈជាប្រយោជន៍ដល់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដែលគ្មានសម្បទា និងការបញ្ចប់បទចោទធ្ងន់ធ្ងរ")។

[172] ហានិភ័យពាក់ព័ន្ធនឹងការផ្អាកយុត្តាធិការចំពោះជនជាប់ចោទដោយសារតែភាពគ្មានស្ថេរភាព ឬកំហុសនៃការវាយតម្លៃរបស់អ្នកជំនាញ ត្រូវបានបង្ហាញតាមរយៈករណីមួយចំនួនដែលទទួលបានការយកចិត្តទុកដាក់តិចតួច។ ជាឧទាហរណ៍ អង្គជំនុំជម្រះបានកត់សំគាល់ថាករណី Ernest Saunders ដែលជាអ្នកជំនួញជនជាតិអង់គ្លេសដែលត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ៥ ឆ្នាំ ចំពោះអំពើឧក្រិដ្ឋពាក់ព័ន្ធនឹងជំនួញដែលរួមមានគណនីក្លែងក្លាយ ការរួមគំនិត និងចោរកម្ម។ គាត់បានប្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចនេះ និងបានទទួលការបន្ថយការកាត់ទោស (*រឿងក្តី R ទល់នឹង Saunders* តុលាការឧទ្ធរណ៍ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩១) ប្រតិចារិកបោះពុម្ពផ្សាយ ដោយ Marten Walsh Cherer in *the Independent* ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩១, ដែលអនុញ្ញាតឱ្យគាត់ត្រូវបានដោះលែងភ្លាមៗ ដោយផ្អែកលើមូលដ្ឋានថាគាត់មានជំងឺផ្លូវចិត្តកម្រិតធ្ងន់។ ស្ថានភាពជំងឺរបស់គាត់ត្រូវបានវាយតម្លៃដោយអ្នកជំនាញដែលបានវាយតម្លៃបន្ទាប់ពីធ្វើតេស និងពិនិត្យថាម្ចាស់បណ្តឹងឧទ្ធរណ៍មិនត្រឹមតែ មានការវង្វេងប៉ុណ្ណោះទេ ប៉ុន្តែគាត់មានបញ្ហាចុះខ្សោយខួរក្បាលធ្ងន់ធ្ងរផង (ទំព័រទី ២ និង ៣ នៃសាលដីកា)។ បន្ទាប់ពីដោះលែងភ្លាមលោក Saunders ត្រូវបានរាយការណ៍ថា បានជាសះស្បើយពីជំងឺផ្លូវចិត្តដែលបានចោទប្រកាន់ ហើយបានបន្តធ្វើជំនួញរយៈពេលជាច្រើនឆ្នាំ។ (J. Warner, "Ernest Saunders; ចេញពីគុក ហើយត្រឡប់ទៅធ្វើជំនួញ", *The Independent*, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៦; *Id.*, "Ronson: Ernest's Alzheimer's គឺជាគំនិតរបស់ខ្ញុំ", *The Independent*, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៩; M. Verdin, "អ្នកជើងឯក Guinness ទាំងបួន បរាជ័យក្នុងការប្រឆាំងនឹងការដោះលែងឱ្យរួចខ្លួន", BBC News Online, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០១។ *សូមមើល* "ភាពគ្មានសម្បទាចូលរួមសវនាការ", 81 *Harv. L. Rev.* 454, ខែ ធ្នូ ឆ្នាំ ១៩៦៧ (ការសង្ស័យ "ថា ជនជាប់ចោទធ្វើពុតជាឈឺ", តម្រូវឱ្យធ្វើសក្ខីកម្មរបស់អ្នកជំនាញផ្នែកចិត្តសាស្ត្រ ដើម្បីធានាឱ្យមានការធ្វើរោគវិនិច្ឆ័យឱ្យបានពេញលេញលើលក្ខខណ្ឌបញ្ហាស្មារតីរបស់ជនជាប់ចោទ។ បង្ហាញនូវហានិភ័យនៃភាពមិនត្រឹមត្រូវក្នុងការវិភាគលើបញ្ហាបញ្ហាស្មារតី ដោយផ្អែកខ្លះចំពោះអាកប្បកិរិយារបស់ជនជាប់ចោទ)។

អនុញ្ញាតការអនុវត្តនូវវិធានការដាក់លាក់ ដែលអាចមានភាពចាំបាច់ក្នុងកាលៈទេសៈទាំងនេះ ដើម្បីបើកចំហរលទ្ធភាពនៃការបន្តកិច្ចដំណើរការនីតិវិធី។ បញ្ហានេះផ្ដាក់មកនៅត្រង់ ថាតើ វិធានការអ្វីខ្លះប្រសិនបើមាន ជាវិធានការចាំបាច់ និងមានសមាមាត្រ នៅពេលដែលជនជាប់ចោទមានក្ដីសង្ឃឹមស្ដួចស្ដើង ក្នុងការទទួលបានការជំនុំជម្រះ[173]។

53. តាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងបានភាន់ច្រឡំផ្នែកអង្គច្បាប់ ក្នុងការសន្និដ្ឋានថា អ.វ.ត.ក មិនត្រូវបានអនុញ្ញាតឱ្យអនុវត្តយុត្តាធិការលើជនជាប់ចោទក្នុងអំឡុងពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធីដោយពុំមានពេលវេលាកំណត់ច្បាស់លាស់ប្រឆាំងនឹងជនជាប់ចោទ ដោយហេតុថា សេចក្ដីសន្និដ្ឋានបែបនេះ ពុំមានការគាំទ្រដោយច្បាប់នៅចំពោះមុខ អ.វ.ត.ក ឬការអនុវត្តនៅក្នុងបទដ្ឋានអន្តរជាតិជាធរមាន។

54. បន្ទាប់ពីបានបញ្ជាក់នៅក្នុងកថាខណ្ឌខាងលើថា អ.វ.ត.ក នៅតែមានយុត្តាធិការលើជនជាប់ចោទក្នុងអំឡុងពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធីដែលគ្មានពេលកំណត់ អង្គជំនុំជម្រះតុលាការកំពូលលើអំណះអំណាងទីពីររបស់អង្គជំនុំជម្រះសាលាដំបូងប្រឆាំងនឹងការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ គឺថា ការជំទាស់ទៅនឹងកង្វះ"មូលដ្ឋានផ្នែកគតិយុត្តជាក់ច្បាស់"។ ជាចំណុចចាប់ផ្ដើម អង្គជំនុំជម្រះតុលាការកំពូល លើកឡើងសារជាថ្មីថា ការផ្អាក់កិច្ចដំណើរការនីតិវិធី មិនបានរារាំងតុលាការក្នុងការធ្វើចំណាត់ការលើដំណើរការនីតិវិធី និងអនុវត្តវិធានការដើម្បីធានាការបន្តកិច្ចដំណើរការនីតិវិធីនិសុចរិតភាពរបស់ខ្លួនឡើយ។ ជាឧទាហរណ៍ តុលាការចាំបាច់ត្រូវចាត់វិធានការដើម្បីបញ្ឈប់ឧបសគ្គដល់កិច្ចដំណើរការនីតិវិធី (ដូចជាការ ទទួលបាននូវការលះបង់ចោលនូវអភ័យឯកសិទ្ធិ ចាប់ខ្លួនជនជាប់ចោទ) ការការពារភស្តុតាង (ទីកន្លែងដាក់ភស្តុតាង ឬការបង្ហាញភស្តុតាង ការការពារ ឬបញ្ឈប់ការការពារសាក្សី) ការធានាវត្តមានរបស់ជនជាប់ចោទចំពោះមុខតុលាការ (តាមរយៈការឃុំខ្លួន ឬការដាក់ប្រាក់ធានា) និងការចាត់វិធានការនានាបង្ហាញភស្តុតា។ ដោយគ្មានការបញ្ជាក់ណាផ្ទុយពីនេះ សកម្មភាពទាំងនេះ ចាំបាច់ត្រូវធ្វើឡើងដោយអនុលោមតាមវិធានទូទៅ។ អាស្រ័យហេតុនេះ មូលដ្ឋានគតិយុត្តិជាផ្លូវការសម្រាប់អនុវត្តការឃុំខ្លួន និងវិធានការផ្សេងៗទៀត ក្នុងអំឡុងពេលផ្អាកកិច្ចដំណើរ

---

[173] តុលាការកំពូល ICC ក្នុងរឿងក្ដី*Lubanga* ត្រូវបានអង្គជំនុំជម្រះសាលាដំបូងផ្នែកលើ បានសម្រេចថា ដោយគ្មានការផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ឬមិនអាចកែប្រែបាន ក្ដីសង្ឃឹមបន្តដំណើរការនីតិវិធី គឺជាកត្តមួយដែល ត្រូវធ្វើការពិចារណាពេលសម្រេចលើបញ្ហាថាតើ ដោះលែងជនជាប់ចោទ ដោយមានលក្ខខណ្ឌ ឬផ្ទុយពីនេះ មិនប៉ះពាល់ដល់យុត្តាធិការរបស់តុលាការក្នុងការដាក់វិធានការរឹតត្បិត ចំពោះការដោះលែងទេ(សេចក្ដីសម្រេច *Lubanga* កថាខណ្ឌ ៣៧)។

ការនីតិវិធី គឺជាបទប្បញ្ញត្តិនានាដែលមានចែងក្នុងគន្ថីទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៦៣, ៦៥ និង ៨២ នៃវិធានផ្ទៃក្នុង។

55. ជាពិសេស របបនៃការត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅតែអាចយកមកអនុវត្តបាន ក្នុងអំឡុងពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលជំនុំជម្រះផងដែរ។ ជាយថាភាពដែលអាចកើតមានឡើងថា ការអនុវត្តមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អាចបង្កឱ្យមានភាពមន្ទិលសង្ស័យដល់ការអនុវត្តនៅពេលជំនុំជម្រះ[174] អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា បន្ថែមទៅលើទឡ្ហីករណ៍ *ពីធំទៅតូចជាក់លាក់* (maiori ad minus) ដែលគាំទ្រដល់សមត្ថកិច្ចរបស់តុលាការជំនុំជម្រះ ក្នុងការអនុវត្តវិធានការនេះ[175] មានបទប្បញ្ញត្តិជាក់លាក់នានាដែលប្រមើលមើលពីការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ នៅក្នុងដំណាក់កាលជំនុំជម្រះ ដូចជា៖ *ជារួម* *(in fine)* មាត្រា ២៩០ ចែងថា តុលាការមានសមត្ថកិច្ចសម្រេចថាតើការត្រួតពិនិត្យតាមផ្លូវតុលាការដែលត្រូវបានបង្គាប់ឱ្យអនុវត្តនៅដំណាក់កាលមុនការជំនុំជម្រះនោះ គួរបន្តទៅដល់ដំណាក់កាលជំនុំជម្រះ ឬយ៉ាងណា ចំណែកឯមាត្រា ៣៥២ ចែងថា ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបញ្ចប់ នៅពេលមានការចេញសាលក្រម។ ជាងនេះទៀត វិធានផ្ទៃក្នុងចែងពីលទ្ធភាពសម្រាប់អង្គជំនុំជម្រះសាលាដំបូងដោះលែងជនជាប់ចោទដោយដាក់ឱ្យ "ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ"[176]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការប្រើពាក្យ "bail order" ("ដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ") ជាភាសាអង់គ្លេស នៅក្នុងវិធានផ្ទៃក្នុង អាចបង្ហាញពីទស្សនាទានគតិយុត្តិមួយ ដែលខុសពីការត្រួតពិនិត្យតាមផ្លូវតុលាការ (judicial supervision) ជាពិសេស នៅពេលសម្លឹងមើលដោយផ្អែកលើប្រព័ន្ធច្បាប់អង់គ្លូសាក់សុងវិញ។ ទោះជាយ៉ាងណាក្តី ទាំងភាសាបារាំង និង ភាសាខ្មែរ សុទ្ធតែប្រើពាក្យ "judicial supervision" ដូចគ្នា។ បើយើងសម្លឹងមើលពីរបៀបដែលវិធានផ្ទៃក្នុងបានពណ៌នាទៅលើពាក្យ "bail order" ("ដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ") ជាដីកាដែលសមត្ថកិច្ចតុលាការបានចេញ នៅពេលជនជាប់ចោទត្រូវបានដោះលែងពីមន្ទីរឃុំឃាំង រង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដោយមានលក្ខខណ្ឌតម្រូវឱ្យជន នោះបង់ប្រាក់ធានា និង/ឬគោរពតាមលក្ខខណ្ឌមួយចំនួនដែលមានចែងក្នុង

---

[174] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសមត្ថភាព កថាខណ្ឌ ៧៤។ សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខ កថាខណ្ឌ ២៥។

[175] សេចក្តីសម្រេចលើកទី១លើបណ្តឹងសាទុក្ខ, កថាខណ្ឌ ៤៥-៤៦។

[176] វិធាន ៨២(២) និង ៦៥ នៃវិធានផ្ទៃក្នុង។

ដីកានោះ[177] យើងឃើញថា វា បានបញ្ជាក់ច្បាស់ណាស់ថា ចំណុចនេះផ្អែកទៅលើទស្សនាទានដូចគ្នាទៅនឹងទស្សនាទានដែលមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែរ[178]។

56. អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា គោលបំណងផ្សេងៗដែលច្បាប់អនុញ្ញាតឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការដែលអាចត្រូវបានបង្គាប់ មានដូចជា ការធានាវត្តមានរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ ការរារាំងហានិភ័យដល់សាក្សី ឬជនរងគ្រោះ ការរារាំងការឃុបឃិតគ្នាជាមួយជនរួមគំនិត ការការពារសាក្សី ការការពារសន្តិសុខរបស់ជនជាប់ចោទ និងការពារសណ្តាប់ធ្នាប់សាធារណៈ[179] មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពចាំបាច់នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ បរិបទនៃគន្ថីទី ៣ ទាំងមូល នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលហៅថា “វិធានការសន្តិសុខ” បង្ហាញថា គោលបំណងនៃវិធានការសន្តិសុខទាំងនេះដែលបានរៀបរាប់ក្នុងមាត្រា ២០៥ និងដូចគ្នាទៅនឹងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ជាក់ស្តែង កំណត់ថា នឹងមានការជំនុំជម្រះទៅនឹងពេលអនាគត និងធ្វើការរារាំងការជ្រៀតជ្រែកជាមុនដល់ការជំនុំជម្រះ។ នៅខាងក្រៅបរិបទនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌវិញ ដូចជា បន្ទាប់ពីការបញ្ចប់សំណុំរឿង ការគ្មានសំអាងហេតុ អាចបង្កើតជាមូលដ្ឋានស្វយ័តមួយសម្រាប់ដាក់ចេញការត្រួតពិនិត្យតាមផ្លូវតុលាការបាន។ មានន័យថា ដោយហេតុថាទំនាក់ទំនងរវាងកិច្ចដំណើរការនីតិវិធី មានលក្ខណៈសំខាន់ ការជំទាស់របស់មេធាវីការពារក្តី ដែលថាវិធានការនៃការត្រួតពិនិត្យ តាមផ្លូវតុលាការ ត្រូវបានអនុញ្ញាតតែក្នុងករណីដែល ការត្រួតពិនិត្យនេះត្រូវបានអនុវត្តដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ[180] ការជំទាស់នេះមានលក្ខណៈវែងឆ្ងាយពេក។ សំអាងហេតុដែលបានអនុញ្ញាតដោយច្បាប់ អាចត្រូវបានអនុវត្តផងដែរ ទាក់ទងទៅនឹងគោលបំណងនៃការធានាវត្តមានរបស់ជនជាប់ចោទ។ បញ្ហាថាតើ វិធានការនេះ គឺជាការរឹតត្បិតដល់សិទ្ធិរបស់ជនជាប់ចោទនោះ គឺអាស្រ័យលើកាលៈទេសៈនៃរឿងក្តី។

57. ជាការសន្និដ្ឋាន បញ្ហាសំខាន់ដែលកើតចេញពីការផ្អាក់កិច្ចដំណើរការនីតិវិធីគ្មានកំណត់ ដោយសារភាពគ្មានសម្បទា ជាអចិន្ត្រៃយ៍របស់ជនជាប់ចោទ លើវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មិនមែន

---

[177] វិធានផ្ទៃក្នុង, សន្ទានុក្រម និង វិធាន ៦៥(១)។

[178] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខលើកទី១, កថាខណ្ឌ ៤៥។

[179] វិធាន ៦៥(១)នៃវិធានផ្ទៃក្នុង (អនុញ្ញាតឱ្យដាក់ “លក្ខខណ្ឌបែបនេះ ដែលមានលក្ខណៈចាំបាច់ ក្នុងការធានាវត្តមានរបស់ជនជាប់ចោទក្នុងកិច្ចដំណើរការនីតិវិធី និងការការពារអ្នកដទៃ”) ដោយអានផ្ទួបគ្នាជាមួយវិធាន ៦៣(៣)(ខ) មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយអានផ្ទួបជាមួយមាត្រា ២០៥។

[180] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៦១។

ជាការខ្វះ យុត្តាធិការ ឬមូលដ្ឋានច្បាប់នោះទេ ប៉ុន្តែគឺជាបញ្ហានៃភាពចាំបាច់ និងសមាមាត្រនៃវិធានការនេះនៅក្នុង កាលៈទេសៈបច្ចុប្បន្ននេះ។ បញ្ហានេះ ពុំត្រូវបានធ្វើការពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង។ ហេតុនេះ ស្ថិតក្នុងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលជាអ្នកសម្រេចលើបញ្ហានេះ។

**៣. ថាតើអង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដោយបង្គាប់ឱ្យដោះលែងដោយឥតលក្ខខណ្ឌ ជំនួសការដាក់លក្ខខណ្ឌសមស្របនៃការត្រួតពិនិត្យតាមផ្លូវតុលាការ និងកំហុសអង្គហេតុ ឬការអនុវត្តឆន្ទានុសិទ្ធិក្នុងការយល់ឃើញថា លក្ខខណ្ឌទាំងនេះមិនអាចអនុវត្តបាន ឬអនុវត្តមិនកើត**

58. ទោះបីវាមានភាពស្រាលជាងការឃុំខ្លួនក៏ដោយ ក៏វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលស្នើឡើងដោយសហព្រះរាជអាជ្ញា នៅតែដាក់កំហិតដល់សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទដែរ *ក្នុងចំណោមនោះ* រួមមាន សេរីភាពក្នុងការដើរហើរ សិទ្ធិរបស់បុគ្គលឯកជន ដែលត្រូវបានការពារក្នុងមាត្រា ១២ និង ១៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ(“ICCPR”)។ ហេតុនេះ ពុំមានភាពគ្រប់គ្រាន់ដែលថា ការរឹតបន្តឹងនេះ មានមូលដ្ឋានច្បាប់ជាផ្លូវការ ដូចដែលបានពិភាក្សាខាងលើ តុលាការអាចកំណត់ដាក់វិធានការទាំងនេះដែលមានភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ និងស្របទៅតាមគោលការណ៍សមាមាត្រ ដោយធ្វើឱ្យមានភាពសមរម្យដើម្បីសម្រេចឱ្យបាននូវតួនាទីការពាររបស់ខ្លួន ដែលជាឧបករណ៍ដែលមានភាពបំពានតិចជាងគេ ក្នុងចំណោម ឧបករណ៍ដទៃទៀត ដែលអាចសម្រេចបាននូវលទ្ធផលដែលចង់បាន និងមានសមាមាត្រជាមួយនឹងផលប្រយោជន៍ដែលត្រូវការពារ[181]។ លក្ខខណ្ឌតម្រូវនៃភាពសមាមាត្រគ្នា បានគិតទៅដល់ទំនាក់ទំនងរវាងវិសាលភាពនៃការ

---

[181] យោបល់ទូទៅលេខ ២៧៖ មាត្រា ១២ នៃកតិកាសញ្ញាណអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ឯកសារលេខ CCP/C/21/Rev.1/Add.9, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩, កថាខណ្ឌ ១៤ (“មាត្រា ១៤ កថាខណ្ឌ ៣ បានបង្ហាញច្បាស់ថា មិនគ្រប់គ្រាន់ទេដែលថា ការកំហិតនានាសម្រាប់គោលបំណងដែលត្រូវបានអនុញ្ញាតនោះ, ការកំហិតទាំងនេះក៏ត្រូវតែជាការចាំបាច់ដើម្បីការពារពួកគេ។ វិធានការតឹងរ៉ឹងត្រូវតែស្របទៅនឹងគោលការណ៍សមាមាត្រ វិធានការទាំងនោះត្រូវតែស្របទៅនឹងគោលការណ៍សមាមាត្រ វិធានការទាំងនោះត្រូវតែសមរម្យដើម្បីសម្រេចឱ្យបាននូវមុខងារការពាររបស់ខ្លួន យ៉ាងហោចណាស់វិធានការទាំងនោះត្រូវតែជាឧបករណ៍ដែលបំពានច្បាប់តិចជាងគេ ក្នុងចំណោមឧបករណ៍ដទៃទៀត ដែលអាចសម្រេចបាននូវលទ្ធផលគួរជាទីពេញចិត្ត និងវិធានការទាំងនោះត្រូវតែសមាមាត្រទៅនឹងផលប្រយោជន៍ដែលត្រូវការពារ”)។ *សូមមើល* យោបល់ទូទៅលេខ ៣១៖ លក្ខណៈនៃកាតព្វកិច្ចគតិយុត្តិទូទៅដែលកំណត់ទៅលើភាគីនៃកតិកាសញ្ញា, ឯកសារលេខ CCPR/C/21/Rev.1/Add. ចុះថ្ងៃទី ១៣, ១៦ ខែ ឧសភា ឆ្នាំ ២០០៤, កថាខណ្ឌ ៦ (“នៅពេលដែលការកំហិត [ទៅលើសិទ្ធិ] ត្រូវបានធ្វើឡើងនោះ រដ្ឋត្រូវបង្ហាញពីភាពចាំបាច់នៃការកំហិតទាំងនោះ និងចាត់វិធានការទាំងនេះតែក្នុងករណីដែលវាសមាមាត្រទៅនឹងគោលបំណងស្របច្បាប់ដើម្បីធានាបន្តការការពារសិទ្ធិនានាទៅតាមកតិកាសញ្ញាឱ្យមានប្រសិទ្ធភាព”); អបជ ១៤ និង ១៥, សេចក្តីសម្រេចលើ

វិតបន្តឹង និងគោលដៅរបស់វា[182]។ អាស្រ័យហេតុនេះ វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវតែមានលក្ខណៈទៀតទាត់ច្បាស់លាស់ ឬមិនត្រូវមានកម្រិតជ្រុលហួសនោះទេ។ ក្នុងករណីដែលមានវិធានការស្រាលជាងការត្រួតពិនិត្យតាមផ្លូវតុលាការ ឬក្នុងចំណោមលក្ខខណ្ឌនានាក្រោមរបបនៃ ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវយកវិធានការនោះមកអនុវត្តវិញ[183]។ ការត្រួតពិនិត្យតាមផ្លូវតុលាការផ្អែកលើអង្គហេតុ និងត្រូវពិចារណាទៅតាមលក្ខណៈជាក់ស្តែងរបស់បុគ្គលម្នាក់ៗ[184]។ ទាក់នឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា របបនៃការត្រួពិនិត្យតាមផ្លូវតុលាការមានចែង

---

បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំដោះលែង និង ពន្យារពេលដីកាសម្រេចដោះលែងបណ្តោះអាសន្ន, អង្គបុរេជំនុំជម្រះ, ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារលេខ C26/5/26, កថាខណ្ឌ ៩១ (“សក្តិសម ចាំបាច់ និងមានទំនាក់ទំនងយ៉ាងសមរម្យទៅនឹងគោលដៅនៃលក្ខខណ្ឌនេះ”), ដោយដកស្រង់ចេញពី *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-04-74, ដីកាសម្រេចលើការដោះលែង Slobodan Praljak បណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ១៤-១៦ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-02-53-PT, សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ Jokić បណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២, កថាខណ្ឌ ១៨; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Hadžihasanović*, សំណុំរឿងលេខ IT-01-47-PT, សេចក្តីសម្រេចអនុញ្ញាតឱ្យដោះលែង Enver Hadžihasanović បណ្តោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១, កថាខណ្ឌ ៨។

[182] *រឿងក្តី Silver និង អ្នកដទៃទៀត តទល់នឹង ចក្រភពអង់គ្លេស,* ECtHR, សំណើលេខ 5947/72; សាលក្រម, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨៣, កថាខណ្ឌ ៩៧ ដកស្រង់ពី Handyside។

[183] សេចក្តីសម្រេចលើ *រឿងក្តី Talić*, កថាខណ្ឌ ២៣។

[184] សេចក្តីសម្រេចទីមួយលើបណ្តឹងសាទុក្ខរបស់ អ.ជ.ត.ក លើសម្បទាក្នុងការចូលរួមសវនាការ, កថាខណ្ឌ ៣០។ អ.ជ.ត.ក លេខ ០៤, សេចក្តីសម្រេចភ្លាមៗលើបណ្តឹងសាទុក្ខ របស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែង អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃ ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E50/3/1/4, កថាខណ្ឌ ៥៤ (“ថាតើហានិភ័យកម្រិតណាអាចកាត់បន្ថយតាមរយៈវិធានការ ដែលមិនផ្អែកលើការឃុំខ្លួន ត្រូវវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានការពិនិត្យយ៉ាងត្រឹមត្រូវរាល់កត្តាពាក់ព័ន្ធទាំងអស់”)។ *សូមមើលផងដែររឿងក្តី រដ្ឋអាជ្ញា ទល់នឹង Boškoski និង Tarčulovski*, សំណុំរឿងលេខ IT-04-82-AR65.1, សេចក្តីសម្រេចលើ បណ្តឹងសាទុក្ខបន្ទាន់បន្ទំរបស់ Johan Tarčulovski ស្តីពីការដោះលែងបណ្តោះអាសន្ន, អង្គជំនុំជម្រះឧទ្ធរណ៍, ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៥ កថាខណ្ឌ ៧ (“សេចក្តីសម្រេចលើសំណើសុំ ដោះលែងបណ្តោះអាសន្ន គឺជាបញ្ហាអង្គហេតុ និង សំណុំរឿង ត្រូវបានសម្រេចផ្អែកលើមូលដ្ឋានបុគ្គល។ ដោយពិចារណាទៅលើភាពស្មុគស្មាញជាក់ស្តែង សំណើសុំនីមួយៗស្តីពីការដោះលែង ត្រូវបានវិភាគ ដោយពិចារណាទៅលើកាលៈទេសៈមួយចំនួននៃជនជាប់ចោទនីមួយៗ”)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bemba*, សំណុំរឿងលេខ ICC-01/05-01/08 (OA), សាលដីកាលើបណ្តឹសាទុក្ខរបស់ Mr. Jean-Pierre Bemba Gombo ប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ III ហៅថា “សេចក្តីសម្រេចលើសំណើសុំដោះលែងបណ្តោះអាសន្ន”, អង្គជំនុំជម្រះឧទ្ធរណ៍, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៨,កថាខណ្ឌ ៥៥ (កត់សម្គាល់ថា ការឃុំខ្លួន ឬ ការដោះលែងអាចធ្វើយុត្តិកម្មបានបន្ទាប់ពីមានការវិភាគរាល់កត្តាទាំងឡាយ)។

ក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៦៥ នៃវិធានផ្ទៃក្នុង មានលក្ខណៈបទបែនគ្រប់គ្រាន់ ក្នុងការអនុញ្ញាតឱ្យមានតុល្យភាពរវាង ផលប្រយោជន៍ផ្សេងៗ និងបង្កើតនូវរបបមួយដែលសមស្របក្នុងកាលៈទេសៈនេះ។

59. នៅក្នុងរឿងក្តីបច្ចុប្បន្ន ដោយហេតុថា ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត ដែលគេស្គាល់នោះ រួមមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនូវអនុសញ្ញាទីក្រុងហ្សឺណែវ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ទើបមានភាពចាំបាច់ដល់សង្គមក្នុងការធានាថា សំអាងហេតុក្នុងការផ្អាកកិច្ចដំណើរការនីតិវិធី នៅតែមានសុពលភាព ក៏ដូចជា ដើម្បីបញ្ជាក់ច្បាស់លើបញ្ហា ថាតើជនជាប់ចោទ នៅតែពុំមានសម្បទាចូលរួមសវនាការ ដែរ ឬយ៉ាងណា។ លទ្ធភាពជាទ្រឹស្តីទូទៅនៃការបន្តកិច្ចសវនាការឡើងវិញ មានចែងក្នុងក្របខណ្ឌគតិយុត្ត ដែលមិនបានអនុញ្ញាតឱ្យបោះបង់កិច្ចដំណើរការនីតិវិធីដោយសារភាពមិនមានសម្បទាគ្រប់គ្រាន់ឡើយ។ យោងតាមភាពជាក់ស្តែងនៃរឿងក្តីនេះ លទ្ធភាពនេះសំអាទៅលើកត្តានានាដូចជា៖ ភាពជឿជាក់តិចតួចទៅលើយោបល់របស់អ្នកជំនាញ កម្រិតនៃភាពប្រហែល/កម្រិតនៃកំហុសឆ្គងនៃយោបល់អ្នកជំនាញ លទ្ធភាពរបស់ជនជាប់ចោទអាចធូរស្បើយឡើងវិញនាពេលអនាគត និងក្តីរំពឹងថាមានភាពប្រសើរឡើងនៃវិធីព្យាបាលជំងឺ។ ទោះបីជាមតិយោបល់ផ្នែកវេជ្ជសាស្ត្រដែលបានផ្តល់ជូននៅក្នុងសវនាការមានភាពខុសគ្នាក្តី[185] អង្គជំនុំជម្រះពុំមានភាពមន្ទិលសង្ស័យទៅលើគុណភាពនៃមតិយោបល់ ដែលអង្គជំនុំជម្រះសាលាដំបូង ទទួលបានពីអ្នកជំនាញដែលតែងតាំងដោយតុលាការ និងភាពត្រឹមត្រូវនៃការធ្វើរោគវិនិច្ឆ័យដែល ថា ជនជាប់ចោទមានជំងឺវង្វេងវង្វាន់ ដែលនាំឱ្យគាត់ពុំមានសម្បទាក្នុងការចូលរួមសវនាការ នោះ។ អង្គជំនុំជម្រះតុលាការកំពូលថែមទាំងទទួលយកមតិយោបល់របស់អ្នកជំនាញដែលថា លទ្ធភាពដែលថាជនជាប់ចោទនឹងមានសុខភាពប្រសើរឡើង មានតិចតួចណាស់ បើពិចារណាទៅ លើអាយុរបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា វិទ្យាសាស្ត្រ វេជ្ជសាស្ត្រមិនមែនជាវិទ្យាសាស្ត្រពិតឡើយ ហើយប្រែប្រួលតាមការវិវឌ្ឍ។ ចំណុចខ្វះខាត ជាក់ស្តែងនៃវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ហើយជាពិសេស មុខវិជ្ជាផ្សេងៗដែលទាក់ទិននឹងករណីនេះ ត្រូវបានបង្ហាញឱ្យឃើញតាមរយៈអង្គហេតុដែលថា បន្ទាប់ពីការព្យាបាល និងការពិនិត្យតាមដាន អស់រយៈពេលមួយឆ្នាំកន្លះរួចហើយ ការសន្និដ្ឋានរបស់អ្នកជំនាញគឺនៅតែស្ថិតនៅកម្រិតភវនីយភាព "*ទំនងជាមានជំងឺវង្វេងស្មារតី*"។ សក្តានុពលនៃវិទ្យា

---

[185] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៣, ២៥ (យោងទៅលើរបាយការណ៍ "ដោយគ្មានការស្នើសុំ"របស់គ្រូពេទ្យព្យាបាលជនជាប់ចោទគឺវេជ្ជបណ្ឌិត ចក ធីតា ដែលបានស្នើឡើងថា ជនជាប់ចោទពុំបានកើតជំងឺផ្លូវចិត្ត ឬធ្លាក់ចុះសតិបញ្ញាស្មារតីឡើយ និងយោងទៅលើសក្ខីកម្មរបស់លោកស្រីនៅចំពោះមុខអង្គជំនុំជម្រះ)។

សាស្ត្រវេជ្ជសាស្ត្រត្រូវបានបង្ហាញតាមរយៈឧទាហរណ៍នៃវិធីព្យាបាលដោយឱសថ ដែលមិនទាន់ត្រូវបានស្រាវជ្រាវឲ្យបានអស់នៅឡើយនោះ។ សូមរំឭកថា អ្នកជំនាញធ្លាប់បានណែនាំឲ្យប្រើថ្នាំ Donepezil ដែលតាមរបាយការណ៍ មានប្រសិទ្ធភាព ៣៣% ចំពោះអ្នកជំងឺវង្វេងស្មារតី។ ទោះបីជាការព្យាបាលបែបនេះ មិនត្រូវបានណែនាំឲ្យអនុវត្ត ក្រោយពីជនជាប់ចោទបានបង្ហាញថា មិនអាចទ្រាំទ្របានជាមួយនឹងឱសថនេះក៏ដោយ[186] ក៏មិនអាចច្រានចោលការស្វែងរករូបមន្តនាពេលអនាគតមួយដែលមានលក្ខណៈប្រសើរជាងនេះចំពោះជនជាប់ចោទ និងអាចយកមកប្រើប្រាស់បាននោះទេ។ អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់បានទទួលស្គាល់លទ្ធភាពនេះ ដោយធ្វើការពិគ្រោះយោបល់ជាមួយអ្នកជំនាញជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យ ថាតើ មានការព្យាបាលតាមបែបវេជ្ជសាស្ត្រថ្មីៗ ដែរ ឬយ៉ាងណា[187]។

60. ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មានភាពចាំបាច់ក្នុងការធានាថា លក្ខខណ្ឌរបស់ជនជាប់ចោទត្រូវបានតាមដានត្រួតពិនិត្យ។ ទោះជាយ៉ាងណាក៏ដោយ ក្ដីរំពឹងតិចតួចនៃការជំនុំជម្រះបានតម្រូវថា មានតែវិធានការដែលមានការប៉ះពាល់តិចតួចជាក់ស្ដែងលើសិទ្ធិរបស់ជនជាប់ចោទ ទើបអាចត្រូវបានចាត់ទុកថា មានភាពសមាមាត្រនៅក្នុងកាលៈទេសៈបច្ចុប្បន្នេះ។ ម្យ៉ាងវិញទៀត អ្វីដែលដើរតួសំខាន់ជាក់ស្ដែងនៅក្នុងការពិចារណានេះ គឺថា ជនជាប់ចោទ ដែលមិនមានសម្បទាជាអចិន្ត្រៃយ៍ក្នុងការចូលរួមសវនាការ ដោយសារលក្ខខណ្ឌនៃបញ្ហាស្មារតី តាមវិធាន និងក្នុងអត្ថន័យពិតជាក់ស្ដែង គឺពុំមានលទ្ធភាពអនុវត្តនូវសិទ្ធិរបស់ខ្លួនឱ្យបានពេញលេញនោះទេ។

61. អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ខ្លួននឹងធ្វើការពិចារណាទៅលើអង្គហេតុដែលថា ការចុះខ្សោយផ្នែកសតិស្មារតី និងជំងឺវង្វេងស្មារតីរបស់ជនជាប់ចោទ ធ្វើឲ្យមានការបារម្ភយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់គាត់ក្នុងការប្រតិបត្តិតាមវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដោយស្ម័គ្រចិត្ត ដែល តម្រូវឲ្យមានការសហការដោយផ្ទាល់ពីរូបគាត់។ តាមពិតទៅ ចំណុចនេះត្រូវបានបញ្ជាក់នៅក្នុង សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខលើកទីមួយ[188]។ ទាក់ទិននឹងបញ្ហានេះ មេធាវីការពារក្ដីអះអាងថា ការធ្លាក់ចុះយ៉ាងខ្លាំងនៃការចងចាំរបស់ជនជាប់ចោទ ធ្វើឲ្យគាត់"នឹងមិនមានការចងចាំ យល់ដឹង និងប្រតិបត្តិ

[186] របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ ដាក់ជូនតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៧។

[187] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៩។

[188] សេចក្ដីសម្រេចលើកទីមួយលើបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤៧។

តាមលក្ខខណ្ឌចាប់បង្ខំណាមួយដែលដាក់មកលើរូបគាត់ឡើយ"[189]។ ទោះបីជាសំអាង ហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធនឹងស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទ ត្រូវបានកំណត់ត្រឹមការសម្រេច ថាតើជនជាប់ចោទមានសម្បទាដើម្បីចូលរួមសវនាការដែរឬទេនោះ ក៏ សេចក្តីសម្រេចដែលរងការជំទាស់ និងរបាយការណ៍អ្នកជំនាញ ដែលបានដាក់នៅចំពោះមុខអង្គ ជំនុំជម្រះសាលាដំបូងបាន បង្ហាញថា ជនជាប់ចោទទទួលរងការខូចប្រព័ន្ធប្រសាទក្នុងកម្រិតពី មធ្យមទៅធ្ងន់ធ្ងរ[190] ដែលប៉ះពាល់ដល់លទ្ធភាពរបស់ជនជាប់ចោទក្នុងការយល់អំពីសំណួរ អនុវត្ត តាមការណែនាំ ចងចាំហេតុការណ៍នានា ផ្តង់អារម្មណ៍ និងការរក្សាការគិតឱ្យបានស៊ីសង្វាក់ គ្នា[191]។ ការចងចាំរយៈពេលខ្លី និងការចងចាំរយៈពេលវែងរបស់គាត់ បានធ្លាក់ចុះ[192]។ ឧទាហរណ៍ ជនជាប់ចោទមិនអាចចាំអាសយដ្ឋានរបស់គាត់ទេ[193]។ មានការបង្ហាញឱ្យឃើញផងដែរអំពីការវង្វេង សូម្បីតែនៅក្នុងទីកន្លែងតូចមួយដែលជនជាប់ចោទស្គាល់រួចហើយក្តី[194]។ នៅពេលសវនាការ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ជនជាប់ចោទមានអារម្មណ៍វង្វេង និងពិបាកយល់សំណួរដែលតុលាការសួរគាត់។

62. ដូចដែលបានរៀបរាប់កន្លងមក អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ការលំបាកក្នុងការអនុវត្តទណ្ឌកម្មលើជនជាប់ចោទ ប្រសិនបើជនជាប់ចោទមិនគោរពតាមកាតព្វកិច្ច ដែលបានដាក់ដោយតុលាការ ពុំបានធ្វើឱ្យកាតព្វកិច្ចទាំងនេះលែងមានសុពលភាពនោះទេ។ ផ្ទុយទៅវិញ ស្ថានភាពបែបនេះតម្រូវឱ្យមានការរៀបចំជាក់ស្តែង ដែលតម្រូវឱ្យមានការកាត់បន្ថយនូវហានិភ័យនៃការមិនគោរពតាមដីការបស់តុលាការ។ ដោយពិចារណាលើព័ត៌មាននេះ របបណាមួយនៃការត្រួតពិនិត្យតាមផ្លូវតុលាការ គប្បីត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់វិធានដែលតម្រូវឱ្យមានការចូលរួមតិចតួចរបស់ជនជាប់ចោទ ប្រសិនបើតម្រូវ ឬក្នុងករណីដែលតម្រូវឱ្យមានការផ្តល់ជំនួយសមស្រប

---

[189] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៧១។

[190] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨-៩, ១១, ២៤។ សេចក្តីសម្រេចលើសម្បទារបស់ អ.ជ.ស.ជ លើកទីមួយ កថាខណ្ឌ ៤៤, ៤៥, ៥៣។

[191] សេចក្តីសម្រេចលើសម្បទារបស់ អ.ជ.ស.ជ លើកទីមួយ កថាខណ្ឌ ៣៣។

[192] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៩, ១២។ សេចក្តីសម្រេចលើសម្បទា របស់ អ.ជ.ស.ជ លើកទីមួយ កថាខណ្ឌ ៥៣។

[193] របាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E138/1/7/13/2 កថាខណ្ឌ ៥០។

[194] សេចក្តីសម្រេចលើសម្បទា របស់ អ.ជ.ស.ជ លើកទីមួយ កថាខណ្ឌ ៣៥, ៣៦។

00869565



ដល់ជនជាប់ចោទ[195]។ ក្នុងករណីគ្មានការធានាអំពីកិច្ចសហការពីជនជាប់ចោទ ចាំបាច់ត្រូវមានការការពារបន្ថែម ដើម្បីសម្រួល និងធានានូវការគោរពកាតព្វកិច្ចដែលបានដាក់ចេញដោយតុលាការ។

63. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កូនស្រីរបស់ជនជាប់ចោទ គឺ អៀង វិជីដា ត្រូវបានសាលាដំបូងរាជធានីភ្នំពេញតែងតាំងជាអ្នកអាណាព្យាបាលទូទៅលើ អៀង ធីរិទ្ធ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ អនុលោមតាមក្រមរដ្ឋប្បវេណីកម្ពុជា[196]។ ជាពិសេស ជនជាប់ចោទត្រូវស្ថិតនៅក្រោម "អ្នកអាណាព្យាបាលទូទៅ"របស់គាត់[197] ដោយផ្អែកលើមូលដ្ឋានដែលថា គាត់"ខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវតុលាការនៃសកម្មភាពរបស់ខ្លួន ដោយ សារមានវិបត្តិផ្នែកបញ្ញាស្មារតី"[198]។ អនុលោមតាមក្រមរដ្ឋប្បវេណីកម្ពុជា តួនាទីរបស់អ្នក អាណាព្យាបាលទូទៅរួមមាន ការថែទាំជននៅក្រោមអាណាព្យាបាលទូទៅ រួមទាំងជីវភាព ការថែទាំព្យាបាល និងទ្រព្យសម្បត្តិរបស់ជននោះ[199]។ ក្នុងចំណោមប្រការផ្សេងទៀត អ្នកអាណាព្យាបាលទូទៅមានកាតព្វកិច្ចជាក់លាក់ត្រូវ"ខិតខំផ្តល់នូវការថែទាំព្យាបាលជននៅក្រោមអាណាព្យាបាលទូទៅ"[200]។ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយថា បទបញ្ញត្តិស្តីពីតួនាទីរបស់អ្នកអាណាព្យាបាល នៅក្នុងក្រមរដ្ឋប្បវេណី គឺផ្តោតទៅលើការជួសដល់ជនជាប់ចោទគ្មានសម្បទា ទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិ និងការផ្តល់ការថែទាំផ្នែកវិជ្ជសាស្ត្រ។ ចំណុចនេះ គឺថា ទំនាក់ទំនងនៃនីតិឯកជន មានភាពចាំបាច់បំផុត និងញឹកញាប់

---

[195] អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចថា កម្រិតនៃកិច្ចសហការពីជនជាប់ចោទដែលអង្គជំនុំជម្រះអាចរំពឹងទុកនោះ ត្រូវយកមកគិតពិចារណា (សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ លើកទីមួយ កថាខណ្ឌ ៤៦)។ អង្គជំនុំជម្រះត្រូវពិចារណាអំពីសមត្ថភាព ជាក់ស្តែងរបស់ខ្លួនក្នុងការដាក់ចេញនូវលក្ខខណ្ឌចាំបាច់ណាមួយ (*សូមមើល ក្នុងចំណោមប្រការផ្សេងទៀត ៖ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Bemba*, សំណុំរឿងលេខ ICC-01/05-01/08 (OA 2) សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ II លើការដោះលែង Jean-Pierre Bemba Gombo ជាបណ្តោះអាសន្ន និងការកោះឱ្យមានសវនាការ ជាមួយនឹងរាជាណាចក្របែលហ្សិក សាធារណរដ្ឋព័រទុយហ្គាល់ សាធារណរដ្ឋបារាំង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សាធារណរដ្ឋអ៊ីតាលី និងសាធារណរដ្ឋអាហ្វ្រិកខាងត្បូង"អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ១០៩។

[196] សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ លេខ ២៨៨ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E/138/1/10/1/2/3.1 ("សេចក្តីសម្រេចអ្នកអាណាព្យាបាលទូទៅ") ទំព័រ ៣។ ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ២៤ និង ១១០៥-១១៣៥។

[197] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ២៥។

[198] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ២៤។

[199] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ១១១៩(១)។

[200] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ១១១៩(២)។ សូមមើលផងដែរមាត្រា ១១២៥ ដែលមានចែងអំពីលទ្ធភាពដើម្បី "ត្រួតពិនិត្យអំពីជីវភាព និងការថែទាំព្យាបាលជននៅក្រោមអាណាព្យាបាលទូទៅ"។

បំផុតក្នុងកាជួយសម្រួលនៅក្នុងកាលៈទេសៈនៃភាពពុំមានសម្បទានេះ។ គោលបំណងនៃការបង្កើតអាណាព្យាបាលនេះ គឺមានលក្ខណៈទូលំទូលាយជាងការចាត់ចែងទ្រព្យសម្បត្តិរបស់បុគ្គល។ យោងតាមការកំណត់និយមន័យនេះ បង្ហាញឱ្យឃើញថា ជាការថែទាំទូទៅ ដែលផ្តល់ប្រយោជន៍ស្របច្បាប់ដល់បុគ្គលស្ថិតក្រោមអាណាព្យាបាលនេះ។ ដូច្នេះ ករណីយកិច្ចរបស់អ្នកអាណាព្យាបាល រួមមានការជួយដល់ជនជាប់ចោទស្ថិតក្រោមអ្នកអាណាព្យាបាល ដើម្បីបំពេញនូវកាតព្វកិច្ចតាមនីតិសាធារណៈ និងរួមទាំងកាតព្វកិច្ចដែលមានចែងក្នុងនីតិព្រហ្មទណ្ឌផងដែរ[201]។

64. ជាក់ស្តែង អ.វ.ត.ក ពុំមានអំណាចដាក់ទណ្ឌកម្មណាមួយទៅលើ អៀង ធីរិទ្ធ ពីបទរំលោភលើកាតព្វកិច្ចរបស់ម្តាយខ្លួន យោងតាមរបបដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[202]។ ទណ្ឌកម្មដែលតុលាការត្រូវដាក់លើកអ្នកអាណាព្យាបាល មានចែងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ត្រង់ធ្វើការជំនួសអ្នកអាណាព្យាបាល ឬចាត់តាំងអ្នកអាណាព្យាបាលថ្មី ឬអ្នកគ្រប់គ្រងទៅលើអ្នកអាណាព្យាបាលនោះ[203]។ ទោះជាយ៉ាងក្តីអង្គជំនុំជម្រះបានឃើញអំពីការចាត់តាំងអ្នកអាណាព្យាបាលលើជនជាប់ចោទដែលជាជំហានមួយវិជ្ជមានក្នុងការជួយដល់ជនជាប់ចោទ ដើម្បីគោរពតាមវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលអង្គជំនុំជម្រះអាចនឹងធ្វើការពិចារណាដាក់វិធានការនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ជាយោបល់នៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខទីមួយ ថាតម្រូវឱ្យបុគ្គលដែលជិតស្និទទៅនឹងជនជាប់ចោទ ក្នុងការជួយជនជាប់ចោទដើម្បីគោរពតាមលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មានសារៈសំខាន់ក្នុងការបញ្ឈប់នូវការឃុំខ្លួនជនជាប់ចោទ[204]។ ការជ្រើសតាំងអ្នកអាណាព្យាបាលពេលបច្ចុប្បន្ននេះមានលក្ខណៈវែងឆ្ងាយជាងការផ្តល់យោបល់នេះទៅទៀត ហើយតាមទស្សនៈនៃកិច្ចដំណើរការនីតិវិធីនេះ ទោះបីជាបានជួយសម្រួល ប៉ុន្តែមិនមានភាពចាំបាច់នោះទេ។ ហេតុនេះ ការជំទាស់របស់មេធាវីការពារក្តីទាក់ទងនឹងការជ្រើសតាំងអ្នកអាណាព្យាបាលនេះ មិនត្រឹមតែធ្វើឡើងមិនត្រឹមត្រូវនោះទេ ថែមទាំងពុំមានភាពជាប់ពាក់ព័ន្ធផងដែរ។ អង្គហេតុជាប់ពាក់ព័ន្ធ

---

[201] ជាឧទាហរណ៍ ក្នុងប្រព័ន្ធច្បាប់បារាំង ដែលបង្ហាញពីដើមកំណើតរបសបទប្បញ្ញត្តិស្តីពីអ្នកអាណាព្យាបាលតាមក្រមរដ្ឋប្បវេណីកម្ពុជា វិសោធនកម្មថ្មីៗលើក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវជូនដំណឹងដល់អ្នកអាណាព្យាបាលរបស់ជនជាប់ចោទ ហើយថា អ្នកអាណាព្យាបាលអាចពិគ្រោះមើលសំណុំរឿងបាន (ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៧០៦ ដល់ ១១៣)។

[202] បានលើកឡើងក្នុងអត្ថន័យនៃភាពមិនអាចធ្វើទៅបាន និងភាពពុំសមហេតុផល នៅក្នុងសេចក្តីសម្រេចរងការជំទាស់ ជើងទំព័រ ៨៦។

[203] ក្រមរដ្ឋប្បវេណីរបស់កម្ពុជា មាត្រា ១១០៥(៣) ១១០៨ ១១១០ និង១១២៤ ដែលត្រូវបានអានផ្គួបជាមួយនឹង ១១២៥(២)

[204] សេចក្តីសម្រេចលើកទី១ លើបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៧។

សម្រាប់សំណុំរឿងបច្ចុប្បន្ន គឺថា កូនស្រីរបស់ជនជាប់ចោទ បានប្រកាសពីឆន្ទៈរបស់ខ្លួនក្នុងការសហការយ៉ាងពេញលេញជាមួយតុលាការ។ ក្នុងន័យនេះ អ្នកស្រី អៀង វិជីដា បានបង្ហាញវត្តមាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ក្នុងអំឡុងពេលសវនាការថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។ អ្នកស្រី បានអះអាងថា អ្នកស្រីស្នាក់នៅជាមួយជនជាប់ចោទប្រហែលជាបីថ្ងៃក្នុងមួយសប្តាហ៍ ហើយថា អ្នកស្រីជួយជនជាប់ចោទក្នុងការធ្វើកិច្ចការប្រចាំថ្ងៃ រួមទាំងការព្យាបាលផងដែរ[205]។ អ្នកស្រីបានបង្ហាញពីឆន្ទៈរបស់គាត់ក្នុងការសហការជាមួយនឹងតុលាការ និងជួយម្តាយរបស់គាត់ក្នុងការ ឆ្លើយតបទៅនឹងដីកាកោះ ហើយប្រសិនបើចាំបាច់ត្រូវផ្លាស់ប្តូរអាសយដ្ឋាន ត្រូវជូនដំណឹងដល់ តុលាការអំពីការផ្លាស់ប្តូរនេះ[206]។ លើសពីនេះទៀត អ្នកស្រីពុំបានជំទាស់មិនសហការជាមួយនឹង ការអនុវត្តការត្រួតពិនិត្យសុវត្ថិភាពនោះឡើយ ប៉ុន្តែបានលើកឡើងនូវក្តីបារម្ភចំពោះសមត្ថភាព របស់គាត់ក្នុងការបំពេញកិច្ចការនេះជារៀងរាល់សប្តាហ៍ ឬជាទៀងទាត់ ដោយសារតែការរវល់ផ្ទាល់ខ្លួនរបស់គាត់[207]។

65. ជាចុងក្រោយ មានការកត់សម្គាល់ឃើញថា ចាប់តាំងពីជនជាប់ចោទនៅថ្ងៃទី ១៦ ខែ កញ្ញា ត្រូវបានដោះលែង ជនជាប់ចោទ និង អ្នកអាណាព្យាបាលរបស់គាត់ បានសហការជាមួយនឹងតុលាការ និងគោរពតាមវិធានការបណ្តោះអាសន្ន ដែលប្រធានអង្គជំនុំជម្រះបានបង្គាប់នៅក្នុងដីកាសម្រេចរបស់អង្គជំនុំជម្រះលើ សំណើសុំផ្អាក ដោយពុំមានបញ្ហាអ្វីឡើយ។ ជាពិសេស ជនជាប់ចោទបានជូនដំណឹងដល់តុលាការ អំពីអាសយដ្ឋានរបស់គាត់ មិនបានផ្លាស់ប្តូរអាសយដ្ឋានឡើយ បានស្ថិតនៅក្នុងប្រទេសកម្ពុជា និងបានឆ្លើយតបទៅនឹងដីកាកោះដែលតុលាការបានចេញសម្រាប់សវនាការនៅថ្ងៃទី ១៣ ខែ វិច្ឆិកា។ លើសពីនេះទៀត វាហាក់បីដូចជាពុំមានការគំរាមកំហែងដល់សុវត្ថិភាពរបស់ជនជាប់ចោទឡើយ បន្ទាប់ពីដោះលែងគាត់ ហើយពុំមានភ័ស្តុតាងបង្ហាញថា មានការរំខានដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ[208]។

---

[205] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E138/1/10/1.2 ទំព័រ ៤៧។

[206] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E138/1/10/1.2 ទំព័រ ៣៤-៥០។

[207] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E138/1/10/1.2 ទំព័រ ៥៥។

[208] ហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈប្រសិនបើជនជាប់ចោទនៅមានសេរីភាព ត្រូវបានបង្ហាញកាលពីអតីតកាល និងជាមូលដ្ឋានមួយសម្រាប់ការឃុំខ្លួនជនជាប់ចោទមុខសវនាការ (ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ C20 ("ដីកាសម្រេចដំបូងឃុំខ្លួន អៀង ធីរិទ្ធ") កថាខណ្ឌ ៦។ អ.ប.ជ ០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះ ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារ C20/I/27 ("សាលដីការបស់ អ.ប.ជ ឆ្នាំ ២០០៨ ស្តីពី អៀង ធីរិទ្ធ") កថាខណ្ឌ ៦៦-៧១។ ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

66. ក្រៅពីពិនិត្យលើបញ្ហាខាងលើនេះ អង្គជំនុំជម្រះ នឹងពិនិត្យមើលទៅលើវិធានការត្រួតពិនិត្យតាមផ្លូវតុលាការដែលសហព្រះរាជអាជ្ញាបានស្នើឡើង។

### *ការវាយតម្លៃវេជ្ជសាស្ត្រ*

67. សហព្រះរាជអាជ្ញាបានស្នើឲ្យមានការពិនិត្យវាយតម្លៃវេជ្ជសាស្ត្រលើជនជាប់ចោទ ជារៀងរាល់ប្រាំមួយខែម្តង ដើម្បីកំណត់ថាតើមានការប្រែប្រួលកាលៈទេសៈដែលអាចនាំឲ្យមានការបន្តកិច្ចដំណើរការនីតិវិធី ឬយ៉ាងណា[209]។ នៅដំណាក់កាលនេះ ជាដំណាក់កាលដែលជនជាប់ចោទទើបត្រូវបានដោះលែងពីមន្ទីរឃុំឃាំង អ.វ.ត.ក ការវាយតម្លៃវេជ្ជសាស្ត្រគឺជាវិធានការដើម្បីពិនិត្យផ្ទៀងផ្ទាត់ថា ស្ថានភាពជំងឺរបស់ជនជាប់ចោទគឺជាស្ថានភាពពិតប្រាកដ ដើម្បីពិនិត្យការប្រែប្រួល កាលៈទេសៈ និងដើម្បីផ្តល់លទ្ធភាពក្នុងការចាប់ផ្តើមវិធីព្យាបាលថ្មីៗ ប្រសិនបើមាន។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះកត់សម្គាល់ថា ការវាយតម្លៃវេជ្ជសាស្ត្រ គឺជាវិធានការមួយនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ជាពិសេសមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[210]។ វិធានការនេះដាក់ជាប្រចាំងក្នុងករណីដែលជនជាប់ចោទ

---

ឯកសារ C20 (“ដីកាសម្រេចបន្តចិរវេលាឃុំខ្លួនឆ្នាំ ២០០៨ លើ អៀង ធីរិទ្ធ”) កថាខណ្ឌ ៣៣។ ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ C20/8 (“ដីកាសម្រេចបន្តចិរវេលាឃុំខ្លួនឆ្នាំ ២០០៩ លើ អៀង ធីរិទ្ធ”) កថាខណ្ឌ ២៥-២៦។ ដីកាសម្រេចឃុំខ្លួន ដីកាដំណោះស្រាយ កថាខណ្ឌ ១៦២៣។ អ.ប.ជ ១៤៤ និង អ.ប.ជ ១៤៥ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/13 (“សាលដីកាខែមករា ឆ្នាំ២០១១ ស្តីពី អៀង ធីរិទ្ធ”) កថាខណ្ឌ ៥) ។ ស្ថានភាព ខុសគ្នានៅពេលនេះដែលជនជាប់ចោទត្រូវបានដោះលែង ដោយផ្អែកលើមូលដ្ឋានដែលគាត់ពុំមានសម្បទាក្នុងការចូលរួម សវនាការ។ មានការចាត់វិធានការនានាដើម្បីជូនដំណឹងដល់សាធារណជនអំពីហេតុផលក្នុងការធ្វើសេចក្តីសម្រេចនេះ ហើយ វាបង្ហាញឲ្យឃើញនូវការយល់ដឹងច្បាស់ និងទទួលបានជាទូទៅ ក្នុងចំណោមប្រជាជនកម្ពុជា។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានចេញផ្សាយជាសាធារណៈនូវសំណៅដែលបានកែសម្រួលនៃរបាយការណ៍អ្នកជំនាញដែលពាក់ព័ន្ធ។ លើសពីនេះទៀត ផ្នែកកិច្ចការសាធារណៈរបស់ អ.វ.ត.ក បានបោះពុម្ពផ្សាយពិសេសមួយនៃរបាយការណ៍តុលាការដែលផ្តោតជាសំខាន់ផ្តាច់មុខលើការដោះលែងជនជាប់ចោទ (http://www.eccc.gov.kh/en/articles/special-edition-case-002-release-ieng-thirith) និងបានឆ្លើយនូវសំណួរដែលបានចោទសួរជារឿយៗ ពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទ នៅលើគេហទំព័ររបស់ អ.វ.ត.ក (http://www.eccc.gov.kh/en/articles/frequently-asked-questions-related-release-ieng-thirith)។ ព័ត៌មានសាធារណៈនៅតែជាវិធីដ៏ល្អបំផុត នៅក្នុងកាលៈទេសៈនានា ដើម្បីធានានូវការការពារសណ្តាប់ធ្នាប់ សាធារណៈ។

[209] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩។

[210] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២២៣(១១)។

ពុំមានសម្បទាក្នុងការចូលរួមសវនាការ ដោយដីការបស់តុលាការ ឬដោយច្បាប់[211]។ ទាំងនេះគឺក្នុងគោលបំណងដើម្បីដោះស្រាយឧបសគ្គដល់កិច្ចដំណើរការនីតិវិធី និង ជាមួយគ្នានេះដែរ ដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ។

68. អង្គជំនុំជម្រះទទួលស្គាល់ថា ការវាយតម្លៃផ្នែកផ្លូវចិត្តសម្រាប់ជំងឺបាត់ការចងចាំ និងមុខងារបញ្ញាស្មារតី ដែលច្រើនតែពាក់ព័ន្ធនឹងការធ្វើតេស្តការចងចាំ និងបញ្ហាផ្ទាល់ខ្លួនទូទៅ[212] ប៉ះពាល់ដល់សិទ្ធិឯកជន និងកិត្តិយសផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែរ[213] បើទោះបីជាការវាយតម្លៃនោះមានលក្ខណៈរំខានបន្តិចបន្តួចក៏ដោយ។ យ៉ាងណាមិញ អង្គជំនុំជម្រះពិចារណាឃើញថា នៅដំណាក់កាលនេះ មានការប៉ះពាល់សិទ្ធិតិចតួចបំផុត។ ជនជាប់ចោទ ដោយសារតែ លក្ខខណ្ឌរបស់គាត់ទន់ខ្សោយ ត្រូវការការថែទាំផ្នែកវិជ្ជសាស្ត្រ។ យោងទៅតាមលទ្ធផលនៃការវាយតម្លៃផ្នែកវិជ្ជសាស្ត្រក្នុងការវិភាគជំងឺ និងអនុសាសន៍នៃការព្យាបាល មានភាពស្របគ្នារវាងប្រយោជន៍របស់ជនជាប់ចោទ និងប្រយោជន៍យុត្តិធម៌ ដែលតម្រូវឱ្យផ្តល់ព័ត៌មានជាបន្តបន្ទាប់ទាក់ទងនឹងបញ្ហាសុខភាពស្មារតីរបស់ជនជាប់ចោទ។

69. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ឱ្យជនជាប់ចោទទទួលការវាយតម្លៃផ្នែកវេជ្ជសាស្ត្រជាទៀងរាល់ប្រាំមួយខែម្តង។ បន្ទាប់ពីមានការវាយតម្លៃនេះ ត្រូវមានរបាយការណ៍ជូនអង្គជំនុំជម្រះ

---

[211] នៅកម្រិតអន្តរជាតិ ការវាយតម្លៃផ្នែវិជ្ជសាស្ត្រ ត្រូវបានចាត់ទុកថាជាការដាក់លក្ខខណ្ឌលើការដោះលែងនៅក្នុងរឿងក្តីមួយចំនួនពាក់ព័ន្ធនឹងជនជាប់ចោទ មិនមានសម្បទាចូលរួមសវនាការ។ សូមមើលសេចក្តីសម្រេចលើរឿងក្តី Talic ទំព័រ ៩ (បង្គាប់ឱ្យជនជាប់ចោទប្រតិបត្តិតាមការវាយតម្លៃជារៀងរាល់ខែពីអ្នកឯកទេសវេជ្ជសាស្ត្រ)។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Kovačević*, IT-01-42 "សេចក្តីសម្រេចលើការដោះលែងបណ្តោះអាសន្ន" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៤ ផ្នែកសម្រេចសេចក្តី (បង្គាប់ឱ្យមានការវាយតម្លៃវេជ្ជសាស្ត្រជារៀងរាល់ខែទីពីរជូនដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យជំនុំជម្រះធ្វើការវិនិច្ឆ័យស្ថានភាពវេជ្ជសាស្ត្ររបស់ជនជាប់ចោទ)។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Stanišić* និង *Simotović*, IT-03-69-PT "សេចក្តីសម្រេចលើការដោះលែងបណ្តោះអាសន្ន" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៦៨(២) (បង្គាប់ឱ្យវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទធ្វើការវាយតម្លៃ និងរាយការណ៍ជូន អង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងរយៈពេលនៃការស្នាក់នៅរបស់គាត់)។ ប្រការនេះគឺជាការអនុវត្តជាទូទៅផងដែរនៅកម្រិតជាតិ ដូចដែលបានពិភាក្សាយ៉ាងច្រើនពីខាងលើ។

[212] របាយការណ៍សង្ខេបរបស់អ្នកជំនាញ ឆ្នាំ ២០១២, កថាខណ្ឌ ៤៦-៥១ (ដែលបញ្ជាក់ជាលម្អិតអំពីវិធីសាស្ត្រដែលអ្នកជំនាញបានប្រើប្រាស់ដើម្បីវាយតម្លៃអំពីកម្រិតនៃការធ្លាក់ចុះផ្នែកសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ)។

[213] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៩ (ដែលចែងអំពីសិទ្ធិទទួលបាន "សន្តិសុខរបស់មនុស្ស" និងមាត្រា ១៧ ដែលចែងថា "គ្មានជនណាម្នាក់ទទួលរងការជ្រៀតជ្រែករំខានតាមទំនើងចិត្តដោយខុសច្បាប់ទៅលើភាពឯកជនរបស់គាត់ឡើយ")។ *សូមមើល រឿងក្តី MG v. Germany* , គណកម្មការស្តីពីសិទ្ធិមនុស្ស លេខ 1482/2006 ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៨ CCPR/C/93/D/1482/2006, កថាខណ្ឌ ១០.១; M. Nowak, U.N. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ– សេចក្តីអត្ថាធិប្បាយ CCPR, Engel Publisher, Strasbourg ឆ្នាំ ១៩៩៣ ទំព័រ ២៩៥។

សាលាដំបូងដើម្បីឲ្យអង្គជំនុំជម្រះពិនិត្យមើលរបាយការណ៍នេះឡើងវិញ និងដើម្បីចាត់វិធានការបន្ថែមទៀត ប្រសិនបើអង្គជំនុំជម្រះកត់សម្គាល់ឃើញអំពីការប្រែប្រួលនៃកាលៈទេសៈ។ អង្គជំនុំជម្រះតុលាការកំពូលសូមបញ្ជាក់បំភ្លឺថាខ្លួនពុំរំពឹងថា អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការវាយតម្លៃអំពីសមត្ថភាពសម្បទារបស់ជនជាប់ចោទជារៀងរាល់ប្រាំមួយខែម្តងនោះទេ ប៉ុន្តែ ខ្លួនរំពឹងថា អង្គជំនុំជម្រះសាលាដំបូងនឹងវាយតម្លៃថាតើវាជាការចាំបាច់ដែរ ឬយ៉ាងណា ក្នុងការធ្វើការវាយតម្លៃនេះ ដោយពិនិត្យទៅលើរបាយការណ៍វេជ្ជសាស្ត្រដែលនឹងត្រូវប្រគល់ឲ្យ។

***ការប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ ការតព្វកិច្ចក្នុងការរាយការណ៍អំពីអាសយដ្ឋាននាពេលបច្ចុប្បន្ន និងការផ្លាស់ប្តូរអាសយដ្ឋានណាមួយ និងការត្រួតពិនិត្យរបស់នគរបាល***

70. សហព្រះរាជអាជ្ញាបានស្នើសុំលក្ខខណ្ឌមួយចំនួនដើម្បីធានាបានថា ជនជាប់ចោទនៅតែមានវត្តមាននៅតុលាការ និងពុំគេចខ្លួនចេញពីដែនសមត្ថកិច្ចរបស់តុលាការ ពោលគឺ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ ស្នាក់នៅអាសយដ្ឋាន ដែលសហមេធាវីរបស់ជនជាប់ចោទបានផ្តល់ជូន[214] និងទទួលការត្រួតពិនិត្យសុវត្ថិភាពជារៀងរាល់ សប្តាហ៍ពីសំណាក់មន្ត្រីដែលតុលាការបានតែងតាំង[215]។

71. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា កត្តាមួយចំនួនត្រូវបានចាត់ទុកកាលពីពេល កន្លងទៅថាជាសញ្ញាបង្ហាញអំពីហានិភ័យដែលអាចមាន ដែលជនជាប់ចោទអាចមិនមានវត្តមាន ពេលតុលាការត្រូវការ និងបានប្រើប្រាស់សញ្ញាបង្ហាញហានិភ័យទាំងនេះជាមូលដ្ឋានមួយដើម្បីដាក់គាត់ក្រោមការឃុំខ្លួនបណ្តោះអាសន្ន។ កត្តាទាំងនេះរួមបញ្ចូលទាំងមធ្យោបាយរបស់ជនជាប់ចោទ[216] ដែលរួមទាំងលំនៅដ្ឋានឯបរទេស[217] ចំនួនតិចតួចនៃកិច្ចព្រមព្រៀងបត្យាប័នរវាងកម្ពុជា និង ប្រទេសដទៃទៀត[218] ទម្ងន់នៃបទចោទ និងលទ្ធភាពនៃការដាក់ជនជាប់ចោទឲ្យជាប់ពន្ធនាគារអស់ មួយជីវិត[219]

---

[214] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៥។

[215] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៤។

[216] ដីកាឃុំខ្លួនដើមពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៨; សេចក្តីសម្រេចរបស់ អ.ប.ជ ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៥៦, ដីកាបន្តចិរវេលាឃុំខ្លួនក្នុងឆ្នាំ ២០០៨ ពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ២៨, សេចក្តីសម្រេចលើសំណើបន្ទាន់ស្នើសុំដោះលែង នួន ជា, ខៀវ សំផន, និង អៀង ធីរិទ្ធ ជាបន្ទាន់, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E50, ("សេចក្តីសម្រេចដោះលែងរបស់អង្គជំនុំជម្រះសាលាដំបូង ខែ កុម្ភៈ ឆ្នាំ ២០១១")កថាខណ្ឌ ៤១។

[217] ដីកាឃុំខ្លួនដើមពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ២៨។

[218] ដីកាឃុំខ្លួនដើមពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៨។ ដីកាបន្តចិរវេលាឃុំខ្លួន *អៀង ធីរិទ្ធ* ឆ្នាំ ២០០៨, កថាខណ្ឌ ២៨។

បណ្តាញនៃអ្នកគាំទ្ររបស់ជនជាប់ចោទ ដែលមានមុខតំណែងធំៗទាំងនៅក្នុងប្រទេស និងបរទេស[220] ដំណាក់កាលនៃកិច្ចដំណើរការស៊ើបសួរ ដែលជាមានជាអាទិ ដីកាដំណោះស្រាយ ការឯកភាពអំពីការបញ្ជូនរឿងទៅជំនុំជម្រះ និងការផ្អាកជាបណ្តោះអាសន្ន ដោយរង់ចាំការព្យាបាលផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានធ្វើក្នុងកិច្ចខិតខំ ដើម្បីធ្វើឲ្យជនជាប់ចោទមានសម្បទាគ្រប់ គ្រាន់ដើម្បីចូលរួមសវនាការ[221]។

72. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ហានិភ័យនៃការរត់គេចខ្លួន ដែលធ្លាប់ត្រូវបានចង្អុលបង្ហាញកាលពីពេលមុន ត្រូវបានកាត់បន្ថយយ៉ាងច្រើនដោយចំណុចថ្មីៗមួយចំនួន។ ទីមួយ ចេតនារបស់ជនជាប់ចោទដើម្បីគេចខ្លួន ដោយគិតទុកជាមុន ចេញពីដែនសមត្ថកិច្ចរបស់តុលាការ ត្រូវបានកាត់បន្ថយ តាមរយៈការផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានពេលកំណត់ និងលទ្ធភាពនៃការពុំមានការជំនុំជម្រះ[222]។ ជាការពិត អង្គជំនុំជម្រះតុលាការកំពូលពុំបានដឹងអំពីការប៉ុនប៉ងណា មួយ

---

[219] ដីកាឃុំខ្លួនដើមពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៨-៩។ សេចក្តីសម្រេចរបស់ អ.ប.ជ ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៥៣, ដីកាបន្តចិរវេលាឃុំខ្លួន អៀង ធីរិទ្ធ ឆ្នាំ ២០០៨, កថាខណ្ឌ ២៨, សេចក្តីសម្រេចដោះលែងក្នុងឆ្នាំ ២០១១ ខែ កុម្ភៈ របស់ អ.ជ.ស.ដ, កថាខណ្ឌ ៤១។

[220] សេចក្តីសម្រេចរបស់ អ.ប.ជ ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៥៤-៥៥។

[221] សេចក្តីសម្រេចលើការឃុំខ្លួនដោយអនុលោមតាមដីកាដំណោះស្រាយ, កថាខណ្ឌ ១៦២៣។ សេចក្តីសម្រេចក្នុងខែ មករា ឆ្នាំ ២០១១ ពាក់ព័ន្ធនឹង *អៀង ធីរិទ្ធ*, កថាខណ្ឌ ៥, សេចក្តីសម្រេចលើបញ្ហាសម្បទា, កថាខណ្ឌ ៤២ (ការព្យាបាលនឹងត្រូវធ្វើដើម្បីធ្វើឲ្យជនជាប់ចោទមានវត្តមានសម្រាប់ការជំនុំជម្រះ), 47 (ដើម្បីធានាបានថាជនជាប់ចោទបានទទួលការព្យាបាល និងពុំមែនអវត្តមានដោយខ្លួនឯងឡើយ)។

[222] ជនជាប់ចោទពុំសូវមានចេតនាចង់គេចខ្លួនឡើយ នៅពេលប្រឈមជាមួយលទ្ធភាពនៃការជំនុំជម្រះ ខុសពីការជំនុំជម្រះដែលជិតមកដល់ (អ.ប.ជ ១៥២, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការពន្យារចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី ដោយអនុលោមតាមដីកាដំណោះស្រាយ, អង្គបុរេជំនុំជម្រះ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១, ឯកសារ D427/5/10 ("សេចក្តីសម្រេចក្នុងខែ មករា ឆ្នាំ ២០១១ ពាក់ព័ន្ធនឹង *អៀង សារី*, កថាខណ្ឌ ៣៦ (ដែលបានកត់សម្គាល់ឃើញថាការឯកភាពអំពីការបញ្ជូនរឿងទៅជំនុំជម្រះ ផ្តល់ភាពសមហេតុផលដល់ការឃុំខ្លួន)។ ស្រដៀងគ្នានេះ ទម្ងន់នៃឧក្រិដ្ឋកម្ម និងការផ្តន្ទាទោសដែលអាចមាន រមែងត្រូវបានលើកយកមកពិចារណា បើទោះបីជាទាំងនេះពុំមានជាកត្តាសម្រេចក៏ដោយ (*សូមមើល ក្នុងចំណោមប្រការផ្សេងៗ៖* អង្គជំនុំជម្រះតុលាការកំពូល04, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន លើសំណើសុំដោះលែង, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E50/3/1/4, ("សេចក្តីសម្រេចក្នុងខែ មិថុនា ឆ្នាំ ២០១១ ពាក់ព័ន្ធនឹង *ខៀវ សំផន*'), កថាខណ្ឌ ៤០។ សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង* Popović et al., លេខសំណុំរឿងIT-05-88-AR65.2, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធការដោះលែង Ljobomir Borovčanin ជាបណ្តោះអាសន្ន, អង្គជំនុំជម្រះតុលាឧទ្ធរណ៍, ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៧, កថាខណ្ឌ ១៤ ("ចេតនាគេចខ្លួន អាចធ្លាក់ចុះទៅតាមពេលវេលា។ ក្នុងសំណុំរឿងផ្សេងទៀត ចេតនាទាំងនេះ

ក្នុងការគេចខ្លួនចេញពីដែនយុត្តាធិការរបស់តុលាការឡើយ ចាប់តាំងពីជនជាប់ចោទត្រូវបានដោះលែង កាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២។ ផ្ទុយមកវិញ គាត់បានបង្ហាញខ្លួនដូចតាមការរំពឹងនៅចំពោះមុខ អង្គជំនុំជម្រះនេះ នៅពេលដែលគាត់ត្រូវបានកោះហៅ។ ក្នុងអំឡុងពេលសវនាការនៅចំពោះមុខអង្គ ជំនុំជម្រះនេះ ជនជាប់ចោទ និងអ្នកអាណាព្យាបាលរបស់គាត់បាន បង្ហាញយ៉ាងច្បាស់អំពីចេតនា របស់ពួកគាត់ក្នុងការបន្តស្ថិតនៅក្នុងប្រទេសកម្ពុជា ហើយអង្គជំនុំ ជម្រះតុលាការកំពូលពុំមានហេតុផល សង្ស័យថា ចម្លើយទាំងនេះពុំមានភាពស្មោះត្រង់ឡើយ[223]។ លើសពីនេះទៀត ស្ថានភាពនាពេលបច្ចុប្បន្ន របស់ជនជាប់ចោទ ដែលអង្គជំនុំជម្រះអាចទទួលស្គាល់ក្នុងអំឡុងពេលសវនាការនេះ ស្ទើរតែធ្វើឲ្យ ពុំមានលទ្ធភាពទាល់តែសោះដែលថាគាត់នឹងមានសមត្ថភាព ប្រសិនបើគាត់ចង់ ក្នុងការចាកចេញពី ប្រទេសកម្ពុជាដោយខ្លួនឯង ឬទៅលាក់ខ្លួន នោះ។

73. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការចាំបាច់ដើម្បីឲ្យខ្លួនដឹងអំពីទីកន្លែងស្នាក់នៅរបស់ជន ជាប់ចោទ ដើម្បីឲ្យអង្គជំនុំជម្រះអាចទាក់ទងទៅគាត់ក្នុងករណីចាំបាច់នៅថ្ងៃខាងមុខ និងធានាបានថា ការវាយតម្លៃផ្នែកវេជ្ជសាស្ត្រដែលខ្លួនបានបង្គាប់ អាចត្រូវបានធ្វើឡើង។ ក្នុងន័យនោះ ជនជាប់ចោទ តាមរយៈអ្នកអាណាព្យាបាលរបស់គាត់ ត្រូវប្រគល់អាសយដ្ឋានរបស់គាត់ទៅតុលាការ និងជូនដំណឹង ទៅតុលាការ មុនពេលមានការផ្លាស់ប្តូរអាសយដ្ឋានណាមួយ។ ត្រង់ប្រការនេះ អង្គជំនុំជម្រះតុលាការ កំពូលកត់សម្គាល់ឃើញថា តុលាការក្រុងភ្នំពេញបានបង្គាប់រួចហើយ ឲ្យអ្នកអាណាព្យាបាលជនជាប់ ចោទ រាយការណ៍ពីអាសយដ្ឋានជនជាប់ចោទមក អ.វ.ត.ក[224]។ ជនជាប់ចោទមានសេរីភាពក្នុងការ ផ្លាស់ប្តូរទីលំនៅរបស់គាត់នៅក្នុងដែនដីនៃប្រទេសកម្ពុជា លុះត្រាតែតុលាការបានទទួលការជូនដំណឹង ទុកជាមុន។ លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូលកត់ សម្គាល់ឃើញថា ថ្វីបើតុលាការមានមធ្យោ បាយដើម្បីអនុវត្តយុត្តាធិការលើជនជាប់ចោទ នៅពេលដែលគាត់ស្ថិតនៅក្នុងដែនដីនៃប្រទេសកម្ពុជា ដោយហេតុថា ខ្លួនអាចពឹងផ្អែកលើនគរបាលយុត្តិធម៌របស់ខ្លួន[225] ព្រមទាំងកិច្ចសហការរបស់រដ្ឋា

---

អាចនៅដដែល ហើយនៅក្នុងសំណុំរឿងដទៃទៀត ចេតនាទាំងនេះអាចប្រែប្រួលសមល្មមដើម្បីប៉ះពាល់ដល់វិធីសាស្ត្រដែល បានអនុវត្តនៅក្នុងសេចក្តីសម្រេចដោះលែងបណ្តោះអាសន្នមុនៗ ពាក់ព័ន្ធនឹងជនជាប់ចោទដដែល")។

[223] ប្រតិចារឹក, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E138/1/10/1.2, ទំព័រ ៤៣ (អៀង ធីរិទ្ធ), ទំព័រ ៣៩-៤៣,៥២ (អៀង វិច្ឆិដា)។

[224] សេចក្តីសម្រេចពាក់ព័ន្ធនឹងអាណាព្យាបាល, ទំព័រ ៣។

[225] វិធាន១៥ នៃវិធានផ្ទៃក្នុង។

ភិបាលកម្ពុជាក៏ដោយ[226] ក៏វាជាការលំបាកខ្លាំងដើម្បីធ្វើដូច្នេះ ប្រសិនបើជនជាប់ចោទស្ថិតនៅឯបរទេស ។ ក្នុងករណីនេះ ខ្លួននឹងត្រូវការពឹងផ្អែកលើការ សហការរបស់បរទេស ដែលភាគច្រើននៃប្រទេសទាំងនោះពុំមានសន្ធិសញ្ញានៃកិច្ចសហការ ជាមួយកម្ពុជាឡើយ[227]។ ហេតុដូច្នេះ ជាការចាំបាច់ក្នុងការបង្គាប់ឱ្យជនជាប់ចោទបន្តស្ថិតនៅក្នុងដែនដីនៃប្រទេសកម្ពុជា លើកលែងតែមានការអនុញ្ញាតពីតុលាការនេះ ដើម្បីឱ្យជនជាប់ចោទចាក ចេញពីប្រទេសកម្ពុជា។

74. បើទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការពុំចាំបាច់ និងពុំមានសមាមាត្រ ក្នុងការរក្សាទុកអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនរបស់ជនជាប់ចោទ។ បើទោះបីជាអ្នកអាណាព្យាបាលរបស់ជនជាប់ចោទពុំបង្ហាញការជំទាស់ណាមួយចំពោះការដែល តុលាការរក្សាទុកឯកសារទាំងនេះ និងពុំបានចង្អុលបង្ហាញអំពីតម្រូវការផ្ទាល់ភ្លាមៗណាមួយចំពោះឯកសារទាំងនេះក៏ដោយ[228] ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វាពាក់ព័ន្ធនឹងសេចក្តីថ្លៃថ្នូររបស់ជនជាប់ចោទ ក្នុងការទទួលបានឯកសារអត្តសញ្ញាណរបស់គាត់ ហើយវា ពុំមានភាពសមហេតុផល ក្នុងកាលៈទេសៈនាពេលបច្ចុប្បន្ន ក្នុងការដកហូតឯកសារទាំងនេះពី ជនរងគ្រោះឡើយ។ ហេតុដូច្នេះ លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់ជនជាប់ចោទ ត្រូវ ប្រគល់ត្រឡប់ទៅឱ្យអ្នកអាណាព្យាបាលទូទៅរបស់ជនជាប់ចោទ ជាអ្នកថែរក្សា ដោយភ្ជាប់ជាមួយនូវការបញ្ជាក់ថា ឯកសារទាំងនេះពុំត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការធ្វើ ដំណើរទៅបរទេស ដោយពុំមានការអនុញ្ញាតរបស់តុលាការនោះទេ។

75. ជាងនេះទៀត ដោយពុំមានការធានាជាក់លាក់ពីសំណាក់ជនជាប់ចោទដែលថាគាត់នឹងអនុវត្តតាមវិធាននៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលបានរៀបរាប់ខាងលើ[229] អង្គជំនុំជម្រះតុលាការកំពូល

---

[226] រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ច ក្រោមកិច្ចព្រមព្រៀង អ.វ.ត.ក ដើម្បីសម្របសម្រួលដល់ការអនុវត្តដីកាចាប់ខ្លួន និងសហការជាមួយតុលាការ (កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ២៥)។

[227] អង្គជំនុំជម្រះនេះបានដឹងត្រឹមតែអំពីកិច្ចព្រមព្រៀងបត្យាប័នចំនួន ៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋដទៃទៀត ដែលមានជាអាទិ៍៖ ប្រទេសថៃ (ឆ្នាំ ១៩៩៨), ប្រទេសចិន (ឆ្នាំ ២000), និងឡាវ (ឆ្នាំ ២០០៥) (ដែលមានជាភាសាខ្មែរនៅលើគេហទំព័រ http://cambodia.ohchr.org/klc_pages/klc_section14.htm)។ កិច្ចព្រមព្រៀងមួយទៀតក៏ត្រូវបានចុះហត្ថលេខាជាមួយប្រទេស អូស្ត្រាលី (ឆ្នាំ ២០០៧) (ដែលមាននៅលើគេហទំព័រ http://www.austlii.edu.au/au/other/dfat/treaties/2009/4.html)។

[228] ប្រតិចារឹក, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E138/1/10/1.2, ទំព័រ ៤៩-៥១។

[229] កត្តានានាដែលលើកយកមកពិចារណាក្នុងការវាយតម្លៃអំពីលទ្ធភាពដែលថា ជនជាប់ចោទនឹងគោរពតាមលក្ខខណ្ឌរបស់តុលាការ រួមបញ្ចូលទាំងការធានាអះអាងផ្ទាល់ខ្លួនដើម្បីគោរពតាមលក្ខខណ្ឌ និងការបង្គាប់របស់តុលាការ ដែលឆ្លុះបញ្ចាំងអំពីសុទ្ធចិត្ត

ពិចារណាឃើញថាជាការសមស្របក្នុងការបង្គាប់ឲ្យមានការចុះពិនិត្យនៅឯលំនៅដ្ឋានរបស់គាត់ ពីសំណាក់នគរបាលយុត្តិធម៌ ឬអាជ្ញាធរមូលដ្ឋានដែលត្រូវបានចាត់តាំង ជារៀងរាល់មួយខែម្តង ដើម្បីផ្ទៀងផ្ទាត់អំពីការអនុវត្តតាមលក្ខខណ្ឌទាំងនេះ[230]។ ការចុះពិនិត្យទាំងនេះគួរមានលក្ខណៈរំខានតិចតួចបំផុត និងបម្រើដល់គោលបំណងនៃការផ្ទៀងផ្ទាត់ថាតើជនជាប់ចោទនៅតែស្នាក់អាស្រ័យនៅឯអាសយដ្ឋាន ដែលគាត់បានប្រគល់ជូនតុលាការ ហើយគាត់ពុំទាន់បានចាកចេញពីប្រទេសកម្ពុជា។ ការព្រួយបារម្ភណាមួយអំពីសុវត្ថិភាពរបស់ជនជាប់ចោទ ប្រសិនបើបញ្ហានេះកើតមាន ក៏អាចត្រូវបានកត់សម្គាល់ផងដែរ ដោយអនុលោមតាមកាតព្វកិច្ចរបស់រដ្ឋអំណាចកម្ពុជាក្នុងការធានាសុវត្ថិភាពរបស់

---

របស់ជនជាប់ចោទ (*សូមមើល ក្នុងចំណោមប្រការផ្សេងៗ៖ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Galić, សំណុំរឿងលេខ IT-98-29-A, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្នើសុំដោះលែង Stanislav Galić ជាបណ្តោះអាសន្ន, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥,("សេចក្តីសម្រេចលើរឿងក្តី *Galić*") កថាខណ្ឌ ១៦ ("ការពិតដែលថាម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រៀមខ្លួនដើម្បីទទួលយកការបង្គាប់ណាមួយរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ស្តីពីលក្ខខណ្ឌសម្រាប់ការដោះលែងបណ្តោះអាសន្ន បញ្ជាក់អំពីសុច្ឆន្ទចិត្តរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍")។ សំណុំរឿង*រដ្ឋអាជ្ញា ទល់នឹង* Norman *ជនដទៃទៀត*, សំណុំរឿងលេខ SCSL-04-14-AR65, Fofana – បណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចដែលបដិសេធការស្នើសុំឲ្យនៅក្រៅឃុំ, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥, ("សេចក្តីសម្រេចលើរឿងក្តី *Norman*")កថាខណ្ឌ ២៣ ("ភស្តុតាងដែលគាំទ្រប្រសើរបំផុតដល់ការសម្រេចប្រកបដោយភាពត្រឹមត្រូវអំពីសំណើសុំនៅក្រៅឃុំគឺជាភស្តុតាងនៃការធានារបស់ជនជាប់ចោទដែលថា គាត់នឹងចូលរួមសវនាការ និងពុំបង្កគ្រោះថ្នាក់ដល់ជនដទៃ") និងសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Sesay et al.*, សំណុំរឿងលេខ SCSL-04-15-AR65, Sesay – សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការបដិសេធសំណើសុំនៅក្រៅឃុំ, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤, កថាខណ្ឌ ៣៦ ("ថ្វីបើជាគោលការណ៍ ចៅក្រមអាចជឿជាក់ថាជនជាប់ចោទណាម្នាក់ នឹងបង្ហាញខ្លួនសម្រាប់ការជំនុំជម្រះក៏ដោយ [ការធានាផ្សេងៗ] នៅពេលដំណាលគ្នានេះ លក្ខខណ្ឌ និងការធានាចាំបាច់ត្រូវប្រកបដោយអត្ថន័យ")។

[230] ការធានាផ្ទាល់ខ្លួនពុំគ្រប់គ្រាន់អាចត្រូវបានបន្ធូរបន្ថយដោយការធានាដែលអាចជឿជាក់បានអំពីកិច្ចសហការរបស់រដ្ឋាភិបាល ឬយន្តការអនុវត្តរបស់តុលាការ ដូចជា កងកម្លាំងនគរបាល ជាដើម (*សូមមើល* ក្នុងចំណោមឯកសារផ្សេងៗ សេចក្តីសម្រេចលើរឿងក្តី *Norman* កថាខណ្ឌ ៤៣ (ដោយពិចារណាឃើញថាការដោះលែងពុំអាចធ្វើទៅបាន នៅពេលដែលនគរបាលមូលដ្ឋានបានអះអាងថាខ្លួនគ្មានសមត្ថភាពដើម្បីតាមដានជនជាប់ចោទ ហើយការធានាផ្ទាល់ខ្លួនពុំទាន់គ្រប់គ្រាន់)។ សេចក្តីសម្រេចលើរឿងក្តី *Galić*, កថាខណ្ឌ ១២។ នៅឯតុលាការ ICTY អ្នកធានាដែលជារដ្ឋាភិបាលចាត់វិធានការ ក្នុងចំណោមសកម្មភាពផ្សេងៗ ដើម្បីធានាបានការអនុវត្តតាមលក្ខខណ្ឌនានា, រួមទាំងការតាមដានអំពីវត្តមានរបស់ជនជាប់ចោទនៅឯ អាសយដ្ឋានដែលត្រូវបានផ្តល់ឲ្យ (*សូមមើលក្នុងចំណោមឯកសារផ្សេងៗ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Čermak and Markač*, សំណុំរឿងលេខ IT-03-73-AR65.1, សេចក្តីសម្រេចលើបន្ទាន់ឧទ្ធរណ៍បន្ទាន់បង្ខំជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធការដោះលែងជាបណ្តោះអាសន្ន, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៤, កថាខណ្ឌ ៤៤ (ខ))។

ជនជាប់ចោទ[231]។ យ៉ាងណាមិញ ត្រង់ចំណុចនេះ មានការកត់សម្គាល់ឃើញថា ហាក់ដូចជាពុំមានការគំរាមកំហែងជាក់លាក់ណាមួយដល់សុវត្ថិភាពរបស់ជនជាប់ចោទឡើយ។ របាយការណ៍សង្ខេបមួយត្រូវប្រគល់ទតុលាការជារៀងរាល់ខែ ដោយផ្តោតជាសំខាន់ទៅលើការជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង នៅក្នុងករណីមានការប្រែប្រួលណាមួយ ចំពោះស្ថានភាពរបស់ជនជាប់ចោទ។ ម្យ៉ាងទៀត ជនជាប់ចោទតាមរយៈអ្នកអាណាព្យាបាលរបស់គាត់ ត្រូវបានផ្តល់ឱ្យនូវលទ្ធភាពនៃការផ្ញើដោយខ្លួនគាត់ផ្ទាល់នូវរបាយការណ៍សង្ខេបជូនតុលាការជារៀងរាល់ខែ។

76. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខខណ្ឌដែលបានលើកឡើងខាងលើ គឺជាការកំហិតជាអប្បបរមាចំពោះសិទ្ធិធ្វើដំណើរដោយសេរី[232] ដែលសមមាត្រទៅនឹងគោលបំណងក្នុងការធ្វើឱ្យជនជាប់ចោទមានវត្តមាននៅក្នុងតុលាការ នៅពេលដែលដំណើរការនីតិវិធីលើរូបគាត់ ពុំទាន់បានចប់នៅឡើយ។

---

[231] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ២៤។

[232] មាត្រា១៣ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សចែងថា (“មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋនីមួយៗ។... មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ”)។ *សូមមើលផងដែរ* មាត្រា១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ជនណាដែលរស់នៅស្របច្បាប់ក្នុងប្រទេសណាមួយ មានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសដ្ឋានរបស់ខ្លួនដោយសេរី។ ជនគ្រប់រូប មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង។ សិទ្ធិដែលបានចែងខាងលើនេះ មិនត្រូវមានការរឹតត្បិតឡើយ លើកលែងតែការរឹតត្បិតនេះ មានចែងក្នុងច្បាប់ ដែលចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិនិងសេរីភាពអ្នកដទៃ ហើយត្រូវស៊ីសង្វាក់គ្នាជាមួយនឹងសិទ្ធិដទៃទៀត ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ”)។*រឿងក្តី R v Beare* [1988] 2 S.C.R. 387 (ប្រទេសកាណាដា) (នៅពេលដែលបុគ្គលត្រូវបានគេបង្ខំឱ្យបង្ហាញខ្លួននៅពេលវេលា និងទីកន្លែងច្បាស់លាស់ណាមួយដើម្បីផ្តិតមេដៃ ករណីនេះគឺជាការកំហិតលើសិទ្ធិសេរីភាពរបស់បុគ្គលនោះ)។ *សូមមើលរឿងក្តី Liakat Ali Alibux, Suriname* គណៈកម្មាធិការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស ឯកសារលេខ ៣២ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ១០០ (“ទាក់ទិននឹងបញ្ហាសមាមាត្រ តុលាការបានពិចារណាថា ការកំណត់លើសិទ្ធិចាកចេញពីប្រទេសដែលត្រូវបានដាក់ក្នុងអំឡុងពេលកិច្ចដំណើរការព្រហ្មទណ្ឌតាមមធ្យោបាយនៃវិធានការប្រុងប្រយ័ត្ន គួរតែសមាមាត្រនឹងគោលបំណងគតិយុត្តិដែលស្នើសុំ ដូចនេះវាអាចអនុវត្តបាន នៅពេលដែលមិនមានវិធានការមិនសូវតឹងរ៉ឹង និងក្នុងអំឡុងពេលដែលចាំបាច់បំផុតដើម្បីអនុវត្តគោលបំណងនេះ”)។ M. Nowak, U.N. កតិកាសញ្ញាស្តីពីសិទ្ធិនយោបាយ និងពលរដ្ឋ– សេចក្តីអត្ថាធិប្បាយ CCPR, Engel Publisher, Strasbourg, ឆ្នា ១៩៩៣, ទំព័រ ២១៣ (“រដ្ឋមានសិទ្ធិមានកម្រិតក្នុងការរារាំង បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ មិនឱ្យចាក់ចេញពីដែនដីរបស់រដ្ឋ (ដូចជា តាមរយៈការឃុំខ្លួនបណ្តោះអាសន្ន ឬរឹបអូសយកលិខិតឆ្លងដែន”)។

*ការទាក់ទងជាមួយសហជនជាប់ចោទ សាក្សី និងជនរងគ្រោះ និងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ*

77. សហព្រះរាជអាជ្ញាស្នើសុំឲ្យហាមឃាត់ជនជាប់ចោទ កុំឲ្យទាក់ទងដោយត្រង់ៗក្តី ឬដោយប្រយោលក្តី ជាមួយនឹងសហជនជាប់ចោទដទៃទៀត (លើកលែងតែស្វាមីរបស់គាត់ គឺលោក អៀង សារី) និងកុំឲ្យទាក់ទងជាមួយនឹងសាក្សី អ្នកជំនាញ ឬជនរងគ្រោះរូបណាក៏ដោយ ដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើសុំស្តាប់ចម្លើយ និងមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការទេ[233]។

78. អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា ការហាមឃាត់មិនឲ្យជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ គឺជាកាតព្វកិច្ចជាសាកលមួយ ដូច្នេះជនជាប់ចោទ ដូចគ្នានឹងប្រជាពលរដ្ឋផ្សេងទៀតដែរ គឺត្រូវតែអនុវត្តកាតព្វកិច្ចនេះ[234]។ បើតាមវិធានការបន្ថែមនានាដែលត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញាដើម្បីហាមឃាត់ជាពិសេសចំពោះជនជាប់ចោទ កុំឲ្យទាក់ទងជាមួយបុគ្គលមួយចំនួន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា វិធានការបន្ថែមទាំងនេះ មិនចាំបាច់នៅក្នុងកាលៈទេសៈនាពេលបច្ចុប្បន្ននោះទេ។

79. នៅដំណាក់កាលពីមុន កត្តាជាច្រើន ត្រូវបានចាត់ទុកថាបានបង្កើតជាហានិយភ័យសំខាន់មួយដែលជនជាប់ចោទអាចជ្រៀតជ្រែកសាក្សី ឬជនរងគ្រោះ និងក្លែងបន្លំភ័ស្តុតាង ដោយរួមបញ្ចូលទាំងការពិនិត្យមើលលើសំណុំរឿង ដែលមានព័ត៌មានលម្អិត ដែលសម្រួលដល់ការទាក់ទង និងជ្រៀតជ្រែកសាក្សី និងជនរងគ្រោះ[235] អតីតតួនាទីរបស់ជនជាប់ចោទដ៏មានឥទ្ធិពល និងបណ្តាញនៃអ្នកគាំទ្រជាច្រើននៅក្នុងតួនាទីដ៏មានឥទ្ធិពល ដោយអ្នកមួយចំនួនជាអ្នកឃាមប្រដាប់អាវុធ[236] ភាព ធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម[237] ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ពោលគឺ ការបន្តការស៊ើបអង្កេត ដីកាដំណោះស្រាយ និង

[233] សារណាបណ្តឹងសាទុក្ខបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៧។

[234] វិធាន៣៥ នៃវិធានផ្ទៃក្នុង។

[235] ដីកាសម្រេចដំបូងឃុំខ្លួន *អៀង ធីរិទ្ធ* កថាខណ្ឌ៧។ សាលដីការបស់ អ.ប.ជ ឆ្នាំ២០០៨ ស្តីពី *អៀង ធីរិទ្ធ* កថាខណ្ឌ៤៥។ ដីកាសម្រេចបន្តថិរវេលាឃុំខ្លួន ឆ្នាំ២០០៨ លើ អៀង ធីរិទ្ធ កថាខណ្ឌ២៦។

[236] ដីកាសម្រេចដំបូងឃុំខ្លួន *អៀង ធីរិទ្ធ* កថាខណ្ឌ៧។ សាលដីការបស់ អ.ប.ជ ឆ្នាំ២០០៨ ស្តីពី *អៀង ធីរិទ្ធ* កថាខណ្ឌ៤៥-៤៧។

[237] ដីកាសម្រេចដំបូងឃុំខ្លួន *អៀង ធីរិទ្ធ* កថាខណ្ឌ៩។

ការដម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[238] អរិភាពពីមុនចំពោះជនទាំងឡាយណាដែលគាំទ្រចំពោះការជំនុំជម្រះមន្ត្រីខ្មែរក្រហមជាន់ខ្ពស់ ឬជនទាំងឡាយណាដែលជាប់ទាក់ទងនឹងជនជាប់ចោទ[239] និងការភ័យខ្លាចរបស់សាក្សី និងជនរងគ្រោះ[240]។

80. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ហានិភ័យដែលជនជាប់ចោទអាចជ្រៀតជ្រែកសាក្សី ឬជនរងគ្រោះ ឃុបឃិតជាមួយសហជនជាប់ចោទ ឬក្លែងបន្លំភ័ស្តុតាង គឺលែងមានទៀតហើយ។ ជាការពិតទទ្បីករណ៍នេះ ត្រូវបានលុបចោលដោយសារមូលហេតុសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទ ក្នុងអំឡុងពេល ពិនិត្យសារឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងខែ កម្ភៈ ឆ្នាំ ២០១១[241]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល ធ្វើការពិចារណាឃើញថា ដោយសារតែការចុះខ្សោយសតិបញ្ញារបស់គាត់ ជនជាប់ចោទមានលទ្ធភាពតិចតួចក្នុងការកំណត់អត្តសញ្ញាណជាមុនថាតើនរណាជាសាក្សី និងជនរងគ្រោះ និងបន្ទាប់មកចូលទៅទាក់ទងដោយចេតនាជាមួយអ្នកទាំងនោះ។ លទ្ធភាពក្នុងការទាក់ទងជាមួយសហជនជាប់ចោទ លើកលែងតែស្វាមីរបស់គាត់ និងការឃុបឃិតជាមួយសហជនជាប់ចោទ គឺវាកាន់តែមិនអាចទៅរួច ដោយសារតែសហជនជាប់ចោទ កំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក។ ដោយពិចារណាលើលក្ខខណ្ឌបច្ចុប្បន្នរបស់ជនជាប់ចោទ និងការលំបាករបស់គាត់នៅក្នុងការប្រើប្រាស់ពាក្យពេចន៍ច្បាស់លាស់មួយ គ្មានការគម្រាមកំហែងណាមួយអាចនឹងកើតឡើងពិតប្រាកដនោះទេ។ នៅក្នុងគ្រប់ករណី ជនជាប់ចោទមានទឹកចិត្តតិចតួចណាស់ក្នុងការជ្រៀតជ្រែកសាក្សីណាមួយ ឬច្រើន ដោយសារតែកិច្ចដំណើរការនីតិវិធីលើរូបគាត់ ត្រូវបានផ្អាកដោយមិនមានពេលកំណត់។ ជាការពិត អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចាប់តាំងពីពេលដោះលែងជនជាប់ចោទកាលពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២ ជនជាប់ចោទមិនមានចេតនាណាមួយដែលបង្ហាញឲ្យឃើញថា គាត់ប៉ុនប៉ងធ្វើបែបនេះឡើយ។

***ការពិនិត្យមើលឡើងវិញនូវលក្ខខណ្ឌ***

---

[238] ដីកាសម្រេចដំបូងឃុំខ្លួន *អៀង ធីរិទ្ធ* កថាខណ្ឌ៧។ ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនឆ្នាំ២០០៨ លើ *អៀង ធីរិទ្ធ* កថាខណ្ឌ២៧ (កត់សម្គាល់ឃើញថា ភាពជឿនលឿននៃការស៊ើបអង្កេត បង្កើតជាហានីភ័យកាន់តែខ្លាំង)។ សាលដីកាលើដីកាដំណោះស្រាយទាក់ទិននឹងការឃុំខ្លួន កថាខណ្ឌ ១៦២៣។ សាលដីកា ខែ មករា ឆ្នាំ ២០១១ ស្តីពី *អៀង ធីរិទ្ធ* កថាខណ្ឌ៥។

[239] ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនឆ្នាំ២០០៨ លើ *អៀង ធីរិទ្ធ* កថាខណ្ឌ ៤៨។ដ ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនឆ្នាំ២០០៨ លើ *អៀង ធីរិទ្ធ* កថាខណ្ឌ ២៦។ សាលដីការបស់ អ.ប.ជ ឆ្នាំ២០០៩ ស្តីពី *អៀង ធីរិទ្ធ* កថាខណ្ឌ៤២។

[240] ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនឆ្នាំ២០០៨ លើ *អៀង ធីរិទ្ធ* កថាខណ្ឌ ២៦។

[241] សេចក្តីសម្រេចដោះលែងរបស់អង្គជំនុំជម្រះសាលាដំបូង ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤១។

81. ដើម្បីធានាថា ជនជាប់ចោទមិនត្រូវបានដាក់កំហិតតាមអំពើចិត្ត លើសិទ្ធិជាឯកជន និងសេរីភាពក្នុងការដើរហើរ វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវតែបានពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង ជារៀងរាល់ ១២ ខែម្តង ឬនៅពេលណាមួយបន្ទាប់ពីមានសំណើសុំ ដូចមានចែងនៅក្នុងមាត្រា ២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៦៥ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការពិនិត្យមើលឡើងវិញជាប្រចាំឆ្នាំ ត្រូវការសម្រេចត្រឹមតែ បញ្ហាថាតើ លក្ខខណ្ឌនីមួយៗនៅតែបន្តមានលក្ខណៈសមស្រប ចាំបាច់ និងត្រឹមត្រូវ ដែរ ឬយ៉ាងណា ប៉ុណ្ណោះ។ ការពិនិត្យឡើងវិញនេះ មិនបានរួមបញ្ចូលវាយតម្លៃឡើងវិញលើសម្បទាដើម្បីចូលរួមក្នុងសវនាការរបស់ជនជាប់ចោទទេ លើកលែងតែមានការផ្លាស់ប្តូរនៃកាលៈទេសៈ។

## VI. **ផ្នែកសម្រេចសេចក្តី**

**យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលៈ**

**សម្រេចទទួលយក** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាដោយផ្នែក។

**បដិសេធ** សេចក្តីសម្រេចដែលរងការជំទាស់ ត្រង់ចំណុចដែលអង្គជំនុំជម្រះសាលាដំបូង បានបដិសេធមិនបង្គាប់ដាក់វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ("បដិសេធរាល់វិធានការទាំងឡាយដែលស្នើឡើងដោយសហព្រះរាជអាជ្ញា")។

**បង្គាប់** ឱ្យមានរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលតម្រូវឱ្យជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបំពេញដូចតទៅ:

(១) ជូនដំណឹងដល់ការិយាល័យរដ្ឋបាល មុនពេលផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ជនជាប់ចោទ

(២) មិនឲ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងនោះទេ

(៣) ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង

(៤) ត្រូវបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យផ្នែកសន្តិសុខ ដែលអនុវត្តដោយ[នគរបាលយុត្តិធម៌ ឬអាជ្ញាធរមូលដ្ឋាន]មួយខែម្តង ដើម្បីបញ្ជាក់ការអនុវត្តនូវវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានលើកឡើងខាងលើ។ ជម្រើសផ្សេងមួយទៀត អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថា ជនជាប់ចោទ ត្រូវផ្តល់របាយការណ៍ប្រចាំខែ តាមរយៈអ្នកអាណាព្យាបាលទូទៅរបស់ជនជាប់ចោទជូនដល់អង្គជំនុំជម្រះសាលាដំបូង ឬមន្ត្រីដែលបានជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីបញ្ជាក់នូវការអនុវត្តតាមវិធានការនៃការត្រួពិនិត្យតាមផ្លូវតុលាការដែលបានរៀបរាប់ខាងលើ។

**បង្គាប់** ឱ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់ជនជាប់ចោទ ជូនទៅអ្នកអាណាព្យាបាលទូទៅ ដោយភ្ជាប់នូវលក្ខខណ្ឌថា មិនត្រូវប្រើលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណទាំងនេះ ក្នុងគោលបំណងធ្វើដំណើរទៅបរទេស ដោយគ្មានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះនោះទេ។

**បង្គាប់** នគរបាលយុត្តិធម៌ ធ្វើការត្រួតពិនិត្យជាប្រចាំខែនៅអាសយដ្ឋានដែលជនជាប់ចោទផ្តល់ជូនទៅតុលាការ ដើម្បី i) បញ្ជាក់ថា ជនជាប់ចោទនៅស្នាក់នៅអាសយដ្ឋាននេះ និងមិនបានចាកចេញពីប្រទេស និង ii) រាយការណ៍អំពីការគម្រាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ជនជាប់ចោទអនុលោមតាមកាតព្វកិច្ចរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសន្តិសុខរបស់ជនជាប់ចោទ និងរាយការណ៍ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

**ណែនាំ** ឱ្យការិយាល័យរដ្ឋបាលផ្តល់នូវការគាំទ្រចាំបាច់ផ្នែករដ្ឋបាលទាំងអស់ ក្នុងការអនុវត្តសេចក្តីសម្រេចនេះ ដោយរួមបញ្ចូលទាំង ការជូនដំណឹងអំពីសេចក្តីសម្រេចនេះ ជូនដល់អាជ្ញាធរពាក់ព័ន្ធរបស់ប្រទេសកម្ពុជា ដើម្បីឱ្យពួកគាត់អនុវត្តសកម្មភាពរបស់ខ្លួន។

**បង្គាប់** ឱ្យលុបចេញវិធានការបណ្តោះអាសន្ន ដែលប្រធានអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់នៅក្នុងដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C

**គង់ ស្រ៊ឹម**